# សម្ភាសន៍ជាមួយឈ្មោះ ស៊ុម សល់ ភេទប្រុស អាយុ៥១ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហមៈ សន្តិសុខគុកភ្នំត្រយោង
## ស្រុកកំណើតនៅភូមិស៊ីងកំបត់ ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង
## សព្វថ្ងៃរស់នៅភូមិចក្រី ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា
## ០២:០៤:១៤
## ៥៩ ទំព័រ

ដានី : បាទ! ពួកខ្ញុំពីរនាក់នេះពូ ខ្ញុំឈ្មោះ ដានី ហើយគាត់ឈ្មោះ ដារ៉ា ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហីមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងធ្វើការងារទាក់ទងទៅនឹងការប្រមែរប្រមូលឯកសារនៅក្នុងសម័យខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់១៩៧៩ ពួកខ្ញុំមកជួបពូនេះគឺខ្ញុំចង់ជួបសួរនាំលោកពូទាក់ទងហ្នឹង ជាពិសេសបទពិសោធន៍លោកពូដែលធ្លាប់បានឆ្លងកាត់សម័យខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់៧៩ ណាពូ ហីការដែលពួកខ្ញុំមកសួរនាំចង់ដឹងពីបទពិសោធន៍របស់ពូនេះ គឺពួលខ្ញុំចង់ចងក្រងទុកជាឯកសារសម្រាប់ឲ្យក្មេងជំនាន់ក្រោយសម្រាប់ឲ្យអ្នកសិក្សាស្រាវជ្រាវ អ្នកដែល ជាពិសសមនុស្សទូទៅដែលគេចង់ដឹង គេចង់អានទាក់ទងពីប្រវត្តិ ពីរឿងរ៉ាវនៅក្នុងសម័យខ្មែរក្រហម បានដឹងបានឮ ណាពូ ដូចថាពូដែលធ្លាប់បានធ្លងកាត់ហ្នឹង គឺមានរឿងរ៉ាវច្រើនដេលក្មេងៈជំនាន់ ដូចពួកខ្ញុំចង់ដឹងណាពូអីចឹងពេលដែលពួកខ្ញុំសួរនាំលោកពូនេះ ពូមានអនុញ្ញាតិឲ្យពួកខ្ញុំសួរនាំពូពីបទពិសោធន៍លោកពូទេ!

សល់ : បាទ! មានអីឲ្យសួរតើ! ខ្ញុំមិនថាបេះទេ វាល្ងង់ដែរណា អាយុច្រើនមែន ដូចថាការរៀនសូត្រនោះមិនសូវបានរៀនដែរពីដើមនោះ ។

ដារ៉ា : ហីពូនៅមានការងឿងឆ្ងល់អីដែរ ចំពោះពួកខ្ញុំទាំងពីនាក់ ឬក៏កន្លែងធ្វើការងាររបស់ពួកខ្ញុំនេះ?

សល់ : បាទ! បេះតែនឹកឃើញឆ្ងល់ដែរថា ចុះបង ហ៊ុយ គាត់ហៅខ្ញុំធ្វើអី ពីបីថ្ងៃមុននោះម្សិលមិញ ម្សិលម្ងៃណា គាត់ថាឲ្យមកបំភ្លឺ ពីរឿងដែលយើងរយៈកាលកន្លងមក ពាក់ពន្ធនឹងត្រយោងអីណា ។

ដារ៉ា ៖ ចុះពូបានស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដូច ដានី បានរៀបរាប់មិញ ពីមុនមកធ្លាប់ឮទេពូ?

សល់ ៖ ទេ! មិនសូវដែរបានយកចិត្តទុកដាក់ផង ។

ដារ៉ា ៖ ដូច ដានី បានរៀបរាប់ប្រាប់មុនហ្នឹងអីចឹងថាយើងទាំងពីរនាក់នេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាកន្លែងដែលស្រាវជ្រាវនិងចងក្រងឯកសារ និងពត៌មានផ្សេងៗទាក់ទងទៅនឹងរបបខ្មែរក្រហម យើងចងក្រងឯកសារនេះ គឺយើងទុកបម្រើដល់ផ្នែកប្រវត្តិសាស្រ្ដដល់កូនចៅជំនាន់ក្រោយបានរៀនសូត្រពីបទពិសោធន៍ ដែលបានកើតឡើងពីអតីតកាលពិសេសគឺក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ៧៥ ដល់៧៩ ហ្នឹងណា យើងចុះមកសម្ភាសន៍អ្នកដែលជាជនរងគ្រោះ អ្នកដែលធ្លាប់បម្រើក្នុងរបបខ្មែរក្រហម ឬក៏បងប្អូនដែលមានកូនចៅអីទៅបម្រើក្នុងជួរខ្មែរក្រហម តែបាត់ដំណឹងបាត់អីណាពូ រឿងរ៉ាវទាំងអស់ហ្នឹង គឺដើម្បីយកមកចងក្រង យកមកប្រើប្រាស់ជាផ្នែកប្រវត្តិសាស្រ្ដផ្សេងៗទៅថ្ងៃមុខអីចឹងពូ មុននឹងចាប់ផ្ដើមនេះ ខ្ញុំសូមអនុញ្ញាតិពីលោកពូ ស្គាល់ឈ្មោះលោកពូឈ្មោះអី?

សល់ ៖ ខ្ញុំ ឈ្មោះ ស៊ុម សល់ ។

ដារ៉ា ៖ ស៊ុម សល់ លោកពូសរសេរយ៉ាងម៉េចដែរលោកពូ?

សល់ ៖ ស ដាក់ត្រីស័ព្ទ ស្រះ, និង ម ។

ដានី ៖ ចុះ សល់ សរសេររបៀបម៉េចវិញ?

សល់ ៖ ស និង ល បន្ដក់ ។

ដានី ៖ លោកពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

សល់ ៖ ខ្ញុំ ៥១ ។

ដារ៉ា ៖ លោកពូកើត ថ្ងៃខែ ឆ្នាំ កំណើតពូអី ពូចាំទេ?

សល់ ៖ ខ្ញុំឆ្នាំជូត ។

ដារ៉ា ៖ ស្រុកកំណើតពូកើតជានៅឯណាដែរ?

សល់ ៖ កំណើតខ្ញុំនៅស្ទឹងកំបត់យើងនេះ ។

ដារ៉ា ៖ ភូមិ?

សល់ ៖ ភូមិស្ទឹងកំបត់ ។

ដារ៉ា ៖ ឃុំអីគេ?

សល់ ៖ ឃុំរហាល ។

ដារ៉ា ៖ ឃុំ រហាល!

សល់ ៖ បាទ! ស្រុកព្រះនេត្រព្រះយើង ។

ដារ៉ា ៖ កាលហ្នឹងដូចជាខេត្ត យើងនៅ...

សល់ ៖ ខេត្តបាត់ដំបង កាលសម័យលន់ នល់ ខេត្តបាត់ដំបង ដល់សម័យយើងគេកែមកដាក់បន្ទាយមានជ័យវិញ ។

ដារ៉ា ៖ សព្វថ្ងៃពូរស់នៅ!

សល់ ៖ បាទ! បច្ចុប្បន្ននេះនៅហ្នឹង ជប់យើង ចក្រី ។

ដារ៉ា ៖ ជាភូមិគេហៅភូមិអី?

សល់ ៖ ភូមិ កន្លែងខ្ញុំនៅ គេហៅ ជប់ចក្រី ។

ដារ៉ា ៖ ភូមិ ជប់ចក្រី?

សល់ ៖ បាទ! ភូមិ ចក្រី ឃុំ ជប់វ៉ារី ។

ដារ៉ា ៖ ឃុំជប់វ៉ារីវិញ មិនមែនឃុំព្រះនេត្រព្រះទេ?

សល់ ៖ ទេ! អានេះអត់មែនខាងព្រះនេត្រព្រះទេ ខាងជប់វ៉ារី ឃុំជប់វ៉ារី ។

ដារ៉ា ៖ ឃុំ ជប់វ៉ារី ស្រុកព្រះនេត្រព្រះ!

សល់ ៖ បាទៗ!

ដារ៉ា ៖ ខេត្តបន្ទាយមានជ័យ?

សល់ ៖ បាទ!

ដារ៉ា ៖ លោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

សល់ ៖ ខ្ញុំច្រើនណាស់បង ដល់អីចឹងរាប់វាមិនអស់ ខ្ញុំកូនទី១ ។

ដារ៉ា ៖ ពូជាកូនទី១ នៅក្នុងគ្រួសារ?

សល់ ៖ បាទ! កូនទី១នៅក្នុងគ្រួសារ ។

ដារ៉ា ៖ តែប៉ុន្មាននាក់ទៅបងប្អូន?

សល់ ៖ ច្រើនណាស់ ទី១ខ្ញុំ ទី២ ទី៣ ទី៤ អូច្រើនណាស់រាប់មិនអស់ទេ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មានទៅលោកពូអាចរៀបរាប់?

សល់ ៖ បងប្អូនខ្ញុំឯងបង្កើតនោះវាច្រើន រាប់វាមិនអស់ ចាស់ពីដើមកូនច្រើន (សើច!) ។

ដារ៉ា ៖ ឪពុកម្តាយលោកគាត់នៅរស់?

សល់ ៖ នៅរស់សព្វថ្ងៃ ។

ដារ៉ា ៖ ឪពុកឈ្មោះអី?

សល់ : ឈ្មោះ ផាន់ ។

ដារ៉ា : ស៊្មី ផាន់ ពូ?

សល់ : ស៊ុម ផាន់ ។

ដារ៉ា : អឺចឹងត្រកូលពូយកត្រកូលតាមឪពុក?

សល់ : បាទ!

ដារ៉ា : ស៊ុម ផាន គាត់អាយុប៉ុន្មានហើយ?

សល់ : អាយុ ឆ្នាំច គាត់អាយុ ៧០ប៉ុន្មានហើយទេ ។

ដារ៉ា : ខ្ទង់ ៧០ ហើយន៎!

សល់ : បាទ! ៧៤, ៧៥ ។

ដារ៉ា : គាត់នៅរស់ទេ?

សល់ : បាទ! ម្តាយក៏នៅដែរ ។

ដានី : ម្តាយឈ្មោះអីដែរ?

សល់ : ម្តាយឈ្មោះ ដួប នៅ ។

ដារ៉ា : គាត់នៅរស់ដែរ?

សល់ : បាទ! ចាស់ៗអស់ហើយ ។

ដារ៉ា : អាយុប៉ុន្មានហើយ?

សល់ : ឆ្នាំខាល ក្បែរៗប៉ុន្មានទេ ។

ដារ៉ា : គាត់នៅភូមិជាមួយពូដែរ?

សល់ : បាទ! នៅស្ទឹងកំបត់ហ្នឹងឯង ។

ដារ៉ា : នៅភូមិកំណើតរបស់ពូ?

សល់ : បាទ!

ដារ៉ា : ហើពូមានគ្រួសារឈ្មោះអីដែរ?

សល់ : គ្រួសារឈ្មោះ តូ វ៉ាន់យើន ។

ដារ៉ា : គ្រួសារពូ អាយុស្រកៗពូដែរ?

សល់ : បង់ខ្ញុំមួយឆ្នាំ ។

ដារ៉ា : បង់មួយឆ្នាំ!

សល់ : បាទ! ឆ្នាំកុរ ។

ដារ៉ា : ហើពូមានកូនចៅប៉ុន្មាននាក់ដែរ?

សល់ ៖ កូន ៨ ប៉ុនស្លាប់មួយ ហើយ នៅតែ ៧ ។

ដារ៉ា ៖ ស្លាប់ហ្នុង ស្លាប់នៅសម័យ យើងនេះទេ?

សល់ ៖ ស្លាប់សម័យ យើងនេះឯង ។

ដារ៉ា ៖ កូន៨នាក់ ហីស្លាប់...

សល់ ៖ ស្លាប់មួយ ។

ដារ៉ា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

សល់ ៖ កូនស្រី ៤ ប្រុស ៣ ៧នាក់ ស្លាប់មួយ វា៨ស្មើគ្នា ។

ដារ៉ា ៖ ចុះកូនបងអាយុប៉ុន្មានហើយ?

សល់ ៖ ឆ្នាំ កុរ!

ដារ៉ា ៖ វាចូលអាយុសាមហើយ?

សល់ ៖ បាទ! វាខ្ទង់សាមហ្នុងឯង ។

ដារ៉ា ៖ កូនទាំងអស់បានគ្រួសារ បានអីហើយឬនៅ?

សល់ ៖ បាទ! បានគ្រួសារ២ ផុតនោះនៅទាំងអស់ ។

ដារ៉ា ៖ ហីបានរៀនប៉ុន្មាននាក់អីដែរ?

សល់ ៖ រៀនទាំងអស់គ្នាហ្នឹងឯង បាទ!មួយនោះរៀនដល់សកលវិទ្យាល័យ ។

ដារ៉ា ៖ នៅឯណា?

សល់ ៖ នៅទឹកថ្លា យើង ។

ដារ៉ា ៖ នៅទួលមខេត្តបន្ទាយមានជ័យ?

សល់ ៖ បាទ! អនុបណ្ឌិត ។

ដារ៉ា ៖ អនុបណ្ឌិតផង?

សល់ ៖ បាទ! មួយទៀតនោះ ១២ ថ្នាក់ មួយទៀតនោះ ១១, ១២ តាមឋានៈនោះឯង ប៉ុនមិនទាន់បានការងារអីធ្វើទេ ។

ដារ៉ា ៖ មានកូនរៀនដល់ថ្នាក់អនុបណ្ឌិតដែរ?

សល់ ៖ បាទ!

ដារ៉ា ៖ រៀនចប់នៅ?

សល់ ៖ ចប់ហើយ ក៏បានប្ដីទៅ ក៏មិនទាន់បានធ្វើការងារអីទេ ។

ដានី ៖ ស្រីទេ ដែលរៀនបានអនុបណ្ឌិតហ្នុង?

សល់ ៖ បាទ! ស្រី ។

ដាវ៉ី ៖ រៀនផ្នែកអី?

សល់ ៖ រៀនផ្នែកខាងពេទ្យសត្វ ។

ដាវ៉ី ៖ ខាងពេទ្យសត្វល្អ!

សល់ ៖ បាទ! ប៉ុន្តែមិនទាន់បានចាប់ការងារអីទេ ។

ដាវ៉ី ៖ ទើបរៀនចប់ថ្មីៗ ?

សល់ ៖ បាទ! ទើបរៀនចប់ថ្មីៗ ដល់យើងមានកូន ។

ដាវ៉ី ៖ ពូបានគ្រួសារអីនៅក្នុងឆ្នាំណា នៅក្នុងសម័យណា?

សល់ ៖ ខ្ញុំបានគ្រួសារនៅសម័យ ឆ្នាំវាភ្លេចហើយ ប្រហែលជា៨២, ៨៣ ហ្នឹងឯង ។

ដាវ៉ី ៖ ៨២, ៨៣ នេះទេ!

សល់ ៖ បាទ!

ដាវ៉ី ៖ អីចឹងបានគ្រួសារហ្នឹងក្រោយពីរបបខ្មែរក្រហមទេ?

សល់ ៖ បាទៗ! បានក្រោយ រៀបចំការត្រឹមត្រូវ ។

ដាវ៉ី ៖ ពីតូចៗមកពូបានរៀន បានចូលសាលារៀនអីហ្នឹងគេដែរ?

សល់ ៖ រៀនដែរ! ប៉ុន្តែរៀនអត់បានខ្ពង់ខ្ពស់ណា ទើបរៀនបានថ្នាក់ទី២ នៅស្រុកយើងវាសង្គ្រាម ពេកទៅ អត់បាន នៅរត់ទៅលូន មិនបានឈប់ទេ ។

ដាវ៉ី ៖ រៀនថ្នាក់ទី២!

សល់ ៖ បាទ!

ដាវ៉ី ៖ ថ្នាក់ទី២ បើធៀបមកឥឡូវវាថ្នាក់ទី១០!

សល់ ៖ ទេ! អាទី២ យើងហ្នុងឯង ។

ដាវ៉ី ៖ ទី២ យើងទេ?

សល់ ៖ បាទ! អាទី២ តូច ។

ដាវ៉ី ៖ ទី២ តូចទេ?

សល់ ៖ បាទ! ពីដើមហៅ ១២ពីសង្គមណា យើងពីដើមរាប់ពីធំទៅរកតូច ។

ដានី ៖ ដល់អីចឹង ពូរៀនថ្នាក់ទីប៉ុន្មានកាលហ្នុង?

សល់ ៖ ទី២ ប៉ុណ្ណុងឯង ។

ដានី ៖ រាប់ពីថ្នាក់ទី ១២ មកដល់ទីប៉ុន្មាន?

សល់ ៖ រៀនថ្នាក់ទី២ ក៏ឈប់បណ្តោយ ថ្នាក់ទី១ ថ្នាក់ទី២ មគេយ្យនោះណា នៅស្ទឹងកំបត់នោះ សង្គ្រាមមកដល់ ។

ដារ៉ា ៖ ឆ្នាំណាពូចូលរៀន?

សល់ ៖ ខ្ញុំដូចជាក្មេចហើយដល់វាយូឆ្នាំពេកទៅ ទើបរៀនថ្នាក់ទី២ ដល់រៀនទៅ ដល់គ្រូរត់ចោលអស់ហើយ អត់មាននៅ គ្រូនៅមណ្ឌលបុរី គ្រូណាមយើង ។

ដារ៉ា ៖ គ្រូណាម!

សល់ ៖ បាទ! គ្រូណាម ដែលគាត់នៅមណ្ឌលបុរីយើង គាត់ទើបហ្នឹងខូចណា ហ្នុងហើយគ្រូខ្ញុំពីដើម ។

ដារ៉ា ៖ រៀនបានប៉ុន្មានឆ្នាំទើបស្រុកភូមិពូ គេហៅរំដោះអីចឹងណា?

សល់ ៖ រៀនបានប្រហែលជា២ឆ្នាំ ៣ឆ្នាំ រៀនមិនបានវែងឆ្ងាយទេ គិតតែពីរត់លូន ខ្មែរក្រហមគេចូលមក គេរករឿងគ្រូបង្រៀនទៅ គ្រូបង្រៀនក៏រត់អស់ទៅ ខ្ញុំដល់អ្នកស្រែអ្នកចម្ការមើលតែគោមើលតែក្របី ឃ្វាលតែគោឃ្វាលតែក្របីដាច់មាត់ដាច់កអស់មិនឃើញ សល់តែគោ ដើរឃ្វាលតែគោចាស់ពីដើម ។

ដារ៉ា ៖ ពូរៀនថ្នាក់ទី២ហ្នឹង ចង់សំដៅថាមុនរបបលន់ នល់ ឬ?

សល់ ៖ បាទ! សម័យ លន់ នល់ ណា បានរៀនសម័យ លន់ នល់ បានថ្នាក់ទី២ ។

ដារ៉ា ៖ រៀននៅសាលាណាដែរពូកាលហ្នុង?

សល់ ៖ នៅសាលាសំបូរយើង ស្រុកមណ្ឌលបុរី ម្ខាងស្ទឹងម្នាក់ណា ខាងណេះស្រុកមណ្ឌលបុរី ។

ដារ៉ា ៖ រៀននៅសាលាសំបូរ?

សល់ ៖ បាទ!

ដារ៉ា ៖ រៀនបានប៉ុន្មានឆ្នាំទើបខ្មែរក្រហមចូលមកដល់?

សល់ ៖ បាន៣ឆ្នាំ ២ទៅ៣ឆ្នាំហ្នុង ខ្មែរក្រហមគេចូលមក គេចេញចូលៗតឹងរហូតមកណា គេចូលមកកាន់កាប់នៅ ចេញចូលៗ ខាងលន់ នល់ មិនហ៊ានទៅ ខាងណេះគេមិនហ៊ានមក គេខ្ជិលកាន់កាប់ ប្រទាញប្រទង់គ្នា ហីយើងមើលតែគោ មើលតែក្របីទៅ ។

ដានី ៖ ក្នុងឆ្នាំណាដែលលោកពូមានប្រសាសន៍ថា ខ្មែរក្រហមចូលមកប្រទាញប្រទងគ្នាហ្នុង?

សល់ ៖ ពីឆ្នាំ កាលហ្នុងប្រហែលឆ្នាំ៧២ ។

ដារ៉ា ៖ ក្នុងឆ្នាំ៧២ហ្នឹង ពួកខ្មែរក្រហមមានចូលមកដល់ភូមិហើយ?

សល់ ៖ បាទ! ចូលមកដល់ហើយ ។

ដារ៉ា ៖ ចូលមកដល់កាន់កាប់ទាំងស្រុង ឬក៏នៅប្រទាញប្រទង់ជាមួយខាង លន់ នល់?

សល់ ៖ នៅប្រទាញប្រទងគ្នា ។ ប្រទាញប្រទងៗណា ។

ដារ៉ា ៖ អ៊ីចឹងពេលហ្នឹងស្ថានភាពប្រជាជននៅក្នុងភូមិយ៉ាងម៉េចដែរពូ ស្ថានភាពទម្លាក់គ្រាប់បែកទម្លាក់អីអត់?

សល់ ៖ ប្រជាជនកាលហ្នឹងព្រួយបារម្ភ ភ័យគ្រប់ៗតែគ្នាហ្នឹង ប៉ុន្មានយើងអ្នកស្រែអ្នកចម្ការយើងមិនដឹងទៅខាងណា មិនឆាយបោលស្រុកដូចក្មេងៗយើងសព្វថ្ងៃទេណា ចាស់ពីដើមអាឡូវតែស្រែ អាឡូវតែចម្ការហ្នឹងឯង មនុស្សពីដើមអត់ជឿនលឿនដូចសព្វថ្ងៃទេ មនុស្សពីដើមណា ច្រើនតែនៅត្រង់ណា នៅត្រង់នោះឯង មានក៏មិនរត់ អាក្រក់ក៏មិនទៅណា នៅចាំស្រុកចាំស្រែហ្នឹង ទល់តែដល់ឆ្នាំ៧៣ ៧៣ទាហានលន់ នល់ វ៉ៃគៀរយកមក ។

ដារ៉ា ៖ គៀរពីណាមកវិញ?

សល់ ៖ គៀរពីស្ទឹងកំបត់មកនៅលើយើង ។

ដារ៉ា ៖ លើហ្នឹងសំដៅនៅកន្លែងណា?

សល់ ៖ លើហ្នឹងសំដៅ ឧបមាថាខ្លះទៅនៅជប់ទៅ ខ្លះទៅនៅទឹកថ្លាទៅ ខ្លះទៅនៅស្វាយទៅ តាមកម្រិតគេអ្នកមានអ្នកក្រណា គេអ្នកមាន គេមានទឹកលុយទៅគេចូលផ្សារទៅ ខ្លះគេអ្នកក្រនៅជាយៗរកស្រែ រកភូមិករទៅណា ដល់ឆ្នាំ៧៥ចប់ទៅបានចូលស្រុកវិញ ។

ដារ៉ា ៖ ទៅភូមិនៅនោះវិញ?

សល់ ៖ បាទ! ដើរនៅស្រុកគេ អាភូមិអាករយើងត្រូវឆេះអស់រលីញហើយ គ្មានសល់ទេ ។

ដារ៉ា ៖ អ៊ីចឹងពេលឆ្នាំ៧៥ ពេលដែលខ្មែរក្រហមបានកាន់កាប់ទាំងស្រុងអ៊ីចឹង ក្រុមគ្រួសារពូត្រូវបានផ្ទេរចូលភូមិវិញ?

សល់ ៖ បាទ! ៧៥ចូលវិញ ។

ដារ៉ា ៖ ចូលភូមិវិញ?

សល់ ៖ បាទ! ចូលភូមិវិញ ។

ដារ៉ា ៖ ចូលវិញ ចូលក្នុងក្រុមគ្រួសារបងប្អូនឪពុកម្ដាយពូអីទាំងអស់?

សល់ ៖ បាទ! ទៅទាំងអស់វិញ ។

ដារ៉ា ៖ ចុះពេលដែល៧៥ ចូលភ្លាមមកអ៊ីចឹងនៅក្នុងភូមិពូមានរៀបចំជាប្រធានភូមិប្រធានឃុំអីនៅពូ?

សល់ ៖ បាទ! គេចប់៧៥ គេរៀបចំហើយ ពួកខ្មែរក្រហមគេបង្កើតប្រធានភូមិ ប្រធានក្រុមអីណា គេអត់ឲ្យនៅស្រុកកំណើតទេ ដល់នេះនៅបានម៉ាភ្លូវរួច គេឲ្យមកនៅភ្នំកូនដីរយើងនេះ អាភ្នំកូនដីរខាងត្បូងព្រះនេត្រព្រះនោះណា ។

ដារ៉ា ៖ ពេលពូចូលមកភូមិវិញ ពួកខ្មែរក្រហម ឆ្នាំ៧៩ហ្នឹង បានរៀបចំជាប្រធានភូមិ ជាក្រុមហើយណាពូ?

សល់ ៖ បាទ!

ដារ៉ា ៖ រៀបចំ ពូអាចដឹងឈ្មោះអ្នកណា អីអ្នកណាអីទេ?

សល់ ៖ ស្លាប់បាត់ហើយ ប្រធានភូមិនោះ ។

ដារ៉ា ៖ គាត់ឈ្មោះអីដែរ?

សល់ ៖ ឈ្មោះ ហ៊ាន ។

ដារ៉ា ៖ ឈ្មោះ ហ៊ាន ជាប្រធានភូមិ!

សល់ ៖ បាទ!

ដារ៉ា ៖ ពូមានប្រសាសន៍ថានៅបានម៉ាភ្លូរួច?

សល់ ៖ បាទ!

ដារ៉ា ៖ មានន័យថាម៉ារដូវ!

សល់ ៖ ម៉ារដូវបានឲ្យមកនៅភ្នំកូនដំរី ។

ដារ៉ា ៖ មកនៅភ្នំកូនដំរី!

សល់ ៖ កូនដំរីយើង ព្រះនេត្រព្រះនេះ ។

ដារ៉ា ៖ ក្រុមគ្រួសារត្រូវបានជម្លៀសទៅភ្នំកូនដំរីទាំងអស់ឬក៏ម៉េចដែរ?

សល់ ៖ បាទ! គេជម្លៀសមកភ្នំកូនដំរីទាំងអស់ ម៉ាភូមិនោះមកទាំងអស់ ។

ដារ៉ា ៖ ម៉ាភូមិរហាលដែលពូនិយាយម៉េចហ្នឹងឬ?

សល់ ៖ បាទទេ! ម៉ាភូមិស្ទឹងកំបត់ហ្នុង គេដេញអត់ឲ្យនៅភូមិកំណើតទេ ៧៩ណា ដល់ចប់យើងចូលស្រុកវិញ ដល់នេះគេដេញឲ្យមកនៅភ្នំកូនដំរីវិញ ខាងត្បូងព្រះនេត្រព្រះ ។

ដារ៉ា ៖ អីចឹងពេលដេញមកដល់ភ្នំកូនដំរីវិញហើយអីចឹង នៅភ្នំកូនដំរី អ្នកណាទទួលខុសត្រូវអ្នកណាអីទៅ ពេលដែលប្រជាជនទៅដល់?

សល់ ៖ បាទ! កាលនោះប្រធានភូមិហ្នុងឯង កាលមិនទាន់ស្លាប់ណា ឈ្មោះ ហ៊ាន ហ្នឹងអ្នកទទួលខុសត្រូវ នៅធ្វើការហ្នុង ។

ដារ៉ា ៖ អីចឹងឈ្មោះ ហ៊ាន ដែលជាប្រធានភូមិនៅស្ទឹងកំបត់ហ្នុង ពេលដែលផ្ទេរប្រជាជនទៅចល័តប្រជាជនទៅភ្នំកូនដំរី គាត់ធ្វើជាប្រធានដដែល!

សល់ ៖ បាទ! កាលនោះគាត់មិនទាន់ស្លាប់ណា នៅជាប្រធានភូមិ ។

ដារ៉ា ៖ មកដល់ភ្នំកូនដំរី គាត់នៅជាប្រធានភូមិនៅឡើយ?

សល់ ៖ បាទ! គាត់នៅជាប្រធានភូមិ ។

ដារ៉ា ៖ កាលហ្នឹងពូអាយុប្រហែលប៉ុន្មានដែរ ធំប៉ុណ្ណា ប៉ុណ្ណឹងទៅ?

សល់ ៖ គិតមើល ខ្ញុំកាលនោះ ខ្ញុំ១០ឆ្នាំជាង ។

ដារ៉ា ៖ ១០ឆ្នាំជាងទេ?

សល់ ៖ បាទ! មានទៅធំ មានទៅអាយុច្រើនអី នៅកុមារដែរហ្នឹង កុមារដើរឃ្វាលគោហ្នឹង គេឲ្យទៅឃ្វាលគោនៅវាលភ្នំកូនដីរហ្នឹង ។

ដារ៉ា ៖ កាលនៅភ្នំកូនដីរហ្នឹង ពូនៅជាមួយឪពុកម្ដាយដែរឬយ៉ាងម៉េច ដូចថានៅកន្លែងកងកុមារដាច់តែម្ដង?

សល់ ៖ នៅជាមួយឪពុកម្ដាយដែរ ប៉ុនថាប្រធានភូមិគេឲ្យយើងឃ្វាលគោ ឲ្យឃ្វាលគោរួម ។

ដារ៉ា ៖ អីចឹងនៅជាមួយឪពុកម្ដាយដែរ?

សល់ ៖ បាទ!

ដារ៉ា ៖ ពេលឪពុកម្ដាយទៅធ្វើការ ពូនៅកងកុមារគេឲ្យឃ្វាលគោ?

សល់ ៖ បាទ ឃ្វាលគោ!

ដារ៉ា ៖ ឃ្វាលគោ មានកងឃ្វាលគោមានអីដែរ?

សល់ ៖ បាទមាន! កងឃ្វាលគោមាន គេឲ្យយើងឧបមាថា ម៉ាភូមិនេះវាត្រូវមានប្រធានមួយ ប្រធានកុមារដូចគ្នា គេឲ្យឃ្វាលគោកុំឲ្យបាត់ណា ដើរឃ្វាលមើលគោរួមទាំងអស់គ្នា ។

ដារ៉ា ៖ ចុះចំណែកឪពុកម្ដាយពូវិញ?

សល់ ៖ ធ្វើការកាប់គាស់ដាំដំឡូង ឥវ៉ាន់ក្នុងភ្នំរបស់រួម របស់រដ្ឋហ្នឹង ។

ដារ៉ា ៖ នៅភ្នំកូនដីរហ្នឹង?

សល់ ៖ បាទ! ឲ្យធ្វើការរស់ររួមទាំងអស់ យើងអត់មានរបស់ឯកជនទេ ដល់ពេលនោះសុទ្ធតែរបស់រួមទាំងអស់ ។

ដារ៉ា ៖ ពេលហូបចុះអី ហូបចុកជាមួយឪពុកម្ដាយដែរ ឬក៏ហូបចុកដាច់ដោយឡែកនៅកងកុមារ?

សល់ ៖ កាលនោះ វា៧៥ ទើបរៀបចំ មិនទាន់ហូបបាយរួមទេណា នៅបើកឲ្យហូបឯកជនសិន ប៉ុន្តែវាមិនសូវមានអង្ករទេ គេបើកកន្ទួកឲ្យហូប កន្ទួកយើងរោងម៉ាស៊ីន បើកទៅគ្រួសារតិចគ្រួសារច្រើនទៅ កន្ទះៗកញ្ជើរទៅ យកទៅឲ្យហូប ។

ដារ៉ា ៖ ធ្វើម៉េចទៅកន្ទួក?

សល់ ៖ យកទៅលីញទៅប្រោសទឹកអំបិលទៅដើរអក ចុះយើងអត់ហើយ

ដារ៉ា:	អត់មានបាយទេ?

សល់:	អត់មានទេ ដល់ពេលអត់ៗ គេថាអង្ការមិនទាន់ដោះស្រាយបាន ដល់ពួកខ្ញុំទឹកភ្នែកជ្រក់ចុះយើងពេញឃ្លាន ពេញដេក ពេញហូប ក្មេងណាកត់ស្លុក ដើរអកកន្ទុកបណ្ដើរ ក៏ដើរឃ្វាលគោបណ្ដើរទៅ ខ្វះយំ ។

ដារ៉ា :	យំ!

សល់ :	យំវាលេបវាមិនចូល ចុះមនុស្សណាហូបកន្ទុកណា កន្ទុកដើរអក ។

ដារ៉ា :	អត់មានបាយសោះម៉ង?

សល់ :	ជួនកាលអត់ អត់មានបាយទេ ។

ដារ៉ា :	កាលហ្នឹងនៅក្នុងឆ្នាំ ៧៥?

សល់ :	បាទ! ក្នុងឆ្នាំ ៧៥, ៧៦ ។

ដារ៉ា :	អីចឹងក្នុងមួយរយៈកាលនោះ ពូអត់មានបានហូបបាយ ហូបបបរអីសោះតែម្ដង ឬក៏ម៉េចដែរ?

សល់ :	បាទ! ទល់តែ ។

ដារ៉ា :	រយៈពេលប៉ុន្មានដែលពូហូបតែកណ្ដុកស្លុទនោះ?

សល់ :	វាដូចថា វាមានកុនដោយថ្ងៃណា វាមិនមែនរាល់ថ្ងៃណាស់ណាក៏មិនមែនដែរ វាកុនដល់យូៗ ការខ្វះខាតវាច្រើនជាង អារឿងសំបូរអត់មានទេ អង្ករដូចថាមួយកំប៉ុងអីចឹងបបរទៅដាក់ទឹកច្រើនហុចទៅ បើយើងថាហូបមិនឆ្អែតក៏មិនបាន នៅតែស្ងៀមៗបានហើយ ។

ដារ៉ា :	ការឃ្វាលគោហ្នឹង សម្រាប់គោនៅក្នុងភូមិ?

សល់ :	បាទ!ក្នុងភូមិរួម ។

ដារ៉ា :	គោហ្នឹងដល់វាធំធាត់សម្រាប់ទៅយកទៅណាមកណា?

សល់ :	គេប្រើប្រាស!

ដារ៉ា :	ប្រើប្រាស់ជាភ្ជួរជាអី?

សល់ :	បាទប្រើប្រាស់ជាភ្ជួរជាអី រាស់ភ្ជួរអីទៅ ធ្វើស្រែរួមទៅណា យើងអត់មានសិទ្ធិយកមកជាឯកជនទេ របស់រួម ។

ដានី :	ចុះលោកពូកាលហ្នឹងឃ្វាលគោគ្នាប៉ុន្មាននាក់ទៅ?

សល់ :	អូ!ម៉ាភូមិច្រើនដែរ ចូល២០, ៣០នាក់ សុទ្ធតែកុមារៗ មួយភូមិៗច្រើន ៣០, ៤០នាក់ ។

ដាវ៉ា : ចុះគោប៉ុន្មានក្បាលទៅ?

សល់ : រាប់មិនអស់ទេ! រាប់រយក្បាល របស់រួមវាច្រើនៗ

ដាវ៉ា : មានគោបាត់ គោងាប់អីដែរអត់ពូ?

សល់ : អត់ដែលមានបាត់ មានងាប់អីទេ ពីព្រោះយើងចុះដាប់ ឃ្វាលដាប់ ថែវាដាប់ ដើរឃ្វាលដើរអីៗ

ដាវ៉ា : បន្ទាប់ពីការងារឃ្វាលគោហ្នឹងទៅឈានដល់ឆ្នាំណាអីណាបន្តទៀត?

សល់ : ដល់ឃ្វាលគោហ្នឹងរួច ដល់នេះបានគេផ្លាស់ទីលំនៅ ឲ្យមកនៅរហាល ម៉ែឪនោះណាៗ

ដាវ៉ា : ក្រុមគ្រួសារហ្នឹង!

សល់ : បាទ!

ដាវ៉ា : ទាំងពូដែរ?

សល់ : បាទ! ខ្ញុំនៅចល័តៗ

ដាវ៉ា : ចាប់ផ្ដើមមកនៅរហាលវិញ?

សល់ : បាទ!

ដាវ៉ា : មិនមែននៅភ្នំកូនដំរីទេ?

សល់ : បាទ! ចេះតែគេចមក អត់ឃ្លានណា មែឪចេះតែគេចៗមករកដំឡូងមករកអីហូបនៅណោះណាៗ

ដាវ៉ា : ចង់និយាយថាជារួម ជាក្រុមគ្រួសារពូទាំងមូលម៉ងណា ត្រូវបានផ្លាស់ប្តូរទៅនៅភូមិរហាលវិញ?

សល់ : បាទ!

ដាវ៉ា : ហីប្រធានភូមិជាឈ្មោះដដែល ហីមានដូរហើយពេលហ្នឹង?

សល់ : ខ្ញុំនៅចល័ត ឪពុកម្ដាយខ្ញុំនៅនោះ ខ្ញុំនៅចល័តគោកឈើនាងយើងនេះណាៗ

ដាវ៉ា : អីចឹងពេលផ្លាស់នៅរហាលនេះពូលែងនៅជាមួយឪពុកម្ដាយហើយពូនៅចល័តវិញ?

សល់ : បាទ! ទៅចល័ត នៅចល័តទាំងកាំៗ

ដាវ៉ា : ទៅចល័តហ្នឹងពូមានគ្នីគ្នាច្រើនទេនៅក្នុងកងចល័តពូ?

សល់ : ច្រើន! កាលហ្នឹងច្រើនមានស្រី មានប្រុសៗ

ដាវ៉ា : ប្រហែលប៉ុន្មាននាក់ដែរ?

សល់ : អូច្រើនណាស់
រាប់រយម៉ាមុខព្រួញទាំងអស់ដើរលើកដីពេញតែវាលទាំងកាំយើងឈើនាងៗ

ដារ៉ា ៖ អីចឹងពូថារាប់រយនៅកងចល័ត?

សល់ ៖ បាទ!

ដារ៉ា ៖ ហើពូចាំទេ កងចល័តហ្នឹង ប្រធាន អនុប្រធានអី?

សល់ ៖ មិននៅទេ ងាប់ហើយ ។

ដារ៉ា ៖ ប៉ុន្តែគ្រាន់តែចង់ស្គាល់ឈ្មោះ?

សល់ ៖ ឈ្មោះវ៉ាន មិនដឹងស្អី វ៉ានទេ ប្រធានមុខព្រួញហ្នឹង លើកតែដីរួចក៏គេសម្លាប់ចោល ។

ដារ៉ា ៖ ឈ្មោះវ៉ាន!

សល់ ៖ បាទ! មិនដឹងស្អីវ៉ានទេ មិនដឹងត្រកូលអីទេ ។

ដារ៉ា ៖ ស្រី ឬប្រុស?

សល់ ៖ ប្រុស ។

ដារ៉ា ៖ វ៉ានហ្នឹងអ្នកក្តាប់រួម!

សល់ ៖ បាទ! ប្រធានមុខព្រួញ ម៉ាចល័តរួមទាំងអស់លើគេ គេធំ ។

ដានី ៖ នៅទាំងកាំ?

សល់ ៖ បាទ! នៅគោកឈើនាងយើងនេះ អាផ្លូវហួសគិរីវ័ន្ត កូនដីរីនោះ ។

ដារ៉ា ៖ កងចល័តពូដែលគ្រប់គ្រងដោយឈ្មោះ វ៉ាន ហ្នឹង ដើរធ្វើការងារអីខ្លះទៅ ពូរៀបរាប់តាមលំដាប់លំដោយ?

សល់ ៖ ដើរលើកប្រព័ន្ធ ទំនប់ប្រឡាយតូចៗប្រព័ន្ធភ្លឺស្រែទៅណា ។

ដារ៉ា ៖ មុំណាដែរ?

សល់ ៖ មុំយើងអាចេញពីគិរីវ័ន្តហ្នឹងទៅវាលស្រែយើងនៅនោះណា លើកប្រព័ន្ធ លើកប្រឡាយយើង ទំនប់ ស្មើរៗ ក្បាលជន្លង់ ខ្ទង់អី ។

ដារ៉ា ៖ កាលលើកទំនប់ប្រឡាយហ្នឹង ការហូបចុកប្រសើរជាងមុន ឬយ៉ាងម៉េចពូ?

សល់ ៖ អត់ទេ! មិនប្រសើរទេ ការអត់ឃ្លានវានៅតែអត់អីចឹងឯង ប៉ុនចេះតែហូបបន្លែឈើត្រពាំងព្រិច ចេះតែផ្សេងផ្សំទៅណាយើងអត់ ហូបជំនួសទៅណា ដូចជាកណ្តុរ ដូចជាហូបស្អីទៅ ចេះតែឆ្នៃប្រឌិតហូបទៅណា ឲ្យតែមានកម្លាំង ។

ដារ៉ា ៖ កាលហ្នឹងពូមានរូបរាងយ៉ាងម៉េចដែរ?

សល់ ៖ ដើរមិនចង់រួច ស្គេកស្គាំងអស់ហើយ ។

ដារ៉ា ៖ ម៉េចទៅលើកទំនប់ទៅលើកអីបាន?

សល់ : អំណាចតែខ្លាចគេ ឧបមាថាអំណាចដែលយើងខ្លាចគេណា យើងកាលណុះអត់មានសិទ្ធិតវ៉ាជាមួយគេទេ បទបញ្ជាថាឲ្យធ្វើអីយើងត្រូវតែធ្វើ យើងអត់ហ៊ានប្រកែកជាមួយគេទេ ។

ដាវ៉ា : ចល័តរបស់ពូហ្នឹង ជាចល័តស្រុក ឬចល័តឃុំ ឬចល័តស្អី?

សល់ : ចល័តឃុំ ។

ដាវ៉ា : ឃុំអីកាលហ្នឹង?

សល់ : ឃុំដប់វ៉ារី ។

ដាវ៉ា : ចល័តឃុំដែលមានឈ្មោះវ៉ានជាប្រធានចល័ត?

សល់ : បាទ! ប្រធានមុខព្រៀញ ។

ដាវ៉ា : នៅក្នុងចល័តពូហ្នឹង ពូនៅមានស្គាល់អ្នកណាខ្លះទៅ?

សល់ : ភ្លេចអស់ហើយ ។

ដាវ៉ា : ដូចជាមិត្តភក្តិ ជាប្រធានកងអី!

សល់ : វាយូយារទៅហើយើងអត់ដែលបាននៅជុំគ្នាយូ ដល់នេះវាព្រាត់បែកគ្នា បែកចុះ បែកឡើង វាមិនសូវបាន ញឹកញាប់បាននៅជាន់យូឆ្នាំណា គ្រាន់យើងទៅបាន២,៣ខែ វារើរអីចេះ វារើរអីចុះទៅ គេចរៀងៗ តែខ្លួនទៅ ។

ដាវ៉ា : មកនៅចល័តឃុំហ្នឹងនៅឆ្នាំណាអីឆ្នាំណា?

សល់ : នៅកងចល័តកាលណុះនៅឆ្នាំ ១៩៧៧ ។

ដាវ៉ា : ជាខែ ជារដូវអី ដើម ឬ ចុងរដូវ?

សល់ : ៧៧ ។

ដានី : លោកពូផ្លាសមកនៅ គ្រួសារមកនៅរហាល ពូចូលក្នុងកងចល័តហ្នឹងក្នុងឆ្នាំ៧៧?

សល់ : បាទ!

ដាវ៉ា : អីចឹងពូនៅកូនដំរីហ្នឹង នៅបានយូអីចឹង?

សល់ : នៅបានប្រហែលជាមួយរដូវ មួយឆ្នាំហ្នឹង យើងវាចេះតែប្រែប្រួលទៅទៀតណា ដូចថាការហូបមិនឆ្អែតចេះតែគេច ចេះតែវិះ បើយើងនៅស្លាប់ យើងចេះតែគេច រកដំឡូង រកអី បើនៅនោះវាអត់មាន ។

ដាវ៉ា : បើនៅភ្នំកូនដំរីមួយឆ្នាំ ខ្មែរក្រហមចូលឆ្នាំ៧៥ អីចឹងវាអាចថា៧៦ទេ ដែលពូទៅរហាល!

សល់ : បាទ! វាមិនចប់៧៥ ចប់ឆ្នាំ៧៥ វាមិនកាន់កាប់ទៅ យើងមិនធ្វើស្រែរួមធ្វើស្រែហើយ វាដេញយើងពីស្រុកមកឲ្យនៅភ្នំកូនដំរី ។

ដានី ៖ អ៊ីចឹងបានន័យថា ពីបែក៧៥មកពូនៅភូមិកំណើតរបស់ពូនៅខាងស្ទឹងកំបត់ទេ ធ្វើស្រែបានមួយរដូវកាលហើយបានមកនៅកូនដំរី នៅកូនដំរីបានប្រហែលមួយឆ្នាំបានផ្លាស់មក ពូគេចមកខ្លួនឯង ជាគ្រួសារគេចមកខាងរហាលវិញ?

សល់ ៖ បាទ!

ដានី ៖ ពេលគេចមកខាងរហាលពូបានចូលកងចល័ត កាលហ្នឹងពូស្ម័គ្រចិត្តចូលកងចល័តឬក៏គេបង្ខំ?

សល់ ៖ កាលនោះកងចល័តគេរើសបញ្ចូលទៅកងចល័ត គេរើសណា យើងត្រូវតែចូល យើងត្រូវតែធ្វើ ។

ដានី ៖ កាលហ្នឹងពូអាយុប៉ុន្មានឆ្នាំដែរ?

សល់ ៖ វានៅតែកុមារ ៗដដែលហ្នឹង ។

ដារ៉ា ៖ ពូចាំថា ១០ប៉ុន្មានឆ្នាំ?

សល់ ៖ បើខ្ញុំសព្វថ្ងៃវាចូល៥១, ៥២ យើងកាលនោះនៅ ១២, ១៣ឆ្នាំយ៉ាងអស់ មិនជាធំទេ នៅតែគិតវាមិនចេញ វាតឹងទៅៗ ។

ដានី ៖ នៅក្នុងកងចល័តរបស់លោកពូហ្នឹង មានអាយុដំណាលៗលោកពូ ឬក៏អាយុច្រើនជាងឬតិចជាង?

សល់ ៖ មានគេធំជាងខ្ញុំ មានគេតូចជាងខ្ញុំដែរ ។

ដារ៉ា ៖ មានតូចជាងពូទៀត!

សល់ ៖ បាទ! មានតូចមានធំបណ្តុះៗគ្នាណា បាទ! ពួកកងល័ត បើកុមារគិតតាមកុមារទៅ យុវជន គិតតាមយុវជនទៅណា គេបែកជាកង ជាក្រុមទៅណា ។

ដានី ៖ គេបែងចែកដាច់ៗពីគ្នា?

សល់ ៖ បាទ! កុមារគេឲ្យនៅអង្គភាពកុមារទៅ យុវជន នៅតាមយុវជនទៅ ។

ដានី ៖ ចុះលោកពូនៅក្នុងកងមួយណា?

សល់ ៖ ខ្ញុំនៅជាមួយអាប៊ុ វ៉ាន ហ្នឹងគេឲ្យក្តាប់រួមជាមួយវាហ្នឹងឯងដែលថាផាប់នោះ ។

ដានី ៖ លោកពូធ្វើនិរសាគាត់?

សល់ ៖ បាទ! វាមិនមែននិរសាចំទេ ប៉ុន្តែនៅៗប្រើណេះ ប្រើណុះ ខ្វះទៅណា អែបៗទៅ ណា ។

ដារ៉ា ៖ ការធ្វើការងារនៅចល័តហ្នឹង គៀកជាមួយនិងឈ្មោះវ៉ានតែម្តង ឬក៏...?

សល់ ៖ បាទ! ដូចថាគៀក ។

ដារ៉ា ៖ អ៊ីចឹងបានន័យថា ពេលឈ្មោះវ៉ាន ស្មើពូទៅនេះ ទៅនោះអ៊ីចឹង?

សល់ ៖ បាទ! ប្រើដូចថា គេចង់ឲ្យយើងថាទៅប្រាប់នេះទៅប្រាប់នោះអី ឲ្យលើកដី ធ្វើចេះ ធ្វើចុះ ស្រេចតែគេទៅណា យើងទៅប្រាប់បន្តៗគ្នាទៅកុមារ ។

ដារ៉ា ៖ អ៊ីចឹងពេលដែលដាក់ផែនការ ការងារអី ឈ្មោះ វ៉ាន ប្រាប់តាមពូ?

សល់ ៖ បាទ! ប្រាប់ទៅ យើងអ្នកធ្វើតាមទៅណាបទបញ្ជា ។

ដារ៉ា ៖ មិនមែនគាត់ចុះទៅប្រាប់ផ្ទាល់ទេ?

សល់ ៖ ជួនកាលគាត់ ជួនកាលយើងផងទៅណា ។

ដារ៉ា ៖ ពូនៅជិតឈ្មោះ វ៉ាន អ៊ីចឹងការហូបចុកប្រសើរហើយ?

សល់ ៖ ខ្ញុំមិនសូវពឹងពាក់គេទេ ព្រោះខ្ញុំទៅបែបៗតែកុមារគ្នាឯង បានកណ្តុរក៏ហូបកណ្តុរទៅ បានដើមត្រពាំងព្រិច ក៏ដើមត្រពាំងព្រិចទៅ មិនជាគិតអីច្រើនទេ ។

ដារ៉ា ៖ វ៉ាន គាត់មានប្រពន្ធនៅពេលហ្នឹង?

សល់ ៖ ខ្ញុំក្តាប់អត់បានរឿងប្រពន្ធគាត់ ដល់យើងចូលថ្មីទៅ នៅអីចុះទៅ ដូចក្តាប់មិនបាន ។

ដានី ៖ គាត់អ្នកស្រុកណាដែរ?

សល់ ៖ ខ្ញុំអត់ស្គាល់ស្រុកស្រែគាត់កើត ស្រាប់តែឃើញគាត់នៅកន្លែងការដ្ឋានមុខព្រួញបណ្តោយទៅណា ដូចថាគេហៅថា បងវ៉ានៗ បងវ៉ានទៅ យើងមិនដឹង មិនស្គាល់គេ មិនហ៊ានសួរដេញគេនៅភូមិណាស្រុកណា ។

ដានី ៖ ពីមុនមកណា ពូធ្លាប់ស្គាល់គាត់ធ្លាប់ជួបគាត់ទេ?

សល់ ៖ អត់ទេ! អត់ធ្លាប់ជួប ធ្លាប់ទំនាក់ទំនងអីទេ ដល់ចូលដល់កងចល័តទៅនៅជាមួយគាត់ ។

ដារ៉ា ៖ កាលហ្នឹងពូហៅគាត់ថាម៉េច?

សល់ ៖ ហៅបងៗ ។

ដារ៉ា ៖ ហៅបង!

សល់ ៖ បាទ!

ដារ៉ា ៖ អ៊ីចឹងគាត់មានវ័យចាស់ប៉ុន្មានទៅអ៊ីចឹង?

សល់ ៖ កាលនោះគាត់ប្រហែលជាខ្ទង់ ៤០ ខ្ទង់អីហ្នឹងឯង ៤០ជាងហ្នឹង ។

ដារ៉ា ៖ ខ្ទង់៤០ជាង!

សល់ ៖ បាទ! តាមស្មានណា ។

ដារ៉ា ៖ ពូខ្ទង់ ១០ជាង ហ្នឹង ម៉េចអាចហៅគាត់បងបាន!

សល់ ៖ កាលនោះ ឲ្យតែគេធំហៅគេតែបងៗហ្នឹង ។

ដារ៉ា ៖ អាចថាពូហៅគាត់ថា ពូ ហៅថា អ៊ំ អ៊ីចឹងអត់ទេ?

សល់ :	បាទ! ហៅអីចឹងក៏បាន ហៅបងក៏បាន ។

ដារ៉ា :	តែពូទម្លាប់ហៅគាត់តែបងទេ?

សល់ :	បាទ!

ដានី :	ចុះលោកពូកាលហ្នឹង ដូចថាយើងនៅបែបគាត់ ធ្វើនិរសាគាត់ហ្នឹងមានគ្នាប៉ុន្មាននាក់ ក្រៅពីពូមានពីណាទៀត?

សល់ :	ទេ! មិនមាននិរសាប៉ុន្មានទេ យើងនៅកងជាមួយគាត់ណា គ្រាន់តែនៅកងជាមួយគាត់ ។

ដានី :	មានតែពូម្នាក់ទេកាលហ្នឹង?

សល់ :	មានតែខ្ញុំហ្នឹងនៅជិត ។

ដានី :	កាលហ្នឹង ខាងចល័តនៅដប់ភ្ញីហ្នឹង ឈ្មោះវ៉ាន គាត់ប្រធានចល័តឃុំ?

សល់ :	បាទ!

ដានី :	ឃុំដប់ភ្ញីហ្នឹងពីណាគេប្រធានឃុំ?

សល់ :	ប្រធានឃុំដប់ភ្ញី កាលនោះឈ្មោះតា រស់ ។

ដានី :	តារស់ គាត់អ្នកស្រុកណាដែរ?

សល់ :	គាត់អ្នកខាង គេហៅនិរតី១ មកពីត្បូង ពីតាកែវយើង ។

ដានី :	ពូស្គាល់គាត់ច្បាស់ដែរកាលហ្នឹង?

សល់ :	ស្គាល់! គ្រាន់តែស្គាល់ ប៉ុន្តែយើងមិនអាចថាទៅនិយាយជាមួយគេកើតកាលហ្នឹង... ព្រោះមនុស្សគេកាលហ្នឹងអំណាចគេធំៗណាស់ យើងមិនសូវមានសិទ្ធិអី និងហ៊ាននិយាយអីជាមួយគេទេ បើគេហៅទៅ យើងបាទទៅ បើឲ្យទៅនិយាយលេងអីចេះអីចុះមិនហ៊ានទេ

ដានី :	កាលហ្នឹងឃុំដប់ភ្ញីហ្នឹង សាលាឃុំនៅម្តុំណាទៅ?

សល់ :	ដូចជាភ្លេចហើយ មិនដឹងត្រង់ណាត្រង់ណីទេ ដូចក្តាប់មិនបាន សាលាឃុំកាលណុះ ។

ដានី :	ឈ្មោះ រស់ ហ្នឹង ពូមានស្គាល់ឈ្មោះគាត់ពេញទេ?

សល់ :	គេហៅតែតារស់ៗ ។

ដានី :	ប្រពន្ធគាត់ពូស្គាល់ទេ?

សល់ :	ខ្ញុំអត់ស្គាល់ទេ ។

ដារ៉ា :	ប៉ុនកាលហ្នឹងគាត់ចំណាស់ណាទៅ?

សល់ :	មនុស្សប្រហែលជាខ្ទង់៥០ជាង ។

ដារ៉ា :	ពូធ្លាប់ធ្វើការនៅគៀកនឹងតាវ៉ានដែរណា តើពូធ្លាប់បានតាវ៉ាន ប្រើឲ្យមកជួប តារស់ ក្នុងពេលនោះ?

សល់ : ក្នុងពេលនោះ តាវ៉ាន គាត់មិនដែលប្រើឲ្យមកជួបទេ ប៉ុន្តែគ្រាន់តែឃើញគាត់ថា នេះតា រស់ៗ បើនិយាយទៅវាច្រើន វាផ្លាស់ប្តូរច្រើនឃុំ អស់ពីមួយទៅមួយ នៅស្គាល់ឃុំមិនទាន់ វាផាប់បន្តគ្នានោះ និយាយរួមទៅផាប់បន្តគ្នា ។

ដានី : ចុះមុនតារស់ពីណាគេ?

សល់ : មុនតារស់នោះមេឃុំយើង ពាយ័ព្យយើង ។

ដានី : គាត់ឈ្មោះអី?

សល់ : ឈ្មោះ ស ដឹងស្អី ស ទេ ។

ដារ៉ា : មេឃុំឈ្មោះ ស!

សល់ : បាទ!

ដារ៉ា : ពាយ័ព្យន៍!

សល់ : បាទ! ពាយ័ព្យ ។

ដារ៉ា : ដល់ពេលបាត់ឈ្មោះ ស ហ្នឹងទៅវាចេញឈ្មោះតា រស់?

សល់ : បាទ!

ដារ៉ា : ភ្លាមឬក៏...

សល់ : ទេ! បាត់ឈ្មោះ តា ស រួចទៅដូចជាឈ្មោះ តារស់ ក្តាប់មិនបានមានមួយទៀតខ្ញុំមិនដឹងថាមុន ឬក្រោយបង ណុញ ប៉ុនមិនដឹងថាមុនក្រោយ ខ្ញុំក្តាប់មិនបានទេ ឈ្មោះ ណុញ មិនដឹងថា មុនតា ស ឬក្រោយតា ស ឈ្មោះ ណុញ ហ្នឹង គេឃុំដែរ នោះនៅខាងកំពត ។

ដារ៉ា : មកពីកំពត?

សល់ : បាទ! សុទ្ធតែអ្នកឆ្ងាយ ។

ដានី : ពូស្គាល់ពួកគាត់ច្បាស់ដែរ?

សល់ : យើងវាស្គាល់ ស្គាល់ហើយ ប៉ុន្តែថាយើងមិនអាចទៅទំនាក់ទំនងអីស្និទ្ធស្និតជាមួយគេ អត់មានទេ គ្រាន់តែស្គាល់ឈ្មោះ រស់, ស, ណុញ ឲ្យតែដឹងទៅណា អត់មានសិទ្ធិអីទៅថា..

ដារ៉ា : ដឹងថាអ្នកទាំងអស់នោះជាអ្នកគ្រប់គ្រង?

សល់ : បាទ! ដឹងប៉ុណ្ណោះឯង ។

ដារ៉ា : ពេលហ្នឹង ពេលដែលពូឃើញ ស ឬឃើញ ណុញ ឬឃើញ រស់ អីចឹងពេលនោះពូមានអារម្មណ៍ភិតភ័យអីដែរពូ?

សល់ : វាភ័យដែរ និយាយពីការភ័យចេះតែភ័យហើយ ប៉ុនគេមិនធ្វើអីយើងដែរ ប៉ុនយើងអត់ទុកចិត្តដែរ ដូចថាគេក៏អត់ទាន់ប្រមាតអីយើងមើលងាយយើងដែរ គេមិនធ្វើអីដែរ ប៉ុនថាខ្លាចវាចេះតែខ្លាចហើយ ។

ដារ៉ា : ខ្លាចហ្នឹងដោយសារ ឧទាហករណ៍ ឈ្មោះ ស ឈ្មោះ ណុញ ឬ ឈ្មោះ រស់ ហ្នឹងពូថាខ្លាច ខ្លាចក្នុងន័យថាអ្នកទាំងអស់ហ្នឹងមើលទៅដូចថាមនុស្សកាចសាហាវ ឬក៏ម៉ឺងម៉ាត់ ឬក៏...

សល់ : អីចេះ ដែលខ្លាចនោះ មនុស្សពីដើម សម័យនោះឲ្យតែហៅទៅវាច្រើនតែបាត់ខ្លួន គេហៅយើងល្អទេណា ប៉ុន្តែទៅយកទៅសម្លាប់ចោល ហៅទៅសម្លាប់ចោល ដូចបងឯងហៅខ្ញុំថាមក ដល់មកអីចឹងទៅ យើងមកតាមយកយើងទៅសម្លាប់បាត់ ម្ល៉ោះហើយក៏បាក់ក្នុតវាចូលអាដំណើរភ័យណា តែហៅ គឺភ័យ ក្នុងនាមហៅទៅធ្វើការក៏ភ័យដែរ គេមិនទាន់សម្លាប់យើង គ្រាន់តែហៅយើងក៏ភ័យមុនដែរ ព្រោះហៅទៅមានគេសម្លាប់ អីចេះណាបានជាខ្លាច មនុស្សកាលណុះ អត់មានដូចមនុស្សយើងសព្វថ្ងៃទេ ខុសត្រូវយើងនិយាយគ្នា ពិភាគ្សាគ្នា ដូចបងឯងជួបខ្ញុំ ខ្ញុំសួរបងឯងទៅវិញទៅមកបាន អត់អីទេពីដើមអត់បានទេ សិទ្ធិគេថាបើកទូលំទូលាយថាឲ្យមានសិទ្ធិ ប៉ុនដល់យើងនិយាយអត់បានអីចឹងណាមនុស្សពីដើម ។

ដារ៉ា : ពូអាចប្រៀបធៀបបានទេ ក្នុងពេលការគ្រប់គ្រងរបស់មេឃុំឈ្មោះ ស ដែលថាអ្នកពាយ័ព្យ ហើយស្ថានភាពរសលនៅពេលហ្នឹងយ៉ាងម៉េចដែរ?

សល់ : កាលពាយ័ព្យយើងនៅកាន់កាប់ក្តោបក្តាប់វាធូគ្រាន់ដែរ មិនសូវជាតឹងរឹងប៉ុន្មានទេ នៅចេះយោគយល់គ្នាណា នៅមានឆ្ងាញ់ មិនឆ្ងាញ់គ្រាន់ ដល់ពួកនិរតីមកនេះគេតឹងផ្តាច់ព្រាតបណ្តោយ ។

ដារ៉ា : បើពូប្រៀបការគ្រប់គ្រងរបស់ឈ្មោះ ស និង ឈ្មោះ ណុញ មួយណាគ្រាន់បើជាងប្រសើជាង?

សល់ : បងស គាត់គ្រាន់ជាង ដល់បងណុញ គេខាងកំពត គេមិនសូវជា ថាគាត់ស្លូតក៏ថាបានមិនស្លូត ក៏ថាបានដែរ ព្រោះគេអ្នកធ្វើការកាលហ្នឹងមិនជាស្លូតណាស់ណា ។

ដារ៉ា : តែរឿងជីវភាពកាលតាណុញមក!

សល់ : កាលតាណុញមកហ្នឹងតឹងហើយ តឹងជាងតា ស ការហូបចុកណា បើបង ស នៅគ្រាន់ ។

ដារ៉ា : ចុះធៀប ណុញ ជាមួយនឹងតា រស់មួយណាមានលក្ខណៈតឹងជាង?

សល់ : កាន់តែតឹងហើយ ចាប់ផ្តើមតឹងឡើងៗ ។

ដារ៉ា ៖ លក្ខណៈហូបចុក ឬក៏ការងារ ឬក៏សិទ្ធិអី គឺថាចាប់ផ្ដើមកាន់តែតឹងឡើងៗ?

សល់ ៖ បាទ! កាន់តែតឹងឡើងៗ ។

ដារ៉ា ៖ តឹងឡើងនោះរហូតមកដល់តា រស់ នោះគឺតឹងកម្រិតណាទៅ?

សល់ ៖ តឹងតែងណាស់ តឹងការហូបចុកនោះតឹងមែនទែន ហូបវាមិនឆ្អែតណា ចង់ថាអារបៀប តឹងតែងហ្នឹង ហូបចុកវាមិនឆ្អែតណា ។

ដារ៉ា ៖ ចុះការធ្វើការងារវិញ?

សល់ ៖ ធ្វើការងារក៏នៅតែសម្រុក ធ្វើការងារខ្លាំងតែអីចឹងឯង ។

ដារ៉ា ៖ ធ្វើខ្លាំងជាងជំនាន់ ស ឬជំនាន់ ណុញ?

សល់ ៖ ធ្វើខ្លាំង គេរើសម្រុក ខ្លាំងយកការងារណា មិនសូវជាប្រងើយកន្តើយទេ ដាក់អីកើតនោះ ធ្វើស្រែធ្វើកម្ការ ធ្វើអី លើកទំនប់ លើកដី ចេះតែធ្វើទៅណា យើងកាលណុះធ្វើដូចគោ ដូចក្របីមនុស្សម្នាក់ៗ គ្មានថ្ងៃសម្រាក់ ថ្ងៃទំនេរទេ ចេះតែធ្វើ ហើយគ្មានបានពេលមក អង្គុយនិយាយលេងបានទេកាលនោះ ច្បាប់គេវាតឹងតែងណាស់ ។

ដារ៉ា ៖ អីចឹងក្នុងម៉ាកំឡុងពេលពូនៅចល័តហ្នុង នៅក្រោមការគ្រប់គ្រងរបស់ឈ្មោះវ៉ាន ហ្នឹង រហូត ឬក៏មានការផ្លាស់ប្ដូរអី?

សល់ ៖ អត់ទេ! ដល់ក្រោយខ្ញុំផ្លាស់ប្ដូរទៀត ដល់ក្រោយមកណា ។

ដារ៉ា ៖ អីចឹងពូនៅចល័តជាមួយឈ្មោះវ៉ានហ្នុងបានរយៈពេលប៉ុន្មាន?

សល់ ៖ នៅជាមួយបងវ៉ាន ដូចមិនដល់មួយឆ្នាំទេ បានខ្ញុំផ្លាស់ប្ដូរចេញពីបងវ៉ានទៀតណា ប្រហែលជា៤,៥ខែដែរ ។

ដារ៉ា ៖ នៅក្នុងឆ្នាំ៧៧ ដដែល?

សល់ ៖ បាទ! ៧៧ ជិតចូល៧៨ ខ្ញុំផ្លាស់ ខ្ញុំដូរចេញ ។

ដារ៉ា ៖ ពូផ្លាស់ទៅខាងណា?

សល់ ៖ ផ្លាស់មកជួបម៉ែឪវិញ សុំគេ ។

ដារ៉ា ៖ សុំគេចេញមក?

សល់ ៖ សុំតា រស់ ប្រធានឃុំ ។

ដារ៉ា ៖ សុំតារស់មកនៅជាមួយម៉ែឪវិញ?

សល់ ៖ បាទ!

ដារ៉ា ៖ ឪពុកម្ដាយពូនៅក្នុងភូមិណា?

សល់ ៖ ភូមិរហាល ។

ដារ៉ា ៖ ម៉េចតារស់អាចឲ្យពូមកបាន បើពូជាកងចល័តកម្លាំងពេញ?

សល់ ៖ ខ្ញុំដូចថាសុំគាត់សាកមើលណា សុំថា អឺខ្ញុំសុំអឺទៅផ្ទះ គាត់សួរថាចុះមិត្តឯងទៅផ្ទះនោះមានមូលហេតុអី ថាខ្ញុំអត់មានមូលហេតុអីទេភ័យណាស់គ្រាន់តែសួររកមូលហេតុភ័យកាលនោះ ថាខ្ញុំនឹកម៉ែនឹកឪ ព្រោះខ្ញុំមកចល័តយូហើយ ចេះតែកុហក់គាត់ខ្វះៗទៅណាគាត់ក៏ធ្វើសំបុត្រឲ្យកាន់ តាមភូមិវិញ សុំចេញពីគាត់ ប៉ុន្តែមុននឹងសុំចេញពីគាត់នោះគាត់សួរថាមិត្តឯងមានមូលហេតុអីបានចេញពីអង្គភាពនេះ កាលនោះគេសួររកមូលហេតុភ័យហើយ ខ្លាចយើងដឹងរឿងអី មានរឿងហេតុអី ប៉ុនការពិតយើងអត់មានទេ ប៉ុនកាលហ្នុងគេសួររកតែមូលហេតុ អាពាក្យមូលហេតុនោះ គឺយើងភ័យហើយ ថាអត់មានទេអឺថាខ្ញុំនឹកម៉ែនឹកឪទៅនៅជិតម៉ែជិតឪ ។

ដារ៉ា ៖ ចុះពូអត់មានបានសុំប្រធានចល័តគេទេ?

សល់ ៖ ប្រធានចល័ត ខ្ញុំអត់ហ៊ានសុំផង សុំប្រធានឃុំ ។

ដារ៉ា ៖ ចេញពីចល័តហ្នុង តាវ៉ាន អត់ដឹងទេអីចឹង?

សល់ ៖ បាទ! អត់មានដឹងទេ សុំតារស់បណ្តោយ បើសុំតាវ៉ាន ក៏មិនឲ្យមកដែរ បើតាមខ្ញុំមើលណា សុំតារស់បណ្តោយ សុំទៅគាត់ឲ្យចេញមក ។

ដារ៉ា ៖ តារស់ និងតាវ៉ាន ពីរហ្នឹងអ្នកណាមានសិទ្ធិជាង?

សល់ ៖ បើសិទ្ធិគេនោះ កាលនោះវាច្បាប់ទម្លាប់គេ បើឧបមាថា បើឃុំថាប្រើយើងបាន បានអនុគ្រោះឲ្យយើងបាន បាន បើចល័តគេប្រើយើងបាន ក៏បាន ឲ្យតែអ្នកធំគេប្រើ គេអត់សូវប្រកាន់វណ្ណៈទេ ។

ដារ៉ា ៖ អីចឹងពេលពូចេញពីកងចល័តរបស់ពូតារស់ទេអ្នកសម្រេច មិនមែនតាវ៉ានទេ?

សល់ ៖ បាទ! តារស់អ្នកសម្រេចទៅ ខ្ញុំសុំក្រដាស់គាត់ គាត់ធ្វើក្រដាសឲ្យយើងទៅជួបម៉ែឪវិញឲ្យគេតាមចុងភៅរួមហ្នុងទទួលស្គាល់យើង ឲ្យបានបបរហូបផង តែយើងអត់ក្រដាសឲ្យគេគេអត់ឲ្យហូបទេ ។

ដារ៉ា ៖ នៅពេលដែលចូលភូមិហ្នុង?

សល់ ៖ បាទ! ចូលក្នុងភូមិជួបម៉ែឪក៏ដោយ គេអត់ថាឲ្យឪ អត់ថាឲ្យម៉ែ អត់ស្គាល់ អត់មានអនុគ្រោះអីចែកគ្នាហូបទេ ក្បាលអ្នកណាសក់អ្នកនោះកាលហ្នុងណា ទោះបីមិត្តក៏ដោយលោកពុកម្តាយក៏ដោយ ត្រូវតែយើងមានក្រដាសឲ្យគេទទួលស្គាល់ថាយើងចេញពីឃុំនេះឃុំនោះមក ទើបយើងបានរបបហូបនឹងគេ ។

ដានី ៖ ឈ្មោះវ៉ាន ហ្នុង គាត់អ្នកនិរតីដែរ?

សល់ ៖ អត់ទេ! អ្នកពាយ័ព្យយើង ។

ដានី ៖ គាត់កាន់នៅចល័តពីឆ្នាំណាដល់ឆ្នាំណាទៅ?

សល់ ៖ ខ្ញុំភ្លាប់អត់បានទេ ដល់ខ្ញុំចូលក្រោយទៅបានតែប៉ុន្មានខែទៅ ខ្ញុំគេចពីគាត់ចេញមកផ្លាស់កន្លែងទៅទៀត ។

ដានី ៖ អីចឹងពេលដែលលោកពូមកនៅជាមួយម៉ែឪវិញយ៉ាងម៉េចទៅ?

សល់ ៖ ខ្ញុំមកជួបម៉ែឪ និរតីគេឃើញខ្ញុំគេហៅខ្ញុំ ពួកនិរតីហ្នុងណា ។

ដារ៉ា ៖ និរតីក្នុងភូមិហ្នឹងឬ?

សល់ ៖ និរតីដែលគេប្រធានឃុំប្រធានអីហ្នុងណា ។

ដារ៉ា ៖ អីចឹងពេលពូមកភូមិនេះ តាមលំដាប់លំដោយខ្ញុំសួរមួយៗសិនណាពូ ពេលពូមកដល់ភូមិរហាលវិញ អីចឹងពួកនិរតីកាន់កាប់ហើយ?

សល់ ៖ បាទ! ពួកនិរតីកាន់កាប់ហើយ ។

ដារ៉ា ៖ ប្រធានភូមិដែលកន្លែងពូដែលថាមកពីចល័តចូលដល់ភូមិវិញប្រធានភូមិហ្នឹងឈ្មោះអីដែរ?

សល់ ៖ ខ្ញុំអត់ទាន់ស្គាល់ផង ពីព្រោះនិរតីទៅហៅខ្ញុំ ខ្ញុំឲ្យក្រដាសមើល សួរថាមកពីណា ខ្ញុំថាខ្ញុំមកពីចល័តទាំងតាំ ដល់គេឃើញក្រដាសខ្ញុំ គេហៅខ្ញុំឲ្យទៅនៅជាមួយ ។

ដារ៉ា ៖ ទៅនៅជាមួយម៉ង?

សល់ ៖ បាទ! ទៅនៅជាមួយគណៈឃុំ ។

ដារ៉ា ៖ គណៈឃុំអីកាលហ្នុង?

សល់ ៖ ឃុំរហាល ។

ដារ៉ា ៖ គណៈឃុំរហាលកាលហ្នុង ជាពួកនិរតី?

សល់ ៖ ខាងនិរតី គាត់អ្នកកំពង់ស្ពឺ មិនដឹងថាភូមិអីស្រុកអីខ្ញុំមិនដឹងទេ ប៉ុន្តែដឹងថាគាត់អ្នកកំពង់ស្ពឺ ។

ដារ៉ា ៖ ឈ្មោះអីពូ?

សល់ ៖ ឈ្មោះ ថា នារី ថា ។

ដារ៉ា ៖ អូ! នារីទេ?

សល់ ៖ បាទ!

ដារ៉ា ៖ ឃើញពូជាបុរសម៉េចបាន?

សល់ ៖ ទេ! មិនដឹងយ៉ាងណា ឃើញ! យើងនៅក្មេងនោះ ឃើញក៏ហៅយើងមក នៅជុំគេទៅណា ។

ដារ៉ា ៖ អ៊ីចឹងពេលដែលមកភូមិរហាលហ្នឹង ពូបានស្គាល់មេឃុំរហាលហ្នឹងឈ្មោះ ថា ហៅថា នារី ថា?

សល់ ៖ បាទ!

ដារ៉ា ៖ ឈ្មោះ នារី ថា?

សល់ ៖ បាទ! នារី ថា, បង ថា ។

ដារ៉ា ៖ ពូហៅគាត់ថាម៉េច?

សល់ ៖ ហៅតែ បងៗ ។

ដារ៉ា ៖ ហើបងថា មកពីកំពង់ស្ពឺ?

សល់ ៖ បាទ! ខាងនិរតីដែរ ប៉ុនគាត់អ្នកកំពង់ស្ពឺណា កាលនោះវាចម្រុះគ្នាណា វាមានអ្នកតាកែវ វាមានអ្នកកំពង់ស្ពឺ មានអីមកក្តាប់ដល់ណេះណា ។

ដារ៉ា ៖ ម៉េចបានពូដឹងថាឈ្មោះថាហ្នុងមកពីកំពង់ស្ពឺ?

សល់ ៖ ដល់នៅជាមួយគាត់ ចេះតែសួរគាត់លេងទៅណា គាត់ប្រាប់ទៅណា ប៉ុនគាត់កុហក់ មិនកុហក់ខ្ញុំមិនដឹងទេ សួរគាត់ថាបងនៅស្រុកណា ភូមិណា គាត់ប្រាប់ទៅណា ។

ដានី ៖ នៅភូមិណាស្រុកណា?

សល់ ៖ មិនបានដាសួរទេ គ្រាន់តែគាត់ថានៅកំពង់ស្ពឺ យើងវានៅក្មេង វាល្ងង់ដែរ មិនបានទៅសួរអស់ ។

ដានី ៖ កាលហ្នុងឈ្មោះថាហ្នុង ប្រហែលអាយុប៉ុន្មាន?

សល់ ៖ ប្រហែលជាខ្ទង់ជិត៣០ហើយទេដឹង?

ដារ៉ា ៖ ជិត៣០ទេ?

សល់ ៖ បាទ! ប្រហែលខ្ទង់៣០ ខ្ទង់អីហ្នុង ។

ដារ៉ា ៖ ក្មេងដែរ?

សល់ ៖ បាទ! នៅក្មេង ។

ដារ៉ា ៖ ថា ហ្នុងមានគ្រួសារនៅ?

សល់ ៖ គាត់នៅលីវ ។

ដារ៉ា ៖ រូបរាង ថា ហ្នុងយ៉ាងម៉េចដែរ ពូអាចប្រាប់ភិនភាគ?

សល់ ៖ បងថា ហ្នុង មនុស្សគាត់ជ្រះ សម្តីម៉ាត់ៗ ។

ដារ៉ា ៖ សជ្រះ!

សល់ ៖ បាទ!ស ពួកខាងមកពីតាកែវ ខាងកំពង់ស្ពឺ ច្រើនតែ សៗ បើខាងកំពង់ឆ្នាំង មកសុទ្ធតែ ខ្មៅៗ មិនសូវមានសទេ បើពួកខាងនិរតីមកសក្លឹងៗ ។

ដារ៉ា ៖ នារី ថា ហ្នឹងជាប្រធានឃុំរហាល គ្រប់គ្រងម៉ឃុំហ្នឹង?

សល់ ៖ បាទ! គ្រប់គ្រងម៉ឃុំរហាល កាលហ្នុងខ្ញុំទៅនៅជាមួយគាត់ ។

ដានី ៖ កាលហ្នុងគាត់មានប្ដីទេ?

សល់ ៖ អត់ទេ នៅទេ ។

ដានីៈ អាយុ៣០ អត់ទាន់មានទេ?

សល់ៈ អត់ទេ! អត់ទាន់មានទេ ។

ដារ៉ា ៖ ពូនៅជាមួយឈ្មោះ ថា ជាឋានៈជាស្ពឺ ជានិរសា ជា...

សល់ ៖ បាទ! នៅជាមួយគេដូចនិរសាគេហ្នុងឯង ។

ដារ៉ា ៖ ពេលស្នាក់នៅ នៅជាមួយឈ្មោះថាហ្នុង?

សល់ ៖ បាទ! គេនៅផ្ទះ យើងនៅដេកការពារគេណា ។

ដានី ៖ មានប៉ុន្មាននាក់ទៅកាលហ្នុង?

សល់ ៖ ប្រហែលជា ពួកខ្ញុំបួនដប់នាក់ដែរ ប្រហែលបួបដប់នាក់ក្មេងៗនោះណា ។

ដារ៉ា ៖ ចុះក្រៅពី ថា មានអ្នកណាអីផ្សេងទៀតទេក្នុងចង្កោមដែលគេធ្វើការងារហ្នុង?

សល់ ៖ ក្រៅពី ថា មានដូចថាកូនចៅគាត់ជាប្រធានភូមិ ប្រធានសហករណ៍អី គេចេះតែបង្កើត ទៅណា ។

ដារ៉ា ៖ អាចពូស្គាល់ជាឈ្មោះទេ?

សល់ ៖ មិនសូវទេ វាភ្លេចភ្លាំងយូឆ្នាំហើយ ២០, ៣០ឆ្នាំទៅហើយ វាវង្វេងអស់ទៅហើយ អត់ស្គាល់គេអស់ ។

ដារ៉ា ៖ នារី ថា ហ្នឹងគាត់គ្រប់គ្រងនៅហ្នឹងរហូតដាប់មក ឬក៏យ៉ាងម៉េច?

សល់ ៖ បាទ! គាត់គ្រប់គ្រងបានប្រហែលជា ខ្ញុំភ្លេចហើយមិនដឹងថាប៉ុន្មានឆ្នាំ ម៉ឆ្នាំ, ២ឆ្នាំ កាលហ្នុងដូរគ្នាវាលឿនៗ គេដូរឲ្យគាត់ទៅភៀស នៅភៀសយើង គឺងកោងនេះណា នៅភូមិភៀសយើង ទៅគឺងកោងយើងនេះ ។ គាត់ដូរទៅនោះទៅ បានតា ណុប នេះអ្នកកំពតមកនៅ ធ្វើមេឃុំទៀត ។ តា ណុប នៅកំពត ដល់ដូរនារីថា នេះគេផ្លាស់ទៅនៅភៀស ក៏តាណុបនេះមក ។

ដារ៉ា ៖ តាណុប នៅកំពត!

សល់ ៖ បាទ! តាណុបនៅកំពត ។

ដានី :	នារី ថា គាត់ដូរទៅនៅភៀសហ្នុង ទៅកាន់គណៈឃុំនៅភៀសវិញ?

សល់ :	ខ្ញុំក្ដាប់មិនបានទេ បើតាមមើលគេអ្នកធំអីចឹង គេច្រើនតែទៅកាន់តែអីចឹងឯង ខ្ញុំអត់ដឹងទេណា ព្រោះគាត់ដូរ បើតាមខ្ញុំចាំណាំមើលគេអ្នកធំគេផ្លាស់ប្ដូរគេនៅតែបុណ្យសក្ដិគេអីចឹងឯង ។

ដារ៉ា :	ចុះកាលរស់នៅជាមួយថា នារី ថា ប្រើពូឲ្យធ្វើអីខ្លះ?

សល់ :	ប្រើដូចជាឲ្យមើលចម្ការមើលអីទៅណា មើលដំណាំរបស់រួម របស់រដ្ឋហ្នឹងណា ឲ្យយើងយាមយើងអីកុំនណាលួចស្រូវ ដកដំឡូង ដកអីចឹងទៅណា ឲ្យយើងមើល ការពារ ។

ដារ៉ា :	ការពារអីចឹង ពូមានកាន់កាំភ្លើងទេ?

សល់ :	អត់មានទេ មិនដែលមានទេ គ្រាន់ដូចថាយើងគេឲ្យមើលការពារដំឡូង ខ្លាចគេមកលួចបូចស្រូវអីណា ឲ្យយើងប្រាប់គេអី ។

ដារ៉ា :	អីចឹងនៅឃុំពូអត់ដែលឃើញមានដូចថា នារី ថា ឬអ្នកផ្សេងទៀតធ្វើជាសន្តិសុខអីមានកាំភ្លើងមានអី?

សល់ :	នារីឃុំកាលហ្នុងដូចអត់មានទេ មិនមានកាំភ្លើងទេ ដៃទទេដែរ គ្រាន់មកកាន់កាប់ មិនមានកាំភ្លើងមានអីទេ មកដូចថាក្ដាប់ៗគេទៅណា អត់មានអាវុធអីទេ ។

ដារ៉ា :	អត់មានអាវុធអីការពារខ្លួនទេ?

សល់ :	អត់មានទេ!

ដារ៉ា :	នៅរហាលនេះ ដូចថា នារីថា ជាប្រធានឃុំ គាត់ដឹកនាំធ្វើការងារអីខ្លះទៅ?

សល់ :	ធ្វើស្រែ ធ្វើចម្ការយើង ធ្វើស្រែប្រាំង ធ្វើស្រែវស្សា ខាងផ្នែកកុមារទន្រៀងខែតអីទៅចព្រាំធ្វើដីធ្វើអី ដាក់ស្រែ ដាក់ស្រូវ ។

ដារ៉ា :	ការហូបចុកពេលហ្នុងយ៉ាងម៉េចដែរ?

សល់ :	វាមិនមែនជាស្រួលទេ ចេះតែតឹង ចេះតែអត់ដែរ មនុស្សសម័យនោះមិនគួរថារស់ដូចសព្វថ្ងៃនេះ បើយើងប្រាប់កូនក្មេង សូម្បីតែកូនខ្ញុំក៏ប្រាប់វាមិនជឿ វាថាបើហូបបបរអីចឹងដែលរស់ដល់សព្វថ្ងៃ វាអត់ដែលជួបប្រទះ មុននឹងឆ្លងផុតនោះមនុស្សហ្នឹងដូចថា មានបុណ្យច្រើនហើយបានឆ្លងមកដល់នេះ ដូចកើតម្ដងទៀត យើងពិចារណាទៅដូចកើតម្ដងទៀត ។

ដានី :	ពេលដែលនារីថាគាត់ផ្លាស់ភៀស ពូយ៉ាងម៉េចផ្លាស់ទៅជាមួយគាត់ដែរ ឬក៏?

សល់ :	អត់ទេ! ខ្ញុំគាត់អត់យកទៅទេ ទុកឲ្យតា ណុប នៅបម្រើតា ណុប ម្ដង ។

ដានី :	និរសា របស់តាណុប?

សល់ : បាទ! នៅនិរសារបស់តាណុបទៀត គ្រាន់តែនៅសម្រាប់គេប្រើប្រាស់ ។

ដារ៉ា : កាលពូនៅជាមួយ ថា នេះ ពូធ្លាប់បាន ថា ប្រើឲ្យទៅណាមកណាទេ?

សល់ : បាទប្រើ! ជួបកាលគេឲ្យយើង ប្រើទៅសហករណ៍នេះ សហករណ៍នោះ ដូចជារត់និរសារត់សំបុត្រ ជាសំបុត្រឯកសារគេណា សំបុត្រគេបិតទៅ យើងមិនអាចបើកបានទេណា គេសរសេរឲ្យយើងដាក់ហោប៉ៅក៏ទៅឲ្យគេ គេមានការគេណា ពីដើមមិញមានទូរស័ព្ទឯណា មានតែរត់សំបុត្រ រត់អីទៅណា ។

ដារ៉ា : អីចឹងខាងសហករណ៍ ភូមិអីគេដឹងថាពូជានិរសារតាមរយៈម៉េចទៅ?

សល់ : ដឹង! គេដឹងដែរ ដែរយើងនៅជុំគ្នាគេ គេដឹង ព្រោះយើងធ្លាប់តែឡើងចុះ ដើរជាមួយគេទៅ គេដឹងណា យើងគ្រាន់តែអែបៗជាមួយគេទៅ ។

ដារ៉ា : អីចឹងពូធ្លាប់ដើរទៅណាមកណាជាមួយ នារី ថា ទៅកន្លែងណាខ្លះ?

សល់ : ដើរដូចថាគេចង់ថាទៅមើលស្រែទៅនាំយើងទៅ ស្រែដូចអន្ទះបាញ់ តាមទំនប់ ក្រោមៗ គេនាំយើងទៅ ទៅមើល ធ្វើស្រែតាមចល័តតាមអី ។

ដារ៉ា : ដែលនាំទៅប្រជុំកន្លែងណា ឬទៅធ្វើអីកន្លែងណា?

សល់ : បើទៅប្រជុំទៅអីគេមិនដែលហៅយើងទៅទេ បើថាទៅមើលស្រែ មើលសម្ការហ្នឹងគេហៅហើយ ព្រោះគេវាលាក់ការណ៍គេដែរដឹង គេមិនឲ្យយើងដឹងទេ យើងក្មេងក្មាង ។

ដារ៉ា : ក្នុងការរស់នៅជាមួយ ថា ក៏ដោយ នៅជាមួយ តារស់, ស ហ្នឹងពូមានធ្លាប់ឃើញជាអ្នកធំ អ្នកតូចគេចុះ មកពិនិត្យ មើល មកជួបអីទេ?

សល់ : មិនដែលឃើញមានច្បាប់មានទម្លាប់ឯណា មកពីនិត្យអី មិនសូវដឹងផង អារឿងអីចុង មិនឃើញមានអីផង ។

ដារ៉ា : អីចឹងពេលដែល នារីថា ផ្លាស់ទៅភៀសហ្នឹងនៅក្នុងឆ្នាំណា?

សល់ : ផ្លាស់ទៅនៅភៀសតាមមើលឆ្នាំ៧៨ហើយ បើមិន៧៨ទេ វាដូចថាពាក់កណ្ដាលឆ្នាំ៧៧ហើយណាទៅ ឈានចូលឆ្នាំ៧៨ អានេះជាការស្មានទេ ។

ដារ៉ា : បន្ទាប់មក ពូថាឈ្មោះ តាណុប មកជំនួស នារីថា?

សល់ : បាទ!

ដារ៉ា : អីចឹងពេលនៅជាមួយតា ណុប ហ្នឹង តាណុប ប្រើអីយ៉ាងម៉េចដែរ?

សល់ : គាត់ប្រើដូចតែគ្នាហ្នឹងឯង ជួនកាលគាត់ឲ្យមើលគោគាត់ខ្លះទៅ ជួនកាលឲ្យយាមគាត់ដេកខ្លះទៅ យើងក្មេងៗ ។

ដារ៉ា : ពេលពូនៅជាមួយឈ្មោះ ថា ពូមានរម្មណ៍ជាការភ័យខ្លាចអីទេ ពេលថាប្រើម្ដងៗ ?

សល់ ៖ ខ្លាចដូចតែគ្នា អារឿងខ្លាចេះតែខ្លាចហើយ អត់ទុកចិត្ត ត្រូវគ្នាយ៉ាងណា ឧទាហរណ៍ថា ត្រូវគ្នាយ៉ាងណាក៏នៅតែខ្លាច យើងអត់ទុកចិត្តទេ ព្រោះមនុស្សសម័យនោះ ត្រូវគ្នាយ៉ាងណាក៏សម្លាប់ណាស់ដែរ ។

ដារ៉ា ៖ ចុះឈ្មោះថាដែរសម្លុត ដែរអីទេ?

សល់ ៖ គេអត់ដែរហ៊ាន សម្លុតខ្ញុំទេ និយាយលេងនិយាយ បន្ទប់ខ្ញុំអីចេះអីចុះអីនិយាយ ប៉ុនថា ឲ្យសម្លុតឲ្យមើលងាយប្រមាត់អីមិនសូវហ៊ានទេ ។

ដារ៉ា ៖ ចុះនៅជាមួយ តាណុប នោះ?

សល់ ៖ នៅជាមួយតាណុបក៏មិនអី យើងក្មេងៗអីចេះមិនអីទេ សម័យកាលណុះគេចូលចិត្តរាងក្មេងទៅវិញ ព្រោះអាសត្វក្មេងវាត្រង់ កូនក្មេងវាត្រង់ គេប្រើអីគឺអស់ពីពោះពីពង់ វាអត់ចេះមានពោះវៀនបត់ចំគៀសលាក់លៀមអីទេណា បានជាសម័យបដិវត្តន៍ វាស្រឡាញ់ក្មេងជាងព្រោះអាសត្វក្មេងវាត្រង់ ថា១០ គឺ ១០ ថា២០ គឺ២០ហើយ បើថាចំណាស់យើងមានប្រពន្ធ មានកូន វាអត់ទុកចិត្តទៅវិញទេ វាថាយើងអត់ត្រង់យើងនៅលើវវាត្រង់ អានេះជាការស្មានទេណា ព្រោះវាចូលចិត្ត ស្រឡាញ់ក្មេង ។

ដារ៉ា ៖ អីចឹងបន្ទាប់ពី ណុប មកទៀតទៅ ពូ...

សល់ ៖ ដល់ខ្ញុំនៅជាមួយតាណុបទៀតទៅបានជាប៉ុន្មានខែទេ វាភ្លេចទៅ វាចូលឆ្នាំ៧៨ហើយណា ដល់ចូលឆ្នាំ៧៨ ត្រូវ តាណុប នេះបញ្ជូនខ្ញុំទៅត្រយោង ។

ដានី ៖ បាទ! យ៉ាងម៉េចទៀតទៅលោកពូ?

សល់ ៖ បាទ! ទៅនៅត្រយោង កន្លែងសន្តិសុខ ។

ដានី ៖ បាទ! លោកពូយ៉ាងម៉េចបានតាណុបគាត់បញ្ជូនពូពីកន្លែងឃុំរហាលទៅសន្តិសុខត្រយោង?

សល់ ៖ ព្រោះប្រធានសន្តិសុខខ្វះកម្លាំងទៅជួយការពារ ព្រោះគេអ្នកធំ គេទាក់តងតាមគេអ្នកធំណា ។

ដានី ៖ បញ្ជូនពូទៅកន្លែងសន្តិសុខត្រយោងហ្នឹងដោយសារខ្វះកម្លាំងការពារ?

សល់ ៖ បាទ!

ដានី ៖ ការពារយ៉ាងម៉េច លោកពូអាចរៀបរាប់...

សល់ ៖ ការពារអ្នកទោសអ្នកអីណា ។

ដារ៉ា ៖ អីចឹងតាណុបបញ្ជូនពូទៅសន្តិសុខត្រយោងជាភ្នំត្រយោង?

សល់ ៖ បាទ!ភ្នំត្រយោងហ្នុងឯង ។

ដារ៉ា ៖ ភ្នំត្រយោង កន្លែងសន្តិសុខហ្នុងពូ?

សល់ ៖ បាទ!

ដារ៉ា ៖ ពេលបញ្ជូនទៅ គាត់មានបានធ្វើលិខិតស្នាមអីកាន់ទៅទេពូកាលហ្នឹង?

សល់ ៖ បញ្ជូនទៅ គេយកយើងទៅអត់ពិបាកនេះទេកាលហ្នឹង យកទៅប្រាប់មេគេប្រគល់ ថាយកទៅឲ្យណា ឲ្យទៅនៅជុំគេ ។

ដារ៉ា ៖ ពេលទៅដល់ភ្នំត្រយោងហ្នឹងគេប្រគល់ឲ្យទៅអ្នកណាមកទទួល?

សល់ ៖ អត់ទេ! ឃុំគេប្រាប់ស្រេច គេនាំយកទៅឲ្យ ឲ្យទៅនៅជុំគេ ។

ដារ៉ា ៖ កាលហ្នឹងភ្នំត្រយោងនៅក្នុងឃុំអីវិញពូ?

សល់ ៖ ដូចជាឃុំភ្នំលៀប ឃុំភ្នំលៀបហើយតាមមើល ព្រោះកន្លែងយាយថែមនៅនោះ ។

ដារ៉ា ៖ អ៊ីចឹងកន្លែងឃុំភ្នំលៀបហ្នឹង អ្នកណាប្រធានឃុំហើយពេលហ្នឹង?

សល់ ៖ នៅភ្នំលៀបខ្ញុំអត់ស្គាល់ឃុំគេទេ ព្រោះគេឲ្យទៅនៅអាកន្លែងសន្តិសុខ ។

ដារ៉ា ៖ ឲ្យទៅនៅកន្លែងសន្តិសុខម៉ង?

សល់ ៖ បាទ! រុញទៅកន្លែងសន្តិសុខបណ្ដោយ ។

ដារ៉ា ៖ អ៊ីចឹងអត់នៅតាមភូមិតាមឃុំអីទៀតទេ?

សល់ ៖ អត់ទេ!

ដារ៉ា ៖ ចូលទៅដល់កន្លែងហ្នឹងគឺជាអ្នកសន្តិសុខ?

សល់ ៖ បាទ!

ដារ៉ា ៖ អ្នកសន្តិសុខការពារនៅកន្លែងភ្នំត្រយោងហ្នឹងម៉ង?

សល់ ៖ បាទ!

ដារ៉ា ៖ អ៊ីចឹងអត់មាននៅជាឃុំ ជាភូមិអីទេម្ដងនេះ?

សល់ ៖ អត់ ។

ដារ៉ា ៖ អត់មានទៅធ្វើស្រែ ធ្វើចម្ការអីទេ?

សល់ ៖ អត់មានទេ! នៅគ្រាន់តែមើលយាមកាមគេហ្នឹង ។

ដារ៉ា ៖ ចូលទៅដល់កន្លែងមន្ទីរសន្តិសុខភ្នំត្រយោងហ្នឹង គឺធ្វើការជាអ្នកការពារ ឬក៏យ៉ាងម៉េច?

សល់ ៖ ជាអ្នកការពារមើលម៉ែៗដូចថាធ្វើចម្ការធ្វើស្រែតាមនោះណា ។

ដារ៉ា ៖ ពេលនោះពូជាអ្នកការពារនៅភ្នំត្រយោង ពូមានអាវុធមានអីទេពូ?

សល់ ៖ កាលទៅត្រយោងមានអាវុធគេឲ្យណា គេឲ្យកាបីនមួយដើម ។

ដារ៉ា ៖ គេឲ្យការ៉ូបីន?

សល់ ៖ ការ៉ូបីនកញ្ចាស់ ។

ដារ៉ា : មានគ្រាប់ប៉ុន្មាន?

សល់ : គ្រាប់អស់ម៉ាបង់ កន្ទះបង់ហ្នឹង មិនមានទេ ។

ដារ៉ា : ហឹទៅអ៊ីចឹង ជាកងសន្តិសុខអ៊ីចឹង ពូស្លៀកសំលៀកបំពាក់យ៉ាងម៉េចទៅ?

សល់ : ឯកសណ្ឋានជាខ្មៅ ។

ដារ៉ា : ខ្មៅទាំងលើ ទាំងក្រោមម៉ង?

សល់ : បាទ! គេបើកឲ្យ ។

ដារ៉ា : ស្បែកជើង?

សល់ : ស្បែកជើងកង់ឡានយើងធម្មតា ។

ដារ៉ា : ចុះក្រមា?

សល់ : ក្រមាយើងធម្មតា ។

ដារ៉ា : ក្រមាមានបង់ករជាប់រហូតទេកាលហ្នឹងពូ?

សល់ : ក្រមាយើង មនុស្សកាលហ្នឹងមានគ្រប់តែគ្នាកាលហ្នឹង វាប្រើ វាត្រូវការតែក្រមាហ្នឹងហើយផ្លាស់មុជទឹក មុជអី ប៉ុន្តែខោអាវអត់មានច្រើនទេ ។

ដារ៉ា : មានមួក មានអីទេ?

សល់ : មានមួកគេបើកឲ្យស្រេច ។

ដារ៉ា : ម៉ាឆ្នាំ បើកបានប៉ុន្មាន?

សល់ : ម៉ាឆ្នាំមួយកំភ្លេរ ២កំភ្លេរអស់ហើយ ។

ដារ៉ា : អ៊ីចឹងមួយថ្ងៃៗស្លៀកពាក់តែខោអាវខ្មៅ?

សល់ : ខ្មៅរហូត ។

ដារ៉ា : ស្ពាយការ៉ូបីនហ្នឹងទៅ?

សល់ : ស្ពាយការ៉ូបីន ។

ដានី : មួកក៏ខ្មៅដែរ?

សល់ : ទេ! អាមួកយើងពណ៌អាចម៍សេះ ។

ដានី : មួកកន្តឹប?

សល់ : មួកកន្តឹបរបស់ចិន ។

ដារ៉ា : អ៊ីចឹងជាកងសន្តិសុខ ឬក៏អ្នកធ្វើការនៅមន្ទីរភ្នំត្រយោងហ្នឹង បើធៀបជាមួយប្រជាជនដែលគេបញ្ជូនទៅហ្នឹង មើលទៅឃើញខុសគ្នាទេពូ?

សល់ : បាទ! ខុស ។

ដារ៉ា ៖ បើថាគ្រាន់តែក្រឡេកទៅដឹងថា អ្នកហ្នឹងអ្នកទោស អ្នកហ្នឹងអ្នកធ្វើការ!

សល់ ៖ បាទ! ខោអាវរាចម្រុះណា ខោអាវយើងដូចថាមេគេស្លៀកពាក់ខោអាវលំដាប់ផ្សេងទៅណា បើថាបើអ្នកប្រជាជនខោអាវ ឧបមាថាគេបើកខោអាវសឲ្យយើង យើងជ្រលក់យកមកដល់ដាំទឹកបានជ្រលក់ យកជ័រឈើ ជ័រគ្រស់អីណា ជ្រលក់ហើយបានយកទៅដាំភក់ឲ្យខ្មៅ សុទ្ធតែខ្មៅទាំងអស់ ខោអាវមិនមានពណ៌អីទេ មានតែខ្មៅទាំងអស់ ។

ដារ៉ា ៖ គ្រាន់ថាខ្មៅគេហ្នឹងមិនដូចសន្តិសុខអីទេ?

សល់ ៖ បាទ! ខ្មៅខុសគេ ។

ដារ៉ា ៖ ពេលពូទៅដល់កន្លែងសន្តិសុខហ្នឹងអ្នកណាអ្នកទទួល?

សល់ ៖ តាសឿន ឈ្មោះ សឿន ។

ដារ៉ា ៖ អីចឹងពេលតាណុប បញ្ជូនទៅ គឺទៅឲ្យឈ្មោះតាសឿន?

សល់ ៖ បាទ! ទៅឲ្យតាសឿន ។

ដារ៉ា ៖ សឿនហ្នឹង គាត់ឈ្មោះអីពេញដែរពូ?

សល់ ៖ តាសឿនហ្នឹងខ្ញុំអត់ស្គាល់ត្រកូលគាត់ទេ ប៉ុនគាត់អ្នកតាកែវ អ្នកខាងណុះឯង សុទ្ធតែមកពីខាងតាកែវ ខាងអីណុះឯង ។

ដារ៉ា ៖ ពូរៀបរាប់កិនភាគតាសឿនបន្តិចមើលយ៉ាងម៉េចដែរ?

សល់ ៖ តាសឿន មនុស្សស្បែកដូចបងខាងណោះអីចឹងឯង ជ្រះ ។

ដារ៉ា ៖ សម្បុរជ្រះ!

សល់ ៖ អីចេះឯង មាំអីចេះ ។

ដារ៉ា ៖ កំពស់កំពរគាត់ម៉េចដែរពូ?

សល់ ៖ កំពស់ម៉ាសមរម្យគាត់ មាំស្អាតកាលណុះ គាត់នៅក្មេង ។

ដារ៉ា ៖ សជ្រះ ពូន៎?

សល់ ៖ បាទ! សជ្រះ ។

ដារ៉ា ៖ កំពស់ប្រហែលជាប៉ុន្មានទៅពូ អាចថា១,៦០ម៉ែត្រ ឬ ១,៧០ម៉ែត្រអីចឹង?

សល់ ៖ ប្រហែលជា១,៧០ ម៉ែត្រហើយទេដឹង ។

ដារ៉ា ៖ ខ្ពស់ឬ?

សល់ ៖ បាទគាត់កំពស់ដែរ ។

ដារ៉ា ៖ សក់គាត់អីយ៉ាងម៉េច?

សល់ ៖ សក់ស្កូតធម្មតា ។

ដារ៉ា ៖ ពេលហ្នឹងគាត់សក់ស្កូវឬខ្មៅ?

សល់ ៖ កាលណុះសក់គាត់មិនទាន់ស្កូវទេ គាត់សក់ខ្មៅ នៅតែសន្ធាដែរហ្នឹង ។

ដារ៉ា ៖ មាឌគាត់យ៉ាំងម៉េចដែរ?

សល់ ៖ មាឌគាត់មាំដឹបដូចគាត់នេះឯង មិនមាំខ្លាំងណាស់ណាទេ ប៉ុនមនុស្សដូចថាពេញលំដាប់ ស្អាត គាត់និយាយញាប់ៗ ។

ដារ៉ា ៖ និយាយញាប់?

សល់ ៖ និយាយញាប់ៗ ។

ដារ៉ា ៖ កាលហ្នុងគាត់មានគ្រួសារហើយនៅ?

សល់ ៖ មានហើយ!

ដារ៉ា ៖ ស្គាល់ឈ្មោះគ្រួសារគាត់ទេពូ?

សល់ ៖ ខ្ញុំអត់ដែលស្គាល់ទេ និយាយរឿងគ្រួសារគាត់ឃើញៗ ប៉ុនអត់ដែលបានស្គាល់ឈ្មោះគេ មិនដែលហ៊ាននិយាយជាមួយគេទេ ព្រោះគេអ្នកធំ (សើច) ។

ដារ៉ា ៖ ហើយមានកូននៅ?

សល់ ៖ មាន!

ដារ៉ា ៖ មានកូនប៉ុន្មាននាក់?

សល់ ៖ ខ្ញុំទាន់តែអានូមួយ ដល់ក្រោយមកមិនឈ្មោះអីមួយ អត់ដឹងវានៅតូច ។

ដារ៉ា ៖ ឈ្មោះអី ឈ្មោះអានូ?

សល់ ៖ ឈ្មោះ នូ មួយ ។

ដារ៉ា ៖ អីចឹងគាត់មានកូន២នាក់?

សល់ ៖ ដល់ទៅក្រោយមកមិនដឹងប៉ុន្មានយើងបែកគ្នាយូណា បើកាលនោះឃើញកូនពីរ ប៉ុនអាមួយ នោះខ្ញុំអត់ស្គាល់ឈ្មោះវានៅតូច ដឹងគាត់មានកូនក្រោយទៀតប៉ុន្មានខ្ញុំអត់ដឹងដែរ ។

ដារ៉ា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន២ហ្នឹង?

សល់ ៖ ខ្ញុំឃើញ ឃើញតែប្រុសៗទេណា កាលហ្នុង កាលខ្ញុំស្គាល់ហ្នុងណា ។

ដារ៉ា ៖ ឈ្មោះ នូ ហ្នុង ប្រុសដែរ?

សល់ ៖ ប្រុស ។

ដារ៉ា ៖ អាតូចមួយហ្នុងក៏ប្រុសដែរ?

សល់ ៖ បាទ! ប្រុស ដឹងប៉ុន្មាននាក់ក្រោយទៀតខ្ញុំអត់ដឹងណាបែកគ្នាយូ ។

ដារ៉ា ៖ ម៉េចបានពូដឹងថាឈ្មោះ នូ និងកូនក្មេងម្នាក់ទៀតនោះជាកូនរបស់តាសឿន?

សល់ : ចុះគាត់យកទៅនៅកន្លែងសន្តិសុខដែរ កូនប្រពន្ធគាត់នៅនោះដែរ ។

ដារ៉ា : កូនប្រពន្ធគាត់ហ្នឹងអ្នកនៅខាងណា?

សល់ : ប្រពន្ធអ្នកស្រុកគាត់មកតែជាមួយគាត់ដែរមក ។

ដារ៉ា : សម្បុរគាត់ម៉េចដែរប្រពន្ធហ្នឹង?

សល់ : ជ្រះៗស្អាតៗទាំងអស់តែគ្នាហ្នឹង ។

ដារ៉ា : ពូអារៀបរាប់ជាស្ថានភាពយ៉ាងម៉េចដែរប្រជាជនដែលបញ្ជូនទៅសន្តិសុខហ្នឹង ហើគាត់មានកំហុសមានអីយ៉ាងម៉េចដែរ?

សល់ : ខ្ញុំវាដឹងមិនដល់បងកាលហ្នឹង ដូចថាយើងវានៅក្មេង វានៅខ្ចី វាខ្ចីនោះដូចថាវាអវិជ្ជាទៅចុះគេរុញទៅ ថាយាមៗ វាមិនដឹងដូចថាគេទៅតាមភូមិឃុំ មិនដឹងថាគេខុស ត្រូវអីគេរុញយកទៅដាក់នៅនោះឯង ឲ្យទៅកសាងខ្លួន លត់ដំទៅ វ៉ៃថ្មវ៉ៃអី ធ្វើស្រែធ្វើចម្ការអីទៅណា កាប់គាស់ ដុត កាប់គាស់ព្រៃទៅណា ដាំដុះទៅណា វ៉ៃថ្មភ្នំហ្នឹង ថ្មគេឲ្យវ៉ៃទៅណាដែកត្បែងម្នាក់មួយៗ វ៉ៃកាប់គាស់យកទៅដាក់អាងត្រពាំងថ្មមិនដឹងកាលណុះខ្ញុំក្តាប់មិនបានដែរ តាមមើលយកទៅដាក់អាងត្រពាំងថ្មហ្នឹងធ្វើមុខទឹកសំណាងណា ។

ដារ៉ា : ការងារនៅកន្លែងសន្តិសុខហ្នឹងសំខាន់អីខ្លះទៅពូដែលអ្នកទោសធ្វើ?

សល់ : សំខាន់អាត្រង់វ៉ៃថ្ម ។

ដារ៉ា : វ៉ៃថ្មយ៉ាងម៉េចទៅ?

សល់ : វ៉ៃគាស់ថ្មយកដុំៗ ។

ដារ៉ា : បើនិយាយពីចំនួនអ្នកទោសច្រើនទេពូ?

សល់ : អូ! ច្រើនដែរ ស្គាល់មិនអស់ រាប់មិនអស់ទេ ច្រើនមានស្រីមានប្រុស ។

ដារ៉ា : មានក្មេងអី?

សល់ : បាន!

ដានី : ប្រហែលប៉ុន្មានទៅបើតាមពូស្មាន?

សល់ : អូ! ចូលរាប់រយទៅ មិនដឹងប៉ុន្មានទេ ក្តាប់មិនបានទេ គ្រាន់តែឃើញវាច្រើនៗទៅ អានេះរបៀប យើងចង់និយាយថាខ្លះដូចថានិរតីមកចាប់កម្មាភិបាលយើងណា ចាប់អីចេះទៅវានៅកូនប្រពន្ធ ជួនកាលអានិរតីនោះវាស្អប់ទៅ វាយកយើងនៅដាក់កន្លែងសន្តិសុខក៏មានជួនកាលអាខ្លះរត់ទៅថៃអីចឹងទៅនៅប្រពន្ធយកទៅធ្វើបាបអីចឹងទៅ វាដូចតែធ្វើបាបយកយើងទៅដាក់ ឲ្យយើងទៅកសាង លត់ដំការងារទៅណា វាស្រេចតែចិត្ត កាលនោះវាអត់មានទៀងកំណត់ទេ ។

ដារ៉ា : អ្នកទោសដែលនៅហ្នឹងមានដាក់ខ្នោះទេ?

សល់ : មាន ។

ដារ៉ា : អាវេងកន្លែងដាក់ខ្នោះ និងអ្នកទោសផ្សេងទៀតនៅជាមួយឡូកឡំគ្នា ឬក៏បែកគ្នាដាច់ពីគ្នា?

សល់ : បែកគ្នា ដូចថាពួកខ្ញុំ ឧបមាថានៅ១០នាក់ម៉ាក្រុមអីចឹងនៅណុះ១០ នៅណោះ១០ កាលណុះមានវាចំណុះ វាមានពួកនិរតីណាមក អំណាចគេធំៗណា យើងពាយ័ព្យគ្រាន់តែអាចក់អាថែម យើងមិនមានសិទ្ធិអីទេ ហៅទៅនៅជុំគេមែន ប៉ុនថាយើងដូចប្រមោច ដូចអន្ទរណា អំណាចគេធ្វើអីតាមតែអំពើចិត្តរបស់គេ ។

ដារ៉ា : កន្លែងសន្តិសុខភ្នំត្រយោងហ្នុងមានអ្នកទោសជាប់ខ្នោះដែរ?

សល់ : មាន!

ដារ៉ា : អ្នកទោសជាប់ខ្នោះហ្នុងភាគច្រើនក្នុងវ័យប៉ុណ្ណា?

សល់ : មានចាស់ មានក្មេង ។

ដារ៉ា : ហើខ្នោះហ្នុង ខ្នោះវាងយ៉ាំងម៉េចដែរ?

សល់ : ខ្នោះឈើយើងដាក់ដែក ។

ដារ៉ា : ឈើដាក់ដែក!

សល់ : ឈើស៊កដែកអីចេះ ។

ដារ៉ា : ឈើស៊កក្នុងកងដែក?

សល់ : បាទ! ដាក់ដែកពីលើ ។

ដារ៉ា : ឈើដែលគេដាក់ផ្គួបគ្នាហើយគេចោះ...

សល់ : បាទ! គេចោះទៅគេដាក់ជើងទៅណា ។

ដារ៉ា : អីចឹងអ្នកទោសប្រភេទណាដែលគេអាចដាក់ខ្នោះ និងដាក់ជើង?

សល់ : វាតាមកម្រិត ខ្ញុំក្តាប់មិនបានដែរ ប៉ុនបានតែម៉ាឃើញៗដែរ យើងអត់ហ៊ានសួរគេដែរណា បានតែម៉ាឃើញៗ យើងនៅជុំគេមែន ប៉ុនយើងអត់មានសិទ្ធិទៅសួរទេ ប៉ុនអានេះវាតាមកម្រិតធ្ងន់ស្រាលរបស់គេយើងមិនអាចដឹងថាកំហុសនោះវាធ្ងន់ប៉ុណ្ណា យើងអត់ដឹង វាចូលអាដំណើរច្បាប់គេវាតឹងពេកទៅ យើងអត់ហ៊ាន មិនហ៊ានទាំងសួរ វាខ្លាចអានៅជុំគេហើយក៏ខ្លាចគេទៀត យើងវាអត់មានបានស្រួលណា គិតតែរឿងភ័យខ្លួន ព្រោះច្បាប់កាលហ្នុងវាតឹងតែង វាដូចថាតឹង វាថាតឹង តឹងហើយ ។

ដារ៉ា : តាសឿនហ្នុង ពូមើលទៅមនុស្សកាច ឬក៏យ៉ាំងម៉េចដែរ?

សល់ : បើតាមមើលមនុស្សវា បើសិនយើងចង់និយាយថា មនុស្សតាសឿន មនុស្សមិនមែនជាអ្នកល្ងង់ទេ មនុស្សគាត់អ្នកចេះអក្សរអីដែរ មិនមែនអ្នកល្ងង់ទេ តាមខ្ញុំមើលណា អ្នកចេះអ្នកដឹងដែរ ប៉ុនដែលថាសម័យនោះ ដល់ដំណាក់កាលនោះវាត្រូវតែកាច បើនិយាយទៅវាត្រូវតែកាច ។

ដារ៉ា : អីចឹងពីពូ ហ៊ីនឹងទំនាក់ទំនងមកតាសឿនអីចឹងតាមរយៈណាទៅពូ ឬតាសឿនគាត់មកបញ្ជាសន្តិសុខដូចពូផ្ទាល់ម៉ង ឬក៏យ៉ាំងម៉េច?

សល់ : តាសឿនមកបញ្ជា!

ដារ៉ា : បាទ! ដូចជាឲ្យទៅយាមកាម ឲ្យទៅយកអ្នកទោសទៅនេះទៅនោះអីចឹងណាពូ?

សល់ : អត់ទេ! ខ្ញុំគ្រាន់ថាគេធ្វើកន្លែងឲ្យនៅ១០ៗនាក់អីចឹងទៅ ដូចថាយើង ព្រឹកឡើងគេគ្រាន់តែប្រាប់ថាទៅគាស់គល់ ដាំដំឡូង ស្អីៗគេប្រាប់យើងហើយណា យើងក៏នាំម៉ែៗទៅ កាលនោះហៅតែម៉ែៗទេណា ពួកវាយកណ្តាលមានកូនមានចៅទៅណា ទៅកាប់ទៅគាស់ ទៅដាំទៅដុះ មិនឲ្យយើងនៅទំនេរទេណា ចេះតែធ្វើទៅណា ។

ដារ៉ា : អីចឹងពូទៅអ្នកទោសនៅក្នុងកន្លែងហ្នឹង អ្នកដាប់ឃុំឃាំងនៅកន្លែងហ្នឹងណា ពូហៅម៉ែៗអីចឹងដែរ?

សល់ : បាទកាលហ្នុងហៅតែពុកម៉ែៗអីចឹងទៅ មិនដឹងថាម៉េច គេទម្លាប់អីចឹងទៅ គេទម្លាប់ហៅទូទៅទៅ កាលនោះគេហៅអីចឹងឯង ។

ដារ៉ា : នៅពេលដែលនៅយាមកាមអីចឹងទៅ ដែលមានអ្នកដាប់ឃុំឃាំងហ្នឹងព្យាយាមរត់គេច ឬក៏យ៉ាំងម៉េចទេ?

សល់ : ជួនកាលក៏មានរត់ចេញខ្លះទៅបាត់ទៅណា ជួនកាលក៏នៅទៅ ខ្លះដែលចិត្តបួរផ្តាច់ថាស្លាប់រស់ក៏មានរត់ចេញទៅ មានបាត់ទៅក៏មានដែរ មិនដឹងថាងាប់រស់ទៅណា ខ្លះក៏នៅដែរ ខ្លះក៏មិនរត់ដែរ ។

ដារ៉ា : បើសិនជារត់អីចឹង តើពូជាសន្តិសុខហ្នឹងមានសិទ្ធិបាញ់ទេពូ?

សល់ : កាលនោះបើសិនជាច្បាប់គេ បើថារត់ខទាហករណ៍ណា វាត្រូវតែឲ្យយើងបាញ់ បើយើងមិនបាញ់គេបាញ់យើងចោល គេសម្លាប់យើងមកវិញ ច្បាប់គេណា អត់មាននិយាយលេងទេ ឧបមាថាឃើញរត់នៅមុខអីចេះ ខទាហករណ៍ ប៉ុនខ្ញុំនៅមិនដែលឃើញមានអ្នកណារត់ទេ ស្រីៗនោះគ្នាដែររត់ទៅណា បើប្រុសតាមគេក្តាប់ ពួកអ្នកតាកែវអីគេក្តាប់ផងវាចំណុះគ្នាណា ហ៊ីយើងពាយ័ព្យអីយើងមិនសូវមានសិទ្ធិអីទេ ដូចខ្ញុំថាអីចឹង ស្អីក៏ដោយ ។

ដារ៉ា : អីចឹងអ្នកដាប់ឃុំឃាំងដែលពូយាមកាមឲ្យធ្វើការធ្វើអីភាគច្រើនស្រីៗ ឬក៏ប្រុសៗ?

សល់ : ស្រីៗ សុទ្ធតែម៉ែៗស្រីៗ ។

ដារ៉ា : គាត់មានគ្រួសារមានកូនហើយឬយ៉ាងម៉េច?

សល់ : បាទ! មានកូនមានអីខ្លះ ។

ដារ៉ា : នៅក្នុងកន្លែងសន្តិសុខហ្នឹង តើប្រធានសន្តិសុខហ្នឹង តើប្រធានសន្តិសុខហ្នឹងនែនាំមកអ្នកសន្តិសុខដូចពូហ្នឹងយ៉ាងម៉េចខ្លះទាក់ទងនិងការការពារ?

សល់ : គេគ្រាន់តែប្រាប់ថាមើលយាមកុំឲ្យបាត់មនុស្ស កុំឲ្យរត់កុំលួនអីណា គ្រាន់តែប្រាប់អីចេះ យើងក៏ធ្វើតាម ។

ដារ៉ា : ប្រាប់ហ្នុង ប្រាប់នៅក្នុងអង្គរប្រជុំ ឬក៏ម៉េច?

សល់ : ប្រាប់នោះ! ជួនកាលគេប្រជុំប្រាប់ដែរ ហៅយើងទៅប្រជុំដែរណា ប្រជុំប្រាប់ឲ្យយើងមើលទទួលខុសត្រូវណា បាត់មនុស្សបាត់អីអ្នកនោះទទួលខុសត្រូវ អត់បានទេ បទបញ្ញាតិគេណា យើងក៏ត្រូវតែប្រឹងប្រែងការពារទៅណា កុំឲ្យបាត់កុំឲ្យបង់ វាខ្លាចតគ្នា តែគេថាម៉េចអីចឹងហើយ ។

ដារ៉ា : ការប្រជុំបានប្រាប់ច្បាស់ៗតែម្តង?

សល់ : បាទ! ប្រាប់ច្បាស់ៗតែម្តង ។

ដារ៉ា : ពូនៅចាំសម្តីដែលប្រធានគុក ប្រធានមន្ទីរសន្តិសុខហ្នឹងប្រាប់មកពូ ដូចជាអីខ្លះទៅពូ?

សល់ : បាទ! ប្រាប់ថាឲ្យយើងមានការប្រុងប្រយ័ត្ន ទី១ អ្នកទោសលួចកាំភ្លើងយើងវ៉ៃយើងបាញ់យើងវិញ ដែលយើងនៅតូចនៅក្មេងគេនែនាំយើងដែរ ហឺឈរយាមគេ កុំឈរបៀត ឲ្យឈរឆ្ងាយៗ ដូចគេនៅដើមពុទ្រានៅធ្វើការអីចេះ យើងឈរណោះ បើថាមានការអីនិយាយពីឆ្ងាយមក អត់ឲ្យមកបៀតដល់យើងទេ ខ្លាចគេស្រវ៉ាកាំភ្លើងយើងបាញ់យើង ឬក៏ស្អី អីចឹងណា អានោះមេគេប្រាប់ណា ការប្រុងប្រយ័ត្ន ។

ដារ៉ា : ហ៊ីទី២!

សល់ : ទី២ឲ្យយើងជួយមើលការខុសត្រូវដូចថា យើងធ្វើចម្ការធ្វើអីទៅ ដាំដុះទៅ យើងប្រាប់ទៅថាដាំ ដាំទៅព្រាតទៅ ថាត្រូវកាប់គាស់ដីក៏ធ្វើទៅ ។

ដារ៉ា : ទាក់ទងទៅនឹងការការពារខ្ញុំងហ្នុង បើសិនជាមានករណីថា ខ្ញុំងរត់ ក្នុងករណីថាអ្នកទោសអីរត់អីចឹង តើមានការនែនាំយ៉ាងម៉េច?

សល់ : បើសិនជាគេរត់ មិនដែលប្រាប់យើងទេ អត់ប្រាប់ទេ តែរត់ហើយគ្មានមកប្រាប់យើងថាខ្ញុំរត់ទេ ។

ដារ៉ា : អត់ទេ! ចង់និយាយថាបើសិនជាមានករណីថាមានរត់មានអីណា តើក្នុងពេលប្រជុំដែលមេប្រជុំប្រាប់នោះណា ថាឲ្យចាត់វិធានការយ៉ាងម៉េចអីយ៉ាងម៉េច?

សល់ : បើសិនជាគេ ប៉ុន្តែនៅតែរត់ខ្លះអីចឹងហើយ ប៉ុន្តែគេថា ថាដែរ ប៉ុន្តែដល់ពេលដែលរត់បាត់គឺបាត់ដែរ ។

ដារ៉ា : តែថាហ្នឹង ប្រធានគុកហ្នឹងគេថាយ៉ាងម៉េច?

សល់ : ថាឲ្យយើងប្រុងប្រយ័ត្ន បើថាបាត់អ្នកទោសអ្នកអី យើងក៏គេមិនទុកដែរ គេថាអីចេះណា ប៉ុនដល់យូៗទៅវាមានបាត់មួយបាត់ពីរអីដែរ យើងទៅធ្វើម៉េច បើគេសម្លាប់ ក៏សម្លាប់ទៅ ប៉ុនគេក៏មិនមានធ្វើអីយើង ប៉ុនគេគ្រាន់តែថាឲ្យយើងប្រុងប្រយ័ត្ន ។

ដារ៉ា : មុនហ្នឹងបន្តិចពូបាននិយាយដែរថា បើសិនជាអ្នកជាប់ឃុំឃាំងរត់អី សន្តិសុខអីអាចបាញ់អាចអីបាន?

សល់ : បាទ! អារឿងនោះដូចថាច្បាប់គេ គេគ្រាន់តែប្រាប់យើងណា ប៉ុនយើងមិនដែលបានទៅបាញ់អ្នកណាទេណា ចិត្តយើងណា មិនបានទៅបាញ់អ្នកណាងាប់បានមួយទេ គេគ្រាន់តែថាទេ ។

ដារ៉ា : ខ្ញុំគ្រាន់តែចង់ដឹងអីចេះទេ ចង់ដឹងថា តើពេលដែលប្រជុំនៅក្នុងកងសន្តិសុខអីនៅកន្លែងមន្ទីរសន្តិសុខអីណាពូ ពេលប្រជុំហ្នឹង មេបានប្រាប់ដែរឬទេ បើសិនជាអ្នកជាប់ឃុំឃាំងហ្នឹងរត់យើងអាចបាញ់ យើងអាចបាញ់អីចឹងណា ខ្ញុំមិនចង់សួរថា ពូធ្លាប់បាញ់ មិនបាញ់ទេ ខ្ញុំចង់សួរអីចឹងទេ?

សល់ : បាទ! ច្បាប់គេ គេថាអីចុះឯង បើរត់បាញ់ហើយ ។

ដារ៉ា : តែរត់បាញ់ហើយន៎?

សល់ : បាទ!

ដារ៉ា : ជារឿងរាល់ការប្រជុំនោះអ្នកណាមកប្រជុំ?

សល់ : អត់ទេ! ឃើញតែកន្លែងសន្តិសុខគេហ្នឹង ប្រធានសន្តិសុខ ។

ដារ៉ា : មានតាសឿនហ្នឹង?

សល់ : បាទ! តាសឿន ។

ដារ៉ា : អីចឹងជារឿងរាល់លើកឲ្យតែប្រជុំដាក់ផែនការ ឬក៏យាមអី តាសឿនហ្នឹងគាត់អ្នកដាក់...

សល់ : បាទ! ចុះគាត់មេ ប្រធាននោះ គាត់ប្រធានធំ ។

ដារ៉ា : ហើបន្ទាប់ពីតាសឿនហ្នឹងមានអ្នកណាទៀតពូស្គាល់ទេ?

សល់ : វាយូឆ្នាំទៅយើងចង់ភ្លេចអស់វាច្រើនណាកម្លាំងនោះ វា៣០នាក់ណុះម៉ាកងតូចដែរ ។

ដាវ៉ា ៖ អត់ទេ! ចង់និយាយថាអ្នកគ្រប់គ្រងនៅហ្នឹង ដូចថាស្គាល់តាសឿនមេអីចឹង បន្ទាប់ពីតាសឿនមកមានអ្នកណាៗបន្តមកទៀតអីចឹងណា?

សល់ ៖ មានដែរ ប៉ុនវាបាត់រូបបាត់រៀងអស់ហើយមានតែឈ្មោះហ្នុង ។

ដាវ៉ា ៖ បាទ! ខ្ញុំចង់ស្គាល់តែឈ្មោះហ្នុងដែរ!

សល់ ៖ ឈ្មោះ ភឹម នោះមួយ ខ្ញុំថាមិនអស់ទេ ថាតែចោះៗ ។

ដាវ៉ា ៖ បាទ! ថាតាមតែពូចាំបាន!

សល់ ៖ បាទ! ភឹម នោះមួយ ថង នោះមួយ ។

ដាវ៉ា ៖ អីទៀតពូ!

សល់ ៖ អីទេ រកនឹកមិនឃើញទេដូចថា២០, ៣០ឆ្នាំទៅវាយូភ្លេចអស់ ។

ដាវ៉ា ៖ ឈ្មោះ ភឹម ហ្នឹងមនុស្សមកពីខាងណាពូ?

សល់ ៖ មកពីខាងតាកែវ ។

ដាវ៉ា ៖ ខាងតាកែវដែរ!

សល់ ៖ បាទ! សរដូចគាត់អីចឹង ដឹបងមាំ ។

ដាវ៉ា ៖ ភឹម ហ្នឹងគាត់ទទួលខុសត្រូវផ្នែកអី?

សល់ ៖ ព្រោះវា មិនដឹងថាជាស្អីៗផងទេ កាលនោះដូចជាលេងបាយឡុកបាយឡ និយាយពិចារណាទៅ ដូចកូនក្មេងលេងអ្នកស្រុក អាយើងធ្វើការទៅជុំគេ នៅជុំគេមែន ដល់គេបែកយើងដាច់ទៅ អាអ្នកធំៗ គេគិតតែការងារគេទៅធំៗទៅណា យើងក្តាប់គេអត់បាន ដូចជាខ្ញុំក្តាប់ភាពគេអត់បានមិនសូវមានពេលមកអង្គុយលេងជុំគ្នាអត់បាន គិតតែពីការងាររៀងតែខ្លួនទៅ ហីយើងក៏មិនដឹងពីឋានៈគេស្អី ពីស្អី អីចេះណា ។

ដាវ៉ា ៖ ចុះ ថង មនុស្ស ថង?

សល់ ៖ ថង ក៏យើងអត់ដឹងតួនាទីគេថាធ្វើអីទេ ដូចថាគេអ្នកធំៗអីចឹង ឧទាហរណ៍ថាមាឌគេធំៗគេចាស់ៗណាការងារអីគេអ្នកគេអ្នកអីទៅ គ្នាគេទៅ ។

ដាវ៉ា ៖ ឈ្មោះ ភឹម និងឈ្មោះ ថង ហ្នុងមានវ័យប្រហាក់ប្រហែលនឹងតាសឿនឬក៏យ៉ាងម៉េច?

សល់ ៖ នែ មិនដឹងជាយ៉ាងណាទេ អារឿងឲ្យធំដូចតាសឿន មិនមែនធំផង...

ដាវ៉ា ៖ ចង់និយាយថាពីវ័យរបស់គាត់ណាពូ?

សល់ ៖ អូ! វ័យរបស់គាត់ អត់ទេពួកនោះកម្លោះៗ ។

ដាវ៉ា ៖ នៅកម្លោះៗទេ!

សល់ ៖ បាទ! ប៉ុនមាឌប៉ុនណោះៗឯង ធំៗ ។

ដារ៉ា ៖ កម្ទោះ ប៉ុនចង់និយាយថាមាឌធំៗ!

សល់ ៖ បាទ! មាឌធំៗ ។

ដារ៉ា ៖ ហើនៅក្នុងកងរបស់ពូ ដែលពូនិយាយថាម៉ាកងតូច មានគ្នាប្រហែល៣០នាក់មិនអីចឹងឬ?

សល់ ៖ អានេះខ្ញុំស្មានទេណា ប្រហែលជា៣០នាក់ មិនដែលមានបួនដប់នាក់ទៅការពារសន្តិសុខទេ យ៉ាងទាបក៏៣០នាក់ដែរ ។

ដារ៉ា ៖ អីចឹងទៅកងរបស់ពូម៉ងឬ?

សល់ ៖ បាទ! នៅក្នុងកងរបស់តាសឿន ។

ដារ៉ា ៖ និយាយនេះកងការពាររបស់តាសឿនផ្ទាល់ទាំងអស់ហ្នឹង?

សល់ ៖ បាទ!

ដារ៉ា ៖ ៣០នាក់ហ្នឹង!

សល់ ៖ បាទ! នេះខ្ញុំថាស្មានទេណា មិនដឹងថាម្ភៃជាងឬក៏អី ខ្ញុំថាកំណត់ម៉ាកងតូចទៅចុះ៣០ ។

ដារ៉ា ៖ អីចឹងក្នុងមួយក្រុមរបស់ពូដែលការពារមានគ្នាប៉ុន្មាននាក់ពូ?

សល់ ៖ ប្រហែលជា៣០នាក់ ។

ដារ៉ា ៖ អីចឹងពេលបែងចែកចេញទៅយាមមួយក្រុមៗមានគ្នាប៉ុន្មាននាក់?

សល់ ៖ បាទ! មួយក្រុមៗគេចាត់ការ ដាក់យាមបំបែកៗគ្នាអស់ហើយ ។

ដារ៉ា ៖ ភាគច្រើនពួយាម ក្រុមការងាររបស់ពូហ្នឹងជាមួយអ្នកណាខ្លះពូអាចចាំទេ?

សល់ ៖ មិនចាំទេ ងាប់រស់អស់ខ្លះហើយវាស្លាប់អស់ វាងាប់រស់អស់ខ្លះៗហើយ ។

ដារ៉ា ៖ តែនៅចាំជាឈ្មោះទេពូ ដែលជួបជាមួយពូផ្ទាល់នៅក្នុងក្រុមណាពេលដែលយាមណា?

សល់ ៖ វាងាប់អស់ហើយដែលនៅជុំជាមួយខ្ញុំងាប់អស់ ។

ដារ៉ា ៖ អាចថាចាំជាឈ្មោះ?

សល់ ៖ ឈ្មោះ អាខេច នោះមួយ អាយៃ៉ នោះមួយ អាអយនោះមួយ ធឿន នោះមួយ ស្លាប់ៗអស់ហើយ ស្លាប់ដែលយួនមករំដោះ ។

ដារ៉ា ៖ ឈ្មោះ ខេច, ឈ្មោះ យៃ៉, ឈ្មោះ អយ, ឈ្មោះ ធឿន ហ្នឹងសុទ្ធតែនៅក្នុងកងជាមួយពូ?

សល់ ៖ បាទ! ងាប់អស់ហើយ គ្នាខ្មោចអស់ហើយ ។

ដារ៉ា ៖ ហើ ឈ្មោះ ខេច, ឈ្មោះ យៃ៉, ឈ្មោះ អយ, ឈ្មោះ ធឿន ហ្នឹងអ្នកស្រុកជាមួយពូដែរ ឬយ៉ាងម៉េច?

សល់ ៖ គេអ្នកនៅព្រះនេត្រព្រះយើងហ្នឹង ប៉ុនមិនដឹងនៅភូមិអីនៅព្រះនេត្រព្រះយើង ។

ដារ៉ា : អ្នកទាំងបួននាក់ហ្នឹងស្លាប់ដោយសារអីទៅពូ?

សល់ : ស្លាប់ដោយសារកាលវៀតណាមរំដោះមក ពួកនេះរត់ចូលព្រៃ ដល់រត់ទៅវាកើតសង្គ្រាមម្តងទៀតនោះទៅវ៉ៃគ្នាទៅ អាខ្លះស្លាប់នឹងអត់បាយ អាខ្លះស្លាប់នឹងឈឺចាញ់ អាខ្លះក៏ត្រូវគ្រាប់ខ្លះទៅណា ។

ដារ៉ា : នៅក្នុងមន្ទីរសន្តិសុខភ្នំត្រយោងហ្នុងមានដាក់កន្លែងសួរចម្លើយ ឬដាទារុណកម្មអីទេ?

សល់ : វាមិនអត់ទេ អារឿងអីចុះណា ប៉ុន្តែថាសម្រាប់ពួកខ្ញុំគ្មានបានទៅបៀតគេ គេមិនដែលហៅរកទេអារឿងស្អីៗហ្នុងណា គេហៅរកតែគេអ្នកមាឌធំៗអី គេប្រជុំគេប្រើប្រាស់អីតែគ្នាគេហ្នុង យើងគ្រាន់តែកូនដៃកូនជើង យើងគ្រាន់តែយាមៗទៅណា យើងគេមិនសាយហៅយើងទៅធ្វើអីចុះៗទេ ។

ដារ៉ា : តែពូនេះជាការជឿជាក់ថាមានកន្លែងធ្វើទារុណកម្ម មានកន្លែងសួរចម្លើយ គ្រាន់តែពូជឿអីចឹងតែពូបានឃើញន្លែងហ្នុងផ្ទាល់ភ្នែកទេ?

សល់ : ឃើញតែពេលដាក់ខ្នោះគេសួរចម្លើយហើយ ទៅឃើញដូចថាកន្លែងខ្នោះគេសួរចម្លើយហើយ ទៅយើងខុសអីយើងអីដែលគេបញ្ជូនមកពីតាមភូមិឃុំនោះទៅឲ្យណា ប៉ុន្តែអានោះដូចថាសិទ្ធិគេអ្នកសួរចម្លើយផ្សេងទៅណា ដូចថាផ្នែកគេផ្សេងៗទៅណា ដូចថាខ្ញុំអ្នកការពារខ្ញុំឧទាហរណ៍ថាមើលអ្នកដំឡូងដាំអីវាផ្សេងយើងអត់មានសិទ្ធិទៅប្រឡូកឡុំអីជាមួយគេទេអីចឹងណា យើងនៅក្មេងៗផង ។

ដារ៉ា : អីចឹងពូធ្លាប់ឃើញកន្លែងសួរចម្លើយដែរ?

សល់ : បាទ!

ដារ៉ា : ធ្លាប់ឃើញកន្លែងធ្វើទារុណកម្មដែរ?

សល់ : ទេអារឿងធ្វើ អារឿងវ៉ៃដំប្រំផាក់អី វ៉ៃសម្លាប់អីខ្ញុំអត់បានដឹងទេអារឿងហ្នឹង ។

ដារ៉ា : តែគ្រាន់តែពូដឹងថាមានកន្លែងសួរចម្លើយ?

សល់ : បាទ! អារឿងសួរចម្លើយ តែមានខ្នោះហើយគេសួរហើយ ព្រោះគេដាក់ខ្នោះហើយឧទាហរណ៍ថាទោសធ្ងន់កម្រិតធ្ងន់ទៅគេសួរទៅណា សួរចម្លើយអី អានោះវាច្រើនតែផ្នែកគេអ្នកចេះអ្នកដឹង អ្នកនេះទេ ដែលគេទៅសួរចម្លើយទៅសួរអី បើត្រឹមតែពួកខ្ញុំ ដូចខ្ញុំប្រាប់ថាដូចស្មោរអីចឹងឯង គ្មានសិទ្ធិអីទៅបៀតគេបានទេ ។

ដារ៉ា : អ្នកទោសដែលជាប់ខ្នោះ ពូច្រើនទេដែលជាប់ខ្នោះ បើធៀបជាមួយអ្នកដែលអត់ជាប់ខ្នោះ?

សល់ : វាមិនមែនជាច្រើនណាស់ណាទេ វាខ្ទះមួយខ្ទះពីរដែលដាក់ទៅ អាខ្លះគេសួរទៅក៏លែងទៅ ដោះលែងក៏មានទៅណា ។

ដារ៉ា : ដោះក៏នៅក្នុងហ្នឹងដដែលទេ?

សល់ : ដោះលែងទៅក៏នៅក្នុងនោះ ធ្វើការងារនោះ ។

ដារ៉ា : មិនមែនព្រលែងអីវិញទេ?

សល់ : អត់ទេ ព្រលែងឲ្យធ្វើការងារនៅនោះទៅណា ខ្លះទៅណាអាហ្នឹងតាមខ្ញុំមើលឃើញណា ។

ដារ៉ា : ចុះការហូបចុកនៅកន្លែងភ្នំត្រយោងហ្នឹងតូ?

សល់ : ដាបបបរដដែល ។

ដារ៉ា : អ្នកជាប់ឃុំឃាំងនៅហ្នឹងណា?

សល់ : បាទ! បបរតែដដែលហ្នឹង ហូបបបរអត់ដូចតែយើងនៅតាមសហករណ៍អីចឹង ដូចតែគ្នា ។

ដារ៉ា : ចុះសម្រាប់ក្មេងដែលទៅជាមួយ ដែលជាប់ទៅជាមួយឪពុកម្ដាយអីចឹងណា?

សល់ : គេឲ្យតែរបបតិចៗដូចតែយើងនៅតាមភូមិយើងអីចឹងឯង នៅកន្លែងនេះក៏ដូចតែនៅកន្លែងនោះ វាអត់ខុសគ្នាទេ ។

ដារ៉ា : បើធៀបពីការងារនៅតាមសហករណ៍ នៅក្នុងកន្លែងភ្នំត្រយោងមួយណាប្រសើរជាង?

សល់ : នៅតាមសហករណ៍យើងឧបមាថាយើងអាចមានលួចទៅដកដំឡូង ឬលួចទៅបូតស្រូវមកហូបបានខ្លះបើយើងកន្លែងនេះវាតឹងជាង ព្រោះការងារគេឲ្យយើងធ្វើណា ។

ដារ៉ា : បើអត់មានអាហារអីគ្រប់គ្រាន់អីចឹងអ្នកជាប់ឃុំឃាំងនៅហ្នឹងអាចទៅវ៉ៃថ្ម ទៅវ៉ៃអីម៉េចបានដែលពូនិយាយពីខាងដើមថាមានឲ្យទៅវ៉ៃថ្មណា?

សល់ : បាទ! គេឲ្យទៅវ៉ៃរាល់តែថ្ងៃហ្នឹងឯង ប៉ុនអត់បេះតែអត់ទៅ ប៉ុន្តែបេះតែតស៊ូទៅ ហូបបបររួមហ្នឹង ប៉ុន្តែធ្វើៗវ៉ៃថ្ម គាស់ថ្មតែអីចឹងឯង វ៉ៃរាល់ថ្ងៃថ្ម ធ្វើរាល់ថ្ងៃ ។

ដារ៉ា : ពូមានដែលជួបប្រទះឃើញមនុស្សស្លាប់អីនៅកន្លែងភ្នំត្រយោងហ្នឹងទេ?

សល់ : វាស្លាប់នោះខ្លះវាឈឺ ជម្ងឺងអត់ឃ្លានទៅក៏មានងាប់ដែរអីចឹងណា មានស្លាប់មានរស់ខ្លះដែរមិនមែនថាបរិសុទ្ធទេ កន្លែងអីចុះនោះ ទោះបីមិនបានទៅកន្លែងសន្តិសុខផងនៅតាមភូមិអាខ្លះឈឺទៅវាមានថ្នាំព្យាបាលមកពីណា វាឲ្យលេបថ្នាំមួយគ្រាប់ប្រើបានមួយរយមុខអាគ្រុនក៏តែថ្នាំសូន្យៗដូចអាចម៍ទន្សាយហ្នឹង ផ្អែមៗ ឈឺក្បាលក៏ឲ្យថ្នាំនោះគ្រុនក៏ឲ្យថ្នាំនោះមិនដឹងថាស្អីៗ វាអត់មានថ្នាំសង្កូវលេបចាក់អីដូចយើង ។

ដារ៉ា : នៅក្នុងបរិវេណមន្ទីរសន្តិសុខភ្នំត្រយោងហ្នឹងធំទេពូ?

សល់ : បាទ! ធំម៉ាខាងកើតភ្នំទៅអីបេះ ធំ ។

ដារ៉ា ៈ បើនិយាយពីជីវិញប៉ុន្មានគីឡូទៅប៉ុន្មាន?

សល់ ៈ អូ! ប៉ុន្មានហិចតាទេវាធំដែរ អានេះវាពង្រីកទាំងចម្ការទាំងអី ធ្វើចម្ការធ្វើអីជងឲ្យយើងធ្វើណាវាធំដែរ ។

ដារ៉ា ៈ មានការកំណត់ដែនអីថាកន្លែងណាត្រឹមណាៗអីជាបរិវេណមន្ទីរសន្តិសុខភ្នំត្រយោង?

សល់ ៈ វាអត់បោះរបងផង វាគ្រាន់តែលួទៅមិនដឹងថាម៉េចវាអត់មានរបង វាអត់មានស្អីនឹងឃាំង វាអត់មានរបង វាគ្រាន់តែទុកធ្វើជាផ្ទះឲ្យយើងដេក យើងនៅទៅ វាមានទៅបោះរបងអីគងសំរាស់ឲ្យយើងចេញមិនរួចទៅមិនរួច វាមិនធ្វើណា ។

ដារ៉ា ៈ ពីមុនហ្នឹងបន្តិចដែរពូថា ពេលដែលតាណុបបញ្ជូនពូទៅកន្លែងសន្តិសុខភ្នំត្រយោងហ្នុង ពូថាទៅកន្លែងយាយថែម អីចឹងពូបានស្គាល់យាយថែមច្បាស់ដែរកាលហ្នុង?

សល់ ៈ យាយថែម បើនិយាយពីរឿងយាយថែមដែលគេអ្នកធំ អ្នកណាក៏ស្គាល់គេដែរ សូម្បីតែប្រជាជនដែលមិនបានធ្វើការក៏ស្គាល់យាយថែមដែរ ឲ្យតែមនុស្សមាសេរី ក្នុងចន្លោមកាលនោះណា ព្រោះយាយថែមគេវងដើរប្រជុំនោះ មកប្រជុំដល់រហាល មកប្រជុំ ចុះគេអ្នកធំគេដើរប្រជុំនោះ អ្នកណាក៏ស្គាល់មុខយាយថែមដែរ ។

ដារ៉ា ៈ ស្គាល់មុខយាយថែម ធ្លាប់បានឮឈ្មោះយាយថែមហ្នឹង ពូសំដៅថាបានស្គាល់អីចឹងឬពាក្យថាបានស្គាល់យាយថែម?

សល់ ៈ ពាក្យថាបានស្គាល់ ព្រោះយើងឃើញច្បាស់នោះណា ឃើញថានេះយាយថែម ។

ដារ៉ា ៈ អីចឹងពេលពូធ្វើការនៅកន្លែងសន្តិសុខភ្នំត្រយោងហ្នុងពូបានឃើញយាយថែមទេ?

សល់ ៈ ឃើញម្តងៗ ។

ដារ៉ា ៈ ឃើញហ្នុងឃើញនៅផ្ទះយាយថែម ឬឃើញនៅកន្លែងសន្តិសុខភ្នំត្រយោង?

សល់ ៈ ឃើញហ្នុងឃើញនៅពេលដែល ដែលឃើញគាត់ឃើញនៅផ្ទះគាត់ ។

ដារ៉ា ៈ នៅផ្ទះគាត់?

សល់ ៈ បាទ!

ដារ៉ា ៈ ផ្ទះគាត់នៅម្តុំណាពូ?

សល់ ៈ នៅឯភ្នំលៀបឯណោះ ។

ដារ៉ា ៈ ចុះពូឃើញគាត់នៅផ្ទះយ៉ាងម៉េចកើតបើនៅតែកន្លែងមន្ទីរសន្តិសុខ?

សល់ ៈ អត់ទេ! ដល់ឃើញ ឃើញអាចុងក្រោយដែលយួនជិតចូលមក យួនមករំដោះខ្មែរហ្នឹងគាត់ហៅទៅប្រជុំ ។

ដារ៉ា ៈ ហៅសន្តិសុខនៅហ្នឹងទាំងអស់ហ្នឹង?

សល់ :　បាទ! ហៅទៅប្រជុំ ។

ដារ៉ា :　ប្រជុំនៅឯណា?

សល់ :　នៅប្រជុំនៅផ្ទះគាត់ ។

ដារ៉ា :　ប្រជុំហ្នុងគាត់មាននិយាយថាម៉េចខ្លះ?

សល់ :　ទៅប្រជុំហ្នុងនែនាំថា ឥឡូវយួនចូលមកជិតដល់ស្រុកខ្មែរហើយឲ្យប្រុងប្រយ័ត្ន គាត់និយាយអីចេះណា គាត់និយាយថាយួនមកដាំក្បាលតែអុងហើយ ហីភ័យបណ្ដោយពួកខ្ញុំយើងនៅកុមារភ័យហើយ គេថាយួនមក មកដាំតែអុង ដល់ពុតែថាអីចុះភ័យ គាត់ប្រាប់អីចុះឯង ដល់នៅក្មេងៗគេប្រឆោតចេះតែភ័យហើយ ។

ដារ៉ា :　ចុះមានដែលឃើញយាយចែមអីទៅកន្លែងមន្ទីរសន្តិសុខភ្នំត្រយោងហ្នឹងទេ?

សល់ :　អត់ដែលឃើញចូល មិនដឹងថាគេចូលយប់ថ្ងៃម៉េច ខ្ញុំមិនដឹងទេ ប៉ុនសម្រាប់ខ្ញុំដូចអត់ឃើញអត់ដែលឃើញចូលផង ។

ដារ៉ា :　ចុះដូចថាកន្លែងពូស្នាក់នៅ កន្លែងពូឈរដើងម៉ង ពូនៅមន្ទីរសន្តិសុខភ្នំត្រយោងហ្នុងពូនៅម្ដុំខាងណាអីខាងណាពូ?

សល់ :　នៅខាងកើតភ្នំហ្នឹងឯង ។

ដារ៉ា :　បើនិយាយពីចម្ងាយថាតើវាឆ្ងាយគ្នាប៉ុន្មានពីកន្លែងពូឈរដើងទៅកន្លែងឃុំឃាំងជារោងជាអីពូ?

សល់ :　រោងគេនៅនឹងជើងភ្នំអីចេះ ដល់ខ្ញុំនៅកើតនោះវាឆ្ងាយប្រហែលជា អើយើងថាពីថ្នល់ជាតិមករបងវាឆ្ងាយដែរ ។

ដារ៉ា :　អាចថា ៥០ម៉ែត្រ?

សល់ :　បាទ! ១០០ម៉ែត្រអីទៅណា នៅឆ្ងាយដែរ ។

ដារ៉ា :　អីចឹងអារោងដាក់អ្នកទោសអ្នកអីនៅខាងជើងភ្នំ?

សល់ :　នៅជាប់ហ្នឹងភ្នំ ខាងកើតភ្នំ ខាងកើតរាងឈិតអីចេះ ពួកខ្ញុំនៅខាងកើតអិចេះ នៅត្រង់ណោះចែកគ្នាជាក្រុមជាកងទៅណា ។

ដារ៉ា :　ពូអាចគូរកន្លែងនេះបានទេពូ គូកន្លែងភ្នំត្រយោងអីចឹងកន្លែងណាពូឈរដើង កន្លែងណារោងដែលអ្នកទោសដែលអីនៅណាពូ?

សល់ :　ឧបមាថាអានេះកន្លែងរោងគេធំមួយ ឧទាហរណ៍ណា មានភ្នំអីចេះ អានេះភ្នំអីចេះ គេធ្វើនៅជាប់នឹងភ្នំអីចឹងឯង រោងវែងអីចេះមួយ ដល់មកកើតណោះរោងសហករណ៍គេវែង

រោងបាយគេបាយរួមគេណា  ឧទាហរណ៍អីចេះណាមានរោងបាយគេទៅក៏មានផ្ទះប្រជាជន គេតាមនេះ អីចេះៗហូរហែរទៅណា ថាមិនត្រូវទេខ្ញុំដល់អីចឹងមិនចេះគូរទេ ។

ដារ៉ា : ឯណាកន្លែងពូឈរដើង អានេះកន្លែងភ្នំត្រយោងហើយឬ?

សល់ : បាទ! អានេះរោងវែង ។

ដារ៉ា : សម្រាប់ដាក់អ្នកទោសហើយអាហ្នឹង?

សល់ : បាទ! ដាក់អ្នកទោស ។

ដារ៉ា : អ្នកទោសជាប់ឃុំឃាំង អាហ្នុងមានខ្នោះមានអីខ្លះអីចឹង!

សល់ : វាមិនមែនពេញតែរោងនោះទេ រោងវែងអីចឹងទៅ គេដាកខ្នោះខ្លះទៅ ដល់ផុតនោះក៏ដេក តាមរោងវែង ។

ដារ៉ា : ចុះកន្លែងណាដែលពូឈរដើង?

សល់ : ខ្ញុំឈរនៅឯណោះ នៅឯនេះឯង ។

ដារ៉ា : នៅម្ដុំនេះវិញ?

សល់ : បាទ! រោងបាយអីចេះ ខ្ញុំនៅឯណោះវិញ ។

ដារ៉ា : អីចឹងកន្លែងនេះ កន្លែងពូឈរដើងហើយណោះ?

សល់ : បាទ!

ដារ៉ា : អានេះរោងបាយ ។

សល់ : មករោងបាយរួមហើយ ដល់វេំដួងម៉ឹងដល់ពេលហូបបាយ ហូបបបរទៅហើយ ។

ដារ៉ា : ពីកន្លែងពូឈរដើងមកចម្ងាយកន្លែងរោងអ្នកទោសជាប់គុកនេះ!

សល់ : ប្រហែលជាចង់១០០ម៉ែត្រ ។

ដារ៉ា : ពីនេះមកនេះឬ?

សល់ : បាទ! ឆ្ងាយ ។

ដារ៉ា : ប្រហែល១០០ម៉ែត្រទេ!

សល់ : បាទ!

ដារ៉ា : ចុះពីរោងបាយមកកន្លែងនេះ?

សល់ : អានេះវាឆ្ងាយដូចគ្នាហ្នុងឯង ដល់នេះកន្លែងតាសឿននៅនេះ ។

ដារ៉ា : តាសឿននៅឯណា នៅម្ដុំនេះ?

សល់ : បាទ! កាលនោះណា កន្លែងអ្នកធំគេនៅនេះ ។

ដារ៉ា : សឿននៅម្ដុំនេះ ចុះបើសិនជាយើងមកផ្ទះយាយចែមយើងមកទិសខាងណាវិញ?

សល់ : ផ្ទះយាយបែមមកនៅភ្នំមួយខាងណោះវិញ ថ្នល់ជាតិនោះ ។

ដារ៉ា : អាណោះភ្នំ!

សល់ : បាទ!

ដារ៉ា : អីចឹងពីកន្លែងតាសឿនមកផ្ទះយាយបែមយើងត្រូវគូយ៉ាងម៉េចវិញ?

សល់ : ពីកន្លែងផ្ទះតាសឿនមកផ្ទះយាយបែមវាមកផ្លូវមកអីចេះឯង វាឆ្ងាយវានៅភ្នំនោះ ។

ដារ៉ា : អីចឹងផ្លូវទៅអីចេះឬ?

សល់ : បាទ!

ដារ៉ា : ផ្លូវទៅអីចេះគឺផ្លូវ!

សល់ : មកថ្នល់ជាតិនេះវិញ ។

ដារ៉ា : នេះសំដៅថាទៅផ្ទះយាយបែមហ្នុង?

សល់ : បាទ! មានភ្នំមួយហ្នុង ផ្ទះយាយបែមនៅអីចេះ ។

ដារ៉ា : អីចឹងតាមផ្លូវនេះវាត្រូវកាត់កន្លែងតាសឿនទៅ?

សល់ : បាទ! អានេះឧទាហរណ៍ថាភ្នំត្រយោងណា យើងលើកឧទាហរណ៍ថាអានេះកន្លែងរោងសន្តិសុខគេ អានេះកន្លែងតាសឿនទៅ កន្លែងពួកខ្ញុំនៅ ច្រើនកន្លែង វាភ្លេចអស់ខ្លះហើយ អ្នកការពារនោះណាវាយូណាស់ទៅហើយ ដឹងថាវាមិនអស់សេចក្ដីទេ វាគ្រាន់ថាបានទ្រួសៗខ្លះ ។

ដារ៉ា : អីចឹងពូនិយាយមុនហ្នឹងថា វៀតណាមជិតចូលហ្នុង យាយបែមបានហៅពូក្រុមកងការពារហ្នុងមកប្រជុំទាំងអស់?

សល់ : ប្រជុំផ្ទះគាត់ ។

ដារ៉ា : មកទាំងតាសឿនដែលអត់?

សល់ : មិនដឹង ដូចវាភ្លេច ប៉ុនគាត់ហៅមកប្រជុំម្ដង ដឹងតាសឿន គាត់មកឬមិនមកខ្ញុំវាភ្លេច ព្រោះគាត់ហៅមកប្រជុំម្ដងហ្នុងយួនចូលបណ្ដោយ ហៅមកប្រជុំផ្ទះគាត់ មកប្រជុំឲ្យប្រុងប្រយ័ត្ន យួនមកបាញ់ស្រួលណាស់ថាអីចេះ យួនមកអាករនឹងធាងត្នោតគាត់បំផុសបំផុលណា ដល់យើងនៅក្មេងចេះតែប្រុង ចេះតែខ្លាចហើយរត់បណ្ដោយ (សើច) ។

ដារ៉ា : កំឡុងពេលដែលពូរស់នៅភ្នំត្រយោងហ្នុង ពូដែលធ្លាប់ជួបប្រទះឃើញកន្លែងសម្លាប់មនុស្សអីដែរទេ?

សល់ : មិនបានជួបប្រទះ មិនបានឃើញទេ ព្រោះរឿងអីគេមិនសូវឲ្យយើងដឹងដែរ ព្រោះយើងនៅក្មេងៗណា ខ្ញុំចង់និយាយថា លើកឧទាហរណ៍ថា យើងវានៅកូនកុមារៗ ដល់មានរឿងអីគេមិនសូវឲ្យយើងដឹងទេ។

ដារ៉ា : អីចឹងនៅក្រុមការងារជាមួយពូ ដែលពូនិយាយរៀបរាប់ឈ្មោះ ខេច ឈ្មោះ យៃ ឈ្មោះ អយ ឈ្មោះ ធឿន នេះ អាយុប្រហាលៗពូដែរ?

សល់ : អាយុប្រហាលៗតែពួកខ្ញុំដែរស្ទួតៗនោះណា មនុស្សមិនបានដឹងនេះទេ។

ដារ៉ា : អីចឹងនៅក្នុងក្រុមរបស់ពូហ្នឹងមានអ្នកណាដែលមានវ័យចាស់ជាងគេណា?

សល់ : មិនសូវមានទេពួកខ្ញុំ សុទ្ធតែក្មេងៗ ពួកគេនោះក្រុមៗគេធំៗគេមានផ្សេង។

ដារ៉ា : ក្រុមតូចៗដូចក្រុមរបស់ពូអីចឹងមានអ្នកណាជាប្រធានក្រុមអីពីលើពូ ឬក៏មកឋានៈស្មើរៗគ្នា?

សល់ : ស្មើៗតែគ្មានសម្រាប់តែគេប្រើ។

ដារ៉ា : ស្មើៗគ្នា ចុះពេលយើងឈរយាមអ្នកណាសម្រេច អ្នកណាអី?

សល់ : យើងចេះតែដាសគ្នាទៅ យាមម្នាក់ម្តងទៅណា។

ដារ៉ា : អីចឹងពូ ដូចថាឈ្មោះតាសឿនអីចឹងពូ សព្វថ្ងៃពូដឹងថាគាត់នៅរស់ឬយ៉ាងម៉េចដែរ?

សល់ : នៅ!

ដារ៉ា : តាសឿននៅទេ!

សល់ : នៅ។

ដារ៉ា : គាត់នៅឯណាអីណា ដូចថាពូបានពត៌មានថាគាត់នៅឯណាអីណាដែរ?

សល់ : ដែលនៅហ្នឹងខ្ញុំខានឃើញប្រហែល៤,៥,៦ ឆ្នាំហើយ ដឹងថាស្លាប់រស់មិនដឹង កាលខ្ញុំឃើញ ឃើញ។

ដារ៉ា : ដែលពូជួបតាសឿន ចុងក្រោយនៅឯណាពូ?

សល់ : នៅសាស្តា។

ដារ៉ា : កាលពូជួបហ្នឹងពូទៅមានការអី?

សល់ : ខ្ញុំទៅនេះ ទៅរកស៊ីឈ្នួលគេណា កាចពោតដកដំឡូងអីណា ចង់ដឹងមើល ទៅសាកមើល ជួបឃើញគាត់។

ដារ៉ា : គាត់ស្គាល់ពូទេ?

សល់ : ឃើញស្គាល់! ខ្ញុំហៅពូៗ អ្នកណាដឹង ខ្ញុំឃើញគាត់។

ដារ៉ា : គាត់ស្គាល់គាត់ជាឈ្មោះ ដាអីម៉ង ឬស្គាល់តែមុខមាត់អីទេ?

សល់ ៈ ស្គាល់ឈ្មោះ ។

ដារ៉ា ៈ ស្គាល់ទាំងឈ្មោះទៀត!

សល់ ៈ បាទ!

ដារ៉ា ៈ កាលហ្នឹងឆ្នាំណាដែលពូជួបគាត់?

សល់ ៈ ប្រហែល៨,៩ឆ្នាំមុននេះ មិនដឹងឆ្នាំណា មិនបានចាំឆ្នាំទេ ។

ដារ៉ា ៈ ដល់ឃើញគាត់ចុងក្រោយហ្នឹង គាត់មានសភាពយ៉ាងម៉េចដែរ?

សល់ ៈ ចុងក្រោយហ្នឹងឃើញសួរថាម៉េចសុខសប្បាយទេចុះ សួរនាំទៅណា ហើនៅណា នៅឯណើ ខ្ញុំនៅជប់ អីចេះ អីចុះ ហើខ្ញុំសួរគាត់វិញថាពូឯងនៅឯណា ថាអញនៅនេះឯងថាអីចេះ នៅនោះឯងនៅសាស្ដា ។

ដារ៉ា ៈ សាស្ដាហ្នឹងជាភូមិជាឃុំពូ?

សល់ ៈ សាស្ដានោះកន្លែងផ្សារគេណា ផ្ទះគាត់នៅកន្លែងជាប់កាស៊ីណូណា ជាប់របងកាស៊ីណូខាងលិច ។

ដារ៉ា ៈ ឃើញគាត់កំពុងធ្វើអីពេលហ្នឹង?

សល់ ៈ ឃើញគាត់កំពុងតែមើលឈើ អារ៉ឹកយើង ។

ដារ៉ា ៈ រកស៊ីឈើ!

សល់ ៈ បាទ! កាលណុះអាយើងទើបកាប់ព្រៃកាប់ដីនោះ វាសំបូរអាឈើបេង ឈើអីច្រើនណា កាលនោះមានឈើសឹងគ្រប់តែផ្ទះនោះ កាលយើងអារ៉ឹកកាប់ឈើលក់ឲ្យថៃអីនោះ ។

ដារ៉ា ៈ កាស៊ីណូនោះគេហៅកាស៊ីណូអីគេពូ?

សល់ ៈ ខ្ញុំអត់ស្គាល់ផង កាស៊ីណូហ្នឹងមិនបានមើលអក្សរផង មិនបានមើលប៉ោយផង ។

ដារ៉ា ៈ អត់ដឹងឈ្មោះ អត់ដឹងអីទេណ៎?

សល់ ៈ អត់! ប៉ុនអានេះប្រកចេញទៅថៃ កាស៊ីណូអីចេះផ្ទះគាត់ កាស៊ីណូតែមួយផ្ទះគាត់ កាស៊ីណូតែមួយកាលខ្ញុំទៅណា ដល់ក្រោយទៀតមិនដឹងយ៉ាងណា ។

ដារ៉ា ៈ សាស្ដាហ្នឹងនៅក្នុងភូមិអីឃុំអីពូ?

សល់ ៈ អូ! អត់ស្គាល់ ក្នុងនោះវាមិនស្គាល់ច្បាស់ វាមានសំពៅលូន វាមានសាស្ដា វាមិនដឹងគេហៅភូមិសំពៅលូនដឹងអី ខ្ញុំក្ដាប់អត់បានទេអារឿងអីចុង ក្ដាប់អត់បានទេ ដល់ក្ដាប់អត់បាន ខ្ញុំមិនហ៊ាននិយាយពាសវាលពាសកាល ព្រោះវាអត់ដឹង ។

ដារ៉ា ៈ ពូថាតាសឿនគាត់មានពុកមាត់?

សល់ ៈ បាទ! ពុកមាត់ប្រមូម ។

ដារ៉ា ៖ ចុះកាលជំនាន់គាត់ធ្វើប្រធានសន្តិសុខនៅភ្នំត្រយោងហ្នឹងគាត់មានពុកមាត់ដែរ?

សល់ ៖ នៅតែមានអីចឹង តែមានគេកោៗ គេមិនទុកឲ្យវែងណា ។

ដារ៉ា ៖ ចុះឥឡូវ ពេលពូជួបគាត់ចុងក្រោយ?

សល់ ៖ ឃើញគាត់កោធម្មតា ។

ដារ៉ា ៖ នៅតែពុកមាត់អីចឹងឬពូ?

សល់ ៖ បាទ!

ដារ៉ា ៖ គាត់មានសុខភាព សុខអីម៉េចដែលពេលដែលពូជួបគាត់ចុងក្រោយ?

សល់ ៖ ដូចអត់អីដែរ ឃើញរៀនធម៌ រៀនអារ្យ រៀនអី គាត់រអែងមើលសៀវភៅ មើលអីណា សៀវភៅធម៌គាត់ ។

ដារ៉ា ៖ ចុះឈ្មោះ ភឹម នោះពូ?

សល់ ៖ បាត់អស់ហើយ ទៅស្រុក ទៅស្រែវិញអស់ហើយដឹង អត់ដឹងដែរ ព្រោះគេច្រើនតែអ្នកតាកែវអ្នកអីណាណី ព្រោះខ្ញុំមិនដែលស្គាល់អ្នកខេត្តតាកែវដែរ បែកបាក់គ្នាអស់ទៅណាអត់ដឹង ។

ដារ៉ា ៖ ចុះឈ្មោះ ថន?

សល់ ៖ ទៅស្រុកវិញអស់ទេដឹង ព្រោះបាត់មិនដឹងរាប់ដឹងរស់ ទៅស្រុកវិញហើយ វាបាត់ទៅមិនដឹងទៅឯណា ក្រោយមកបែកបាក់អស់ទៅណាទៅណីអស់ ។

ដារ៉ា ៖ ចុះឈ្មោះ ជន ពូធ្លាប់ឮទេ?

សល់ ៖ តាជនឬ?

ដារ៉ា ៖ បាទ!

សល់ ៖ តាជននោះ គាត់នៅព្រះនេត្រព្រះនេះតើសកាលពីពាយ័ព្យយើង គាត់អនុឃុំព្រះនេត្រព្រះ គាត់នៅឃុំព្រះនេត្រព្រះ ។

ដារ៉ា ៖ សព្វថ្ងៃគាត់នៅឯណា?

សល់ ៖ សព្វថ្ងៃកាលខ្ញុំទៅស៊ីឈ្នួលគេនោះឃើញគាត់ដើរ ខ្ញុំប្រកូកហៅគាត់ដែរ តាជន គាត់ងាកមើល គាត់ថាបាទ ខ្ញុំថានៅឯណា គាត់ចង្អុលអីចេះ ខ្ញុំមិនបានចុះពីលើឡានទេកាលហ្នឹងឃើញខ្ញុំហៅៗទៅណា កាលហ្នឹងគាត់នៅក្តាប់នេះឯង គាត់ធ្វើអនុឃុំ មេគាត់តាក្រក់ តាក្រក់នោះគាត់គណៈឃុំណា គាត់អនុប្រធាន តាក្រក់នោះស្លាប់ហើយ គាត់អ្នកខ្ទង់យើងនេះ ខ្ទង់សរស្តមនេះណា ។

ដារ៉ា ៖ ពេលដែលជួបតាជនហ្នឹង ជួបនៅម្តុំណា?

សល់ ៖ ជួបនៅម្តុំជិតភ្នំ៩៣ ភ្នំ៩៣ ខាងកើតមាំឡៃនោះ អាកូនភ្នំដែលមានវត្តនោះគេហៅភ្នំ៩៣ ដែលមានវត្តនៅលើភ្នំនោះណា ។

ដារ៉ា៖ មានវត្តមួយឬ?

សល់៖ ហ្នឹងហើយ មានកូនភ្នំតូចនោះណា ហ្នឹងគេហៅវត្ត៩៣ ភ្នំ៩៣ ។

ដារ៉ា៖ ជួនគាត់ក្នុងដំណើរជាអ្នកដំណើរដែរឬក៏គាត់ស្នាក់នៅហ្នឹង?

សល់៖ គាត់អត់ស្គាល់ទេ គាត់អត់ស្គាល់ខ្ញុំទេ ព្រោះខ្ញុំជិះឡានមក ចុះឡានឈ្នួលមក ដល់ឃើញគាត់ដើរ ខ្ញុំប្រកួកហៅគាត់ទៅណា ដល់ហៅគាត់ គាត់បាទពន្រៀស! ហើខ្ញុំ ឡានក៏វាមិនឈប់ណា ព្រោះខ្ញុំជិះឡានឈ្នួល អត់បាននិយាយគ្នាទេ អត់បាននិយាយគ្នាបន្តិចទេអីចឹងណា គាត់បាទពន្រៀសដែរ គាត់មិនស្គាល់ខ្ញុំទេ ខ្ញុំដឹង ។

ដារ៉ា៖ ពេលពូឃើញតាជនហ្នឹង គាត់ស្លៀកពាក់អីយ៉ាងម៉េចៗ ជាអ្នកស្នាក់នៅ ជាអ្នកស្រុកភូមិនៅ!

សល់៖ ដែលឃើញគាត់នោះ ជាអ្នកស្លៀកពាក់អ្នកស្រុកយើងធម្មតា ។

ដានី៖ គាត់អ្នកស្រុកនៅ ៩៣ ហ្នឹងម៉ែន ឬជាអ្នកដំណើរ?

សល់៖ តាជននោះ! ខ្ញុំក្តាប់ប្រវត្តិរូបគាត់មិនបានដែរ ព្រោះគាត់អតីត តាជននេះ មនុស្សគាត់មិនមែន មនុស្សដូចថាមកនៅសម័យ លន់ នល់ ក៏មិនដឹង សម័យប៉ុល ពត ដូចមិនមែនទេ សង្ស័យមកនៅស្រុកនេះពីសម័យ លន់ នល់ មនុស្សពីត្បូងដែរមកនៅណា តាមខ្ញុំមើលណា បើនេះសួរល្បេង ហ៊ុយ គាត់ដឹងប្រវត្តិ ។

ដានី៖ អត់ទេ! ខ្ញុំចង់សួរ ពេលដែលពូជួប...

សល់៖ បើខ្ញុំក្តាប់អត់បានទេ ។

ដារ៉ា៖ ពេលពូជួបគាត់នៅកន្លែង៩៣ ដែលពូមើលទៅថាគាត់ស្នាក់នៅហ្នឹង ឬក៏គាត់អ្នកដំណើរដូចពូដែរ?

សល់៖ អត់ទេ! គាត់អត់មែនអ្នកដំណើរទេ ។

ដារ៉ា៖ អីចឹងគាត់ដើរតាមផ្លូវទេ?

សល់៖ បាទ! ដើរតាមផ្លូវ ដើរទៅខ្ញុំប្រកួកហៅ ។

ដារ៉ា៖ គាត់ក៏ឆ្លើយដែរ?

សល់៖ ឆ្លើយ! បើតាមខ្ញុំក្តាប់សមាសភាពគាត់នោះ គាត់មិនដែលហ៊ានចូលស្រុកនេះទេ ប៉ុនមនុស្សគាត់ស្លូតដែរ ប៉ុនដល់ថាយើងសម័យកាលណុះដល់យើងធ្វើការទៅ ក៏ពេលដែលក្រោយមក វៀតណាមចូលមក គាត់ក៏បានចាក់ចេញអីចេះទៅ ក៏បែកបាក់ទៅ បានគាត់

មកគៀងនៅនោះទៅ គាត់ក៏មិនហ៊ានមកចូលស្រុកព្រះនេត្រព្រះទេ បើតាមខ្ញុំស្មាន មិនដែលហ៊ានមកទេ ខ្លាចតែខ្លួនឯងទេ ប៉ុនមនុស្សគាត់អ្នកចេះអ្នកដឹងណា ។

ដានី: ប្រពន្ធគាត់ឈ្មោះអីដែរ?

សល់: អត់ដែលស្គាល់ទេ ។

ដារ៉ា: មិនដែលស្គាល់ទេ?

សល់: បាទ! ប្រពន្ធគាត់ខ្ញុំអត់ស្គាល់ឈ្មោះ ។

ដារ៉ា: ធ្លាប់ឃើញមុខដែរ?

សល់: ឃើញ មនុស្សដាំងពេញតែខ្លួន មិនដឹងកើតអីអាដែងដាំង។ កាលពីដើមមក ។

ដានី: កើតអីគេដាំងហ្នឹង?

សល់: អាដាំងដូចគោដាំងនោះ របក។ ពេញខ្លួនប្រពន្ធគាត់ ។

ដារ៉ា: អូ! របកពពាលឬ?

សល់: បាទ! ពពាល ។

ដារ៉ា: ចុះប្រពន្ធតាសឿន?

សល់: អត់អីទេ ។

ដារ៉ា: នៅល្អល្អាចដូចយើងធម្មតា?

សល់: បាទ! មនុស្សតាសឿន មនុស្សលំដាប់ធន់លើ មនុស្សកាលីបលើ ក្រលាលើមនុស្ស ។

ដានី: កាលតាផននេះ កាលលោកពូជួបគាត់ ពូហៅគាត់តាផនអីចឹង ឬហៅឈ្មោះអីផ្សេង?

សល់: ខ្ញុំហៅតែតាផនហ្នឹង អឺ! តាផន ខ្ញុំហៅអីចឹង ។

ដានី: អីចឹងគាត់ងាកមក!

សល់: ងាកមក បាទ! ខ្ញុំស៊ើបសួរគេថាគាត់នៅ៩៣នេះឯង ក្នុំ៩៣ ។

ដានី: កាលលោកពូជួបគាត់ហ្នឹង កាលហ្នឹងគាត់អាយុប្រហែលប៉ុន្មាន?

សល់: តាផនចូលនេះហើយ បើយើងសព្វថ្ងៃចូល ៦០ កន្ទុយធំហើយ

ដារ៉ា: ៦០ កន្ទុយធំ!

សល់: បាទ! យើងថា កុំដល់៧០ ។ ៦៧, ៦៨ អីចឹងទៅណា អាហ្នឹងការស្មានទេណា ។

ដារ៉ា: ពូជួបតាផនហ្នឹងពេលពូធ្វើដំណើរទៅណា?

សល់: ដូចខ្ញុំនិយាយមិញអីចឹងថា ខ្ញុំទៅកាប់ពោត កាច់សណ្តែកគេ ។

ដារ៉ា: ជួបប៉ុន្មានឆ្នាំហើយពូ?

សល់: ៤,៥,៦ ឆ្នាំ ហើយ ។

ដារ៉ាៈ	ជួបដូចដំណាលជាមួយតាសឿនដែរ?

សល់ៈ	បាទ! ជួបអីចុះឯង ជួបដោយចៃដន្យអីចុងឯង ។

ដារ៉ាៈ	ក្នុងឆ្នាំជាមួយគ្នាពូ?

សល់ៈ	ទេ! តាជនក្រោយទេ ដូចថាមួយឆ្នាំម្នាក់ណា ។

ដានីៈ	ចុះតាសឿន ឥឡូវអាយុគាត់ប្រហែលប៉ុន្មានដែរ?

សល់ៈ	សព្វថ្ងៃខ្ទង់ប្រហែល ៦០, ៧០ ហើយទេដឹង ៦០ កន្ទុយធំ ៧០ អីអស់ហើយ អានេះតាមការស្មានទេណា ខ្ញុំវាយូខ្ញុំនេះក៏វាចូល៥០ជាងហើយដែរ ។

ដានីៈ	កាលពូនៅសន្តិសុខ ពូមានស្គាល់អ្នកដែលទៅជាប់គុកនៅហ្នឹងណា នៅស្រុកភូមិយើងអីចឹង លោកពូមានដែលធ្លាប់ស្គាល់គាត់ណាម្នាក់ទេ?

សល់ៈ	មានស្គាល់ខ្លះ ។

ដានីៈ	ចុះគាត់ដែលធ្លាប់ជាប់គុកនៅហ្នឹង គាត់មាននៅរស់អីនៅស្រុកភូមិយើងដែរទេ?

សល់ៈ	វាចម្រុះគ្នា ខ្លះក៏ស្រុកជិត ស្រុកឆ្ងាយមិនដឹងឯណាឯណីទេ ។

ដានីៈ	ពូមានចាំទេ អ្នកដែលជាប់នៅហ្នឹង ហើយពូថាស្គាល់ខ្លះ ឈ្មោះអីខ្លះទៅ?

សល់ៈ	សព្វថ្ងៃគាត់បួសហើយ គាត់លោកហើយ ។

ដារ៉ាៈ	គាត់ឈ្មោះអីពូ?

សល់ៈ	ល្បង ថង នៅព្រះនេត្រព្រះ បួស ។

ដានីៈ	ឈ្មោះអី?

សល់ៈ	ល្បង ថង ។

ដានីៈ	ថង គាត់បួសនៅព្រះនេត្រព្រះនេះ ។

សល់ៈ	បាទ!

ដារ៉ាៈ	វត្តព្រះនេទ្រព្រះនេះ!

សល់ៈ	បាទ!

ដារ៉ាៈ	មិនមែនថងដែលពូប្រាប់មុននោះទេ?

សល់ៈ	អូ! អានោះឈ្មោះ ថង ខាងយោធាទេ ផ្សេងទេ ល្បង ថង នេះបួស ។

ដានីៈ	ពីណាទៀតក្រៅពីលោកតា ថង?

សល់ៈ	ខ្ញុំមិនស្គាល់ទេ មិនស្គាល់គេអស់ទេមនុស្សវា ទៅដោយអីចុះៗ មិនសូវដែលស្គាល់គេអស់ទេ ឃើញតែមួយភ្លែតៗ ។

ដារ៉ាៈ	ម៉េចបានស្គាល់ឈ្មោះ ថង ហ្នឹងថាជាប់ឃុំឃាំងដែរ?

សល់ៈ នៅក្បែរខ្ញុំ គាត់សម្រាក់នៅក្បែរៗនោះណា ។

ដារ៉ាៈ នៅក្បែរកន្លែលពួឈរជើងហ្នុង?

សល់ៈ បាទ! គាត់នៅសម្រាក់នោះ ទៅក៏ស្គាល់ ខ្ញុំសួរគាត់ថានៅឯណាបង គាត់ថានៅព្រះនេត្រព្រះ ថារឿងអីបានគេបញ្ជូនមក គាត់ថានៅពង្រកនវ៉ាថាអីចេះ ថាគាត់ធ្វើទាហាន លន់ នល់ អីចេះអីចុះ ពូគាត់ប្រាប់នោះណា ប៉ុនគេមិនបានសម្លាប់ មិនបានធ្វើបាបអីក៏នៅរស់ដល់សព្វថ្ងៃទៅ ក្រោយមកគាត់ធ្វើទាហានទៅ គាត់រឺគ្រែតទៅ គាត់ក៏បានទៅបួសទៅអីចេះ គាត់បួសដោយខ្លួនគាត់ ដូចថារឺត្រែតហើយខ្ជិលនៅ ។

ដានីៈ ចុះពូនៅស្រុកព្រះនេត្រព្រះហ្នឹងមានប៉ុន្មានឃុំទៅ?

សល់ៈ ក្តាប់អត់បានទេ អត់ចាំបានទេ មិនដឹងប៉ុន្មានឃុំទេ ។

ដានីៈ ពូមានប្រសាសន៍ម៉េច ពូធ្លាប់នៅឃុំដប់វ៉ារី នៅឃុំរហាល ហើយនៅកន្លែងសន្តិសុខភ្នំត្រយោងហ្នុងមានឃុំភ្នំលៀប ហីឃុំព្រះនេត្រព្រះយើង!

សល់ៈ បាទ!

ដានីៈ ៤ឃុំ មានឃុំអីផ្សេងក្រៅពីបួនឃុំហ្នឹងទៀត?

សល់ៈ សព្វថ្ងៃដឹងគេបញ្ចូលឯណា ខាងឯណាឯណីផងទេ ។

ដានីៈ បាទ! ខ្ញុំចង់សួរពូកាលពីជំនាន់ពន្លាំណាពូ?

សល់ៈ ទេ! មានតែឃុំទាំងកាំ, ឃុំគិរីវ័ន្ត នេះ ។

ដានីៈ ឃុំទាំងកាំ, ឃុំគិរីវ័ន្ត!

សល់ៈ បាទ! ដប់វ៉ារីនេះ និងឃុំរហាល, ឃុំភ្នំលៀប អានេះខ្ញុំចាំបានតែប៉ុន្មានឃុំនេះ ផុតពីនោះមិនដឹងឯណាឯណីផង ក្តាប់មិនបានទេ ។

ដានីៈ ចុះលោកពូ ឃុំភ្នំលៀបកាលហ្នុង ពីណាគេគណៈឃុំ?

សល់ៈ អត់ស្គាល់ទេ យើងអត់ស្គាល់ទេ ក្តាប់អត់បាន យើងអត់ស្គាល់ ។

ដានីៈ គណៈឃុំក្តាប់អត់បានទេ?

សល់ៈ បាទ! កាលនោះដូចជាប់គុកអីចេះ មិនសូវបានទៅស្គាល់អ្នកណាស្គាល់អ្នកណីទេ ។

ដានីៈ កាលនៅរហាល តាណុប អីចឹងឬ?

សល់ៈ បាទ!

ដានីៈ ចុះលោកពូស្គាល់តាណុបឥឡូវគាត់នៅឯណាដែរ?

សល់ៈ ស្លាប់អស់ហើយ ។

ដារ៉ាៈ ស្លាប់ម៉េចទៅ?

សល់៖ ស្លាប់ដោយជម្ងឺខ្លួនគាត់ ។

ដារ៉ា៖ អីចឹងគាត់រស់រាណមានជីវិតមកក្រោយទៀតបានស្លាប់!

សល់៖ អត់ទេៗ!

ដារ៉ា៖ ស្លាប់នៅក្នុងរបបហ្នឹងម៉ង់ របបខ្មែរក្រហមហ្នឹងម៉ង?

សល់៖ ស្លាប់ដែលសម័យវៀតណាមចូលហើយ ដែលស្លាប់នោះដូចថាអស់បុណ្យ ជម្ងឺខ្លួនគាត់ទៅណា ចាស់ជរា ។

ដានី៖ ចុះឈ្មោះ ថា នារី ថា?

សល់៖ បាត់ទៅណា! វៀតណាមចូលមកក៏បែកបាក់គ្នាអស់ទៅ អត់បានជួបជុំគ្នាទេ ។

ដានី៖ ចុះកាលគាត់ទៅនៅភៀស ពូនៅដឹងថាគាត់នៅធ្វើអី តួនាទីគាត់ធ្វើអី?

សល់៖ ខ្ញុំប្រាប់ខាងដើមហើយថាខ្ញុំក្តាប់អត់បាន មិនដឹងថាគាត់នៅធ្វើឃុំដដែល មិនដឹងថាគាត់ធ្វើប្រធានសហករណ៍ ខ្ញុំក្តាប់អត់បានដែរ ព្រោះវាឆ្ងាយពីគ្នាណា បើយើងស្មានវាអត់ត្រូវ យើងដឹងអត់ដល់ប្រយោល ។

ដានី៖ ចុះលោកពូ កាលនៅជប់វ៉ារី គណៈឃុំឈ្មោះ រស់ អីគាត់នៅដែរឬក៏យ៉ាងម៉េច?

សល់៖ ពួកនោះ បើកាលណុះនៅ ដល់ចុងក្រោយដែលវៀតណាមមកវាបែកបាក់គ្នាអស់ មិនដឹងស្លាប់រស់អត់ដឹងដែរណា ព្រោះគេអ្នកដំណើរអ្នកឆ្ងាយៗយើងក្តាប់អត់បាន ។

ដានី៖ កាលនៅ ជប់វ៉ារី មានតា រស់ តាណុញ!

សល់៖ បាទ!

ដានី៖ ចុះតាណុញ ម៉េចដែរ?

សល់៖ តាណុញ គឺបាត់ដែរមិនដឹងទៅណាទេ ព្រោះគាត់ធ្វើខ្មែរក្រហមទៀតទៅ មិនដឹងថាគាត់ទៅខាងណា ។ គាត់កើតមេខ្មែរក្រហមទៀតទៅ គាត់ក៏ចេះតែរសាត់រសែទៅ សព្វថ្ងៃ ប៉ុនមិនដឹងទេ អ្នកខ្លះគេថានៅភ្នំប្រាល ភ្នំត្រាល ឯណាទេ ខ្ញុំមិនស្គាល់ដែរ ។

ដានី៖ ភ្នំអីគេ?

សល់៖ គេហៅភ្នំត្រាល ពូតែគេថាដែរ ថាគាត់នៅ ។

ដានី៖ ចុះលោកពូខាងឃុំទាំងកាំ?

សល់៖ ឯណា!

ដានី៖ ទាំងកាំគណៈឃុំគេឈ្មោះអីទៅ?

សល់៖ មានឈ្មោះប៉ុន្មានដែលកត់នៅ តាណុញ, ស, តារស់ នេះឯង ៣នាក់នេះ ។

ដានី៖ អាហ្នឹងក្រែងឃុំជប់វ៉ារី!

សល់ៈ ខ្ញុំភ្លាប់អាពីឃុំនេះអត់បាន កាលណុះវានៅស្ទើរៗទៅ ខ្ញុំហៅតែជប់វ៉ារីៗ ដូចនៅក្នុងឃុំទាំងកាំក៏មិនដឹង ដូចម៉េចក៏មិនដឹង ខ្ញុំដូចវាវង្វេងដែរ អាពីរកន្លែងនេះ ភ្លាប់អត់បានទេ វាដូចអំពិលអំពែកអីចឹងបើមួយថ្ងៃៗអត់ដែរបាននៅស្ងៀមនោះ តិចធ្វើអីចេះ តិចទៅណុះ ដូចវាលំបាកវាលំបិន នឹកឃើញថាវាមិនបានរស់ទេដឹងម្នាក់ៗ ការងារវាមិនបានឈប់ឈរនោះ ម៉ាថ្ងៃៗដងរែកដាប់តែនឹងស្មារក៏មានដែរ ។

ដានីៈ ចុះឃុំមួយទៀត?

សល់ៈ ឯណា ។

ដានីៈ ពូមានប្រសាសន៍មិញថាឃុំអី?

សល់ៈ ដែលថាឃុំទាំងកាំនោះឬ?

ដានីៈ ឃុំទាំងកាំហើយ ឃុំមួយទៀត ឃុំអី?

សល់ៈ ជប់វ៉ារីឬ ។

ដានីៈ ចុះនៅខាងព្រៃមាន់ ខាងអី?

សល់ៈ ព្រៃមាន់យើងនេះ ដូចនៅក្នុងឃុំរហាលទេ ចំណុះឲ្យឃុំរហាល ។

ដានីៈ នៅឃុំព្រះនេត្រព្រះយើង តាក្រក់គាត់ធ្វើប្រធាន?

សល់ៈ បាទ! ប្រធានឃុំ ។

ដានីៈ តាជនគាត់អនុ?

សល់ៈ បាទ!

ដានីៈ គាត់អនុតាំងអីអន្លាលមក?

សល់ៈ យូដែរ គាត់ធ្វើតាំងពី៧៥មិនដឹង ឧទាហករណ៍អីចឹងណា ព្រោះឃើញគាត់វាមុនគេដែរ តាក្រក់ តាជន ហ្នឹងណា ការស្មានទេណា ខ្ញុំដឹងមិនដល់ទេ តាំងពីកាលនោះមក ដល់និរតីមកគេដណ្ដើមភារៈកិច្ចពីគាត់នេះ ។

ដានីៈ គាត់នៅធ្វើអីវិញទៅដល់ពេលពួកនិរតីមក?

សល់ៈ ដល់ពួកនិរតីមកគាត់ក៏ គេចាប់តាក្រក់ទៅអស់ទៅ មេគាត់នោះណា គាត់ក៏អែបជាមួយនិរតីទៅ អែបបណ្ដែតៗទៅ ដែលមនុស្សគាត់ដូចជាសម្របខ្លួនតាមទៅណា ។

ដានីៈ អីចឹងគាត់នៅជាគណៈឃុំ ជាអនុឃុំហ្នឹងតាំងពី៧៥រហូតដល់៧៩ម៉េង?

សល់ៈ បាទ! ដល់នេះមកនៅអែបៗ បណ្ដែតៗ មិនដឹងថាបុណ្យសក្ដិគាត់នៅដដែល មិនដឹងជាយ៉ាងណា ខ្ញុំភ្លាប់មិនបានដែរ ប៉ុនឃើញតែគាត់នៅធ្វើការនៅអែបៗជាមួយគេហ្នឹង ។

ដានីៈ ពូដឹងពីការងារពីតួនាទីគាត់ដែរកាលសម័យនោះ?

សល់៖ តាជន!

ដានី៖ តាជន!

សល់៖ ដឹង! អ្នកធំយើងរហ័សដឹង ឧទាហរណ៍ថាយើងប្រជាជនអីក៏ដោយឲ្យតែគេអ្នកធំយើងរហ័សដឹងហើយ គេអ្នកធំគេរអែងដើរធ្វើការ ប្រជុំអីទៅក៏យើងអាចដឹងដែរ អ្នកនេះធ្វើនេះ អ្នកនោះធ្វើនោះ ឧទាហរណ៍ថាអីចឹង (សើច) បើអារឿងអ្នកតូចទៅសួររក មិនងាយស្គាល់ទេ បើអ្នកធំគេឆាប់ដឹងថានៅត្រង់ណេះនៅត្រង់ណុះហើយ ឧទាហរណ៍ណាដូចតែសព្វថ្ងៃអីចឹងតែអ្នកធំគេឆាប់ស្គាល់ហើយ បើថាប្រជាជនគេមិនងាយស្គាល់ទេ ។

ដានី៖ បន្ទាប់ពីគេចាប់តាក្រក់ទៅ គណៈឃុំព្រះនេត្រព្រះឈ្មោះអីទៅ?

សល់៖ ខ្ញុំអត់ដឹង ។

ដានី៖ និរតីឡើងមកណា?

សល់៖ បាទ! និរតីឡើងមក ណេះពួកនិរតីគេក្តាប់ ខ្ញុំក្តាប់អត់បានទេ អត់ដឹងទេ ព្រោះខ្ញុំ ដូចខ្ញុំថាម៉េចអីចឹង បែកគ្នាអស់ក្តាប់អត់បានទេ អានេះទល់តែសួរ តា ហ៊ុយ តាអី តាហ៊ុយនៅនេះដឹងកាលណុះ ។

ដានី៖ ពូកាលហ្នុង ពូស្គាល់ភូមិត្រពាំងវែងទេ?

សល់៖ ត្រពាំងវែងនៅព្រះនេត្រព្រះនេះ?

ដានី៖ បាទ!

សល់៖ ត្រពាំងវែងដូចជានៅអាកន្ទែងរថក្រោះសព្វថ្ងៃ ។

ដានី៖ កាលហ្នុងប្រធានភូមិគេឈ្មោះអី?

សល់៖ ខ្ញុំអត់ស្គាល់ទេ ។

ដានី៖ ពូដែលស្គាល់ឈ្មោះនារីម៉ន, នារីហាន នារីអូន អីទេ?

សល់៖ អត់ទេ! យើងអត់ដែលបានទំនាក់ទំនងគ្នាទេ សឹងតែថាពីភូមិមួយទៅភូមិមួយបើអត់មានការ គឺអត់ដែរស្គាល់ ព្រោះគេអត់ឲ្យដើរណា ដើរសុទ្ធតែសុំច្បាប់គេ វាតឹងពេកណាក្រៅពីអង្គភាពគ្នាយើង ឧទាហរណ៍ថាធ្វើការអីចឹងបានស្គាល់ បើថាទៅឆ្លងកាត់អីចេះចុះឲ្យស្គាល់ អូអត់មានដូចសព្វថ្ងៃនេះទេវាតឹងពេក ទៅណាក៏សុំច្បាប់គេ បើគេអនុញ្ញាតិឲ្យបានបើគេថាទេ គឺអត់ហើយ ច្បាប់គេអីចុះ ។

ដានី៖ បើយាយចែម ពូ ស្គាល់គាត់ច្បាស់ទ៌?

សល់៖ ច្បាស់នោះ ច្បាស់ត្រង់ថា គាត់តែងមកប្រជុំទៅស្គាល់ ស្គាល់នោះក៏យើងមិនបានទៅទំនាក់ទំនង ទៅនិយាយ ទៅស្តី អត់ដែលទេ គ្រាន់តែឃើញៗណា ។

ដានី: គាត់តួនាទីអីកាលហ្នឹង?

សល់: គាត់ចៅហ្វាយស្រុក ។

ដានី: ចៅហ្វាយស្រុកអីគេ?

សល់: ខ្ញុំភ្លេចមិនបានកាលនោះ គាត់ចៅហ្វាយស្រុក មិនដឹងគាត់គណៈតំបន់ណា ព្រោះប្តីគាត់ធ្វើចៅហ្វាយស្រុកភ្នំស្រុក ។

ដានី: ប្តីគាត់ចៅហ្វាយស្រុកភ្នំស្រុក?

សល់: បាទ!

ដានី: ឈ្មោះអីទៅប្តីគាត់?

សល់: ឈ្មោះ ញ៉ៀន មិនថាផាប់ មិនដឹងថារស់សព្វថ្ងៃខ្ញុំមិនដឹងផង ។

ដានី: ចុះស្រុកព្រះនេត្រព្រះ?

សល់: គណៈស្រុកព្រះនេត្រព្រះនេះ អានេះខ្ញុំនិយាយទៅហើយខ្ញុំមិនដែលបានជិតស្និទ្ធទេណា ចៅហ្វាយស្រុកព្រះនេត្រព្រះនេះឈ្មោះតាម៉ោង ប្រធានស្រុក ចៅហ្វាយស្រុក ទី២តាសំអាត ប៉ុនអស់ហើយ ។

ដានី: គាត់ស្លាប់ឬ?

សល់: គេចាប់យកទៅអស់ហើយ ។

ដានី: ពួកណាចាប់?

សល់: ពួកនិរតីដែលគេចូលមកនេះ ដណ្តើមអំណាចគ្នាទៅ គេចាប់អស់បាត់ ។

ដានី: ដល់ពេលចាប់តាម៉ោង តាសំអាតទៅពីណាគេឡើង?

សល់: ដល់ក្រោយមិនដឹងអ្នកណាអ្នកណីទេ វាច្របូកវាច្របលនោះ វាពិបាកសន្និដ្ឋាន វាអស់ច្រើនខ្សែណាស់ ។

ដានី: យាយថែមគាត់មកពេលណាកាលហ្នឹង?

សល់: គាត់មក ខ្ញុំចាប់ឃើញគាត់ ឃើញៗ មិនដឹងថាគាត់មកពីឆ្នាំណាដែរទេណា ប៉ុន្តែខ្ញុំឃើញគាត់ដូចជាឆ្នាំ៧៧ បាទនេះជាការស្មានរបស់ខ្ញុំណា ខ្ញុំក៏ដឹងមិនច្បាស់ដែរ ដែលខ្ញុំឃើញនោះ ៧៧, ៧៨ ហ្នឹងឯង តែមុនៗនោះខ្ញុំភ្លេចអត់បានទេ ដូចខ្ញុំថាអិចឹង មិនដែលបានដើរឃើញគេទេ ។

ដានី: គាត់មកជំនួសតាម៉ោងហ្នឹងឬក៏យ៉ាងម៉េច? .

សល់: មិនដឹងដល់កាលណុះពុកតែគណៈស្រុកគណៈអី មិនដឹងម៉េចនៅខែភ្នំលៀបនោះឯង ដូចជាគណៈស្រុក គណៈអីម៉េចទេ ពុកតែគេហៅយាយថែមៗហ្នឹង ។

ដានី៖ យាយថែមគាត់ស្គាល់សន្តិសុខភ្នំត្រយោងទេ?

សល់៖ នៅជិតគ្នាហ្នឹងឯង ភ្នំត្រយោង និងភ្នំលៀប ប៉ុន្មានគីឡូម៉ែត្រហ្នឹងឯង ។

ដានី៖ ពីផ្ទះគាត់ទៅភ្នំត្រយោងប្រហែលជាប៉ុន្មានទៅ?

សល់៖ ប្រហែលជា៣,៤,៥,គីឡូ មិនដឹង ការស្មានទេណា នៅកៀកដែរ ។

ដានី៖ ពូមានស្គាល់ពីណាដែលបន្ទាប់ពីយាយថែមមក ឋានៈបន្ទាប់ៗពីគាត់ទៀតណា?

សល់៖ អត់ទេ! អត់ដែលស្គាល់ទេ មិនមែនថាលាក់ទេ គឺអត់ស្គាល់ ។

ដារ៉ា៖ ពូ! មិញពូមានប្រសាសន៍ថា ពូស្គាល់យាយថែមដោយសារតែយាយថែមដើរប្រជុំកន្លែងនេះ កន្លែងនោះអីចឹង?

សល់៖ បាទ! មកប្រជុំប្រជាជនអីណា ។

ដារ៉ា៖ អីចឹងក្នុងម៉ារយៈកាលដែលពូរស់នៅកន្លែងភ្នំត្រយោង ឬក៏មុនហ្នឹងអីចឹងណា ពូធ្លាប់បានចូលរួមប្រជុំ ដែលយាយថែមហៅទៅប្រជុំ ឬក៏គាត់ចុះមកប៉ុន្មានដងដែរ?

សល់៖ អត់ទេ! ទៅតែម្ដងគត់ គាត់ហៅទៅផ្ទះគាត់តែម្ដង ហៅទៅប្រជុំតែម្ដង វៀតណាមចូលបណ្ដោយ អត់បានទៅញឹកញាប់អីចឹងទេ ។

ដារ៉ា៖ ចុះពីមុនមក ពូអត់ដែលឮឈ្មោះយាយថែមទេ មុននឹងទៅភ្នំត្រយោងហ្នឹងណា?

សល់៖ គាត់មកប្រជុំដល់រហាល ។

ដារ៉ា៖ មកប្រជុំដល់រហាល!

សល់៖ បាទ! គាត់មកប្រជុំដល់រហាល ។

ដារ៉ា៖ អីចឹងកាលពូនៅរហាលហ្នឹងបានឃើញយាយថែមទេ?

សល់៖ ឃើញ! គាត់មកប្រជុំប្រជាជន ។

ដារ៉ា៖ ពូបានចូលរួមប្រជុំជាមួយប្រជាជនហ្នឹងដែរ?

សល់៖ បាទ!

ដារ៉ា៖ នៅរហាល!

សល់៖ បាទ! គាត់មកប្រជុំប្រជាជនហ្នឹងឯងយើងឃើញ ។

ដារ៉ា៖ ចុះនៅជប់វ៉ារី ពូបានឃើញយាយថែមទេ?

សល់៖ ខ្ញុំអត់បានឃើញទេ ឃើញតែគាត់នៅរហាលទេណា ។

ដារ៉ា៖ ពូបានឃើញប៉ុន្មានដងនៅរហាល?

សល់៖ ឃើញតែម្ដងដែលមកប្រជុំ ។

ដារ៉ា៖ កាលចូលរួមនៅរហាលហ្នឹងយាយថែមនិយាយថាម៉េចខ្លះ?

សល់៖ កាលណុះគេប្រជុំនិយាយតែពីរឿងការងារដូចថាបង្កបង្កើនផល គេនិយាយតែពីរឿងបង្កបង្កើនផល ឲ្យយើងខំបម្រើការងារឲ្យអង្គការឲ្យអី គេនិយាយតែក្នុងច្បាប់ការងាររបស់គេហ្នុងណា ពាក្យកុម្មុយនិស្តគេនោះពិបាកណាស់ ។

ដារ៉ា៖ អ៊ីចឹងពេលដែលតាណុប បញ្ជូនពូឲ្យទៅនៅមន្ទីរសន្តិសុខភ្នំត្រយោងហ្នុង ពូបានឃើញយាយចែម ម្តងទៀត?

សល់៖ បាទ! បានឃើញម្តងទៀតដែលវៀតណាមជិតចូល ហៅទៅប្រជុំណា ។

ដារ៉ា៖ ពេលដែលពូទៅនៅមន្ទីរសន្តិសុខភ្នំត្រយោងហ្នុង ពូមានដឹងថាយាយចែមហ្នឹងនៅក្បែរៗហ្នឹងដែរទេ ក្បែរភ្នំត្រយោងហ្នឹង ពូបានដឹងទេ?

សល់៖ ដឹងភូមិគាត់នោះ!

ដារ៉ា៖ បាទ!

សល់៖ ដឹងតើស! ឃើញនៅផ្ទះ កាលនោះផ្ទះគាត់នៅណា ដល់សព្វថ្ងៃបាត់រប៉ាយអស់ហើយមិនដឹងទៅណា ។

ដារ៉ា៖ ពូបាននិយាយថា ពូបានដឹងយាយចែមនៅកន្លែងភ្នំត្រយោងហ្នុង គឺនៅពេលដែលយាយចែមហៅមកប្រជុំ!

សល់៖ គាត់ហៅពីត្រយោងមកជុំនៅភ្នំលៀប គាត់នៅភ្នំលៀប ។

ដារ៉ា៖ អ៊ីចឹងពេលដែលពូនៅភ្នំត្រយោងហ្នុង ពូមានដឹងថាយាយចែមនៅភ្នំលៀបពីមុនមកដែរទេ?

សល់៖ ដឹង!

ដារ៉ា៖ ដឹងតាមរយៈម៉េចទៅពូ?

សល់៖ ដឹងដូចថាយើងទៅ គេអ្នកធំដូចខ្ញុំថាអ៊ីចឹង គេឆាប់ឃើញ ព្រោះវាមានកន្លែងគេ តែនេះវាមានអ្នកការពារ មានអីទេហើយណា ឆាប់ឃើញ ទៅក៏គេនិយាយប្រាប់ថាកន្លែងនេះកន្លែងរបស់យាយចែម អីចេះអីចុះឧទាហរណ៍អ៊ីចឹងណា ទៅក៏យើងចំណាំថាកន្លែងរបស់យាយចែម អីចេះទៅ ។

ដារ៉ា៖ អ៊ីចឹងពេលដែលពូទៅនៅមន្ទីរសន្តិសុខភ្នំត្រយោងហ្នឹងមុននឹងបានជួបយាយចែមដែលហៅពូមកប្រជុំហ្នឹង ពូបានដឹងថាយាយចែមបាននៅកន្លែងហ្នឹងតាំងពីមុនមកដែរហើយ?

សល់៖ បាទ! ខ្ញុំដឹង ។

ដារ៉ា៖ ដឹងហ្នឹង ដឹងតាមរយៈម៉េច?

សល់៖ គាត់នៅជិតផ្ទល់វាឆាប់ឃើញ ។

ដារ៉ា៖ អីចឹងពូធ្លាប់ចេញចូលពីភ្នំត្រយោងហ្នុងមកផ្ទល់ដែរបានពូឃើញយាយចែម?

សល់៖ បាទ! ព្រោះផ្លូវហ្នុងវាចេញចូលមកមាត់ផ្លូវនេះឯង ផ្ទះគាត់នៅដូចថា ឧទាហរណ៍ថា នេះភ្នំលៀប គាត់នៅអីចេះទៅ អាផ្លូវយើងចេញចូលអីចេះទៅ ផ្ទះគាត់នៅខាងណោះ យើងទៅមក ដូចថាទៅភ្នំលៀបអីចេះ ទៅយើងឆាប់ឃើញ នៅខាងស្ដាំកាលហ្នុងណា ប៉ុនសព្វថ្ងៃខ្ញុំភ្លេចកន្លែងអស់ហើយ ព្រោះសព្វថ្ងៃវាអស់ផ្ទះអស់អី គេធ្វើថ្មី ធ្វើអី ដូចថារបស់អ្នកស្រុកទៅវិញទៅ មិនដឹងឯណាឯណី ចំណាំមិនបានទេវង្វេងវង្វន់អស់ហើយ សព្វថ្ងៃ ។

ដានី៖ ពូដែលស្គាល់ឈ្មោះ តាកាន់ ទេ?

សល់៖ អត់ស្គាល់ទេ ។

ដានី៖ បាទលោកពូ ពួកខ្ញុំដូចជាអស់សំណួរអីត្រូវសួរនាំលោកពូទៀតហើយ អីចឹងលោកពូមាន អីចង់បញ្ជាក់បន្ថែមនូវអ៊ីដែលពួកខ្ញុំអត់ទាន់បានសួរនាំពូអី?

សល់៖ មិនដឹងថាមានអី ខ្ញុំអត់ចេះនិយាយផង ប៉ុនថានិយាយនេះ ប៉ុនប្រាប់នេះ ប្រាប់ប្រវត្តិ របស់ខ្ញុំអស់ហើយ រៀបរាប់អស់ហើយ ។

ដារ៉ា៖ អីចឹងបើសិនជាយើងយកប្រវត្តិរបស់ពូដែលរៀបរាប់ទាំងប៉ុន្មាននេះយកទៅសរសេរ ជាអត្ថបទ ជាអីចឹងបានទេពូ អត់អីទេឬ?

សល់៖ សរសេរអត្ថបទដាក់យ៉ាងម៉េច?

ដារ៉ា៖ សរសេរពីឆាកជីវិតរបស់ពូ ពីអីចឹងដើម្បីឲ្យក្មេងជំនាន់ក្រោយបានសិក្សា បានយល់ពី ពិសោធន៍ដែលអ្នកដែលធ្លាប់បានឆ្លងកាត់ហ្នឹងបានរស់នៅបានអីចឹងណា ដូចជាមេរៀន សម្រាប់ក្មេងជំនាន់ក្រោយអីចឹង ពូមិនយល់ទាស់ទេឬ?

សល់៖ ទេ! ខ្ញុំអត់មានយល់ទាស់អីទេ ស្រេចតែខាងផ្នែកការងារនោះ បើថាមើលទៅសមស្របថា ធ្វើម៉េច ចុះជាសៀវភៅ ជាឯកសារធ្វើទៅ ខ្ញុំមិនដឹងថាម៉េចដែរ ព្រោះការងារខាងគាត់ ខាងណុះ ។

ដារ៉ា៖ អីចឹងពួកខ្ញុំអរគុណពូច្រើន ដែលពូបានចំណាយពេលវេលាសម្ភាសន៍ជាមួយពួកខ្ញុំ ។

សល់៖ បាទ!

ដារ៉ា៖ ដូចពូបានបញ្ជាក់ម្ដងហើយពូ ថាស្រុកកំណើតរបស់ពូនៅភូមិ...

សល់៖ ភូមិស្ទឹងកំបត់ ។

ដានី៖ ឃុំអី?

សល់៖ ឃុំរហាល ។

ដានី៖ ស្រុកព្រះនេត្រព្រះ?

សល់៖ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ពីដើមណា ។

ដានី៖ សព្វថ្ងៃពូរស់នៅក្នុងភូមិ?

សល់៖ បាទ! ខ្ញុំរស់នៅក្នុងភូមិដប់ចក្រី ។

ដានី៖ ភូមិដប់ចក្រីហ្នឹងនៅក្នុងឃុំព្រះនេត្រព្រះឬពូ?

សល់៖ ឃុំដប់វៀរី ។

ដានី៖ ស្រុកព្រះនេត្រព្រះ!

សល់៖ បាទ!

ដានី៖ អឺចឹង ពួកខ្ញុំអរគុណពូច្រើន!

សល់៖ បាទ!